Public Disclosure Authorized
Public Disclosure Authorized
Public Disclosure Authorized
Public Disclosure Authorized

100537

# បច្ចុប្បន្នភាពសេដ្ឋកិច្ចកម្ពុជា



# ការកែសម្រួលដើម្បីបន្តភាពប្រកួតប្រជែង

## ប្រធានបទពិសេស

## កសិកម្មកម្ពុជាក្នុងអន្តរកាលៈ កាលានុវត្តភាព និងហានិភ័យ

WORLD BANK GROUP

ខែតុលា ឆ្នាំ២០១៥

# ការកែសម្រួលដើម្បីបន្តភាពប្រកួតប្រជែង

## បច្ចុប្បន្នភាពសេដ្ឋកិច្ចកម្ពុជា

## ខែតុលា ឆ្នាំ២០១៥

@ រក្សាសិទ្ធិគ្រប់យ៉ាង

បច្ចុប្បន្នភាពសេដ្ឋកិច្ចកម្ពុជានេះគឺជាផលិតផលរបស់ធនាគារពិភពលោក។

របកគំហើញ ការបកស្រាយ និងការសន្និដ្ឋាន នៅក្នុងបច្ចុប្បន្នភាពសេដ្ឋកិច្ចកម្ពុជានេះគឺជារបកគំហើញ ការបកស្រាយ និងការសន្និដ្ឋានរបស់បុគ្គលិកធនាគារពិភពលោក និងមិនប្រាកដថាឆ្លុះបញ្ចាំងពីទស្សនៈរបស់គណៈគ្រប់គ្រងរបស់ធនាគាររបស់ក្រុមប្រឹក្សាភិបាល ឬរដ្ឋាភិបាលដែលធនាគារពិភពលោកតំណាងនោះទេ។

ធនាគារពិភពលោកមិនធានាពីភាពត្រឹមត្រូវនៃទិន្នន័យដែលមាននៅក្នុងរបាយការណ៍នេះទេ។

# អារម្ភកថា និងសេចក្តីថ្លែងអំណរគុណ

របាយការណ៍បច្ចុប្បន្នភាពសេដ្ឋកិច្ចកម្ពុជា (CEU) គឺជាផលិតផលមួយរបស់បុគ្គលិករបស់ធនាគារពិភពលោក។ ផលិតផលនេះត្រូវបានរៀបចំដោយ លោក លី សូដេត ហើយលោកមីហ្គែល អេកាដូ សានឆេហ្ស ម៉ាទីន (Miguel Eduardo Sánchez Martín) ជាអ្នកបញ្ចូលយោបល់ចំពោះរបាយការណ៍នេះ។ លោក លី សូដេត (Sodeth Ly) ហើយលោកមីហ្គែល អេកាដូ សានឆេហ្ស ម៉ាទីន (Miguel Eduardo Sánchez Martín) បំពេញការងារក្នុងផ្នែកម៉ាក្រូសេដ្ឋកិច្ច និងការអនុវត្តការគ្រប់ គ្រងសារពើពន្ធពិភពលោក (MFMGP)។ កញ្ញា គី លីនណា (Linna Ky) មានតួនាទីជាជំនួយការស្រាវជ្រាវ។ ក្រុមការងារធ្វើការក្រោមការដឹកនាំរបស់លោកម៉ាសូ អេ វើហ្គិស (Mathew A. Verghis) ប្រធានផ្នែកការអនុវត្តនៃ MFMGP ។ លោកសឺហ្គី ហ្សូរីយា (Sergiy Zorya) ទទួលខុសត្រូវផ្នែកការអនុវត្តកសិកម្ម បានរួមចំណែកទៅលើចំណុចស្តីពី បញ្ហាពិសេសនៃកសិកម្មកម្ពុជាក្នុងអន្តរកាលៈ កាលានុវត្តភាព និងហានិភ័យ។ ក្រុមអ្នកនិពន្ធសូមថ្លែងអំណរគុណចំពោះយោបល់ ការប្រឹក្សា និងការណែនាំ ដែលលោកអូលរិក ហ្សាចៅ (Ulrich Zachau) នាយកប្រចាំប្រទេសកម្ពុជាសម្រាប់អាស៊ីបូព៌ា និងប៉ាស៊ីហ្វិក និងលោកអាឡាសាន សូ (Alassane Sow) និងលោកសាបីស អាលីមូហីប (Shabih Ali Mohib) នាយកគ្រប់គ្រងធនាគារពិភពលោកប្រចាំកម្ពុជា បានផ្តល់ជូន។

របាយការណ៍បច្ចុប្បន្នភាពនេះត្រូវបានផលិតរៀងរាល់ឆមាស ដើម្បីផ្តល់ព័ត៌មានថ្មីៗលើការអភិវឌ្ឍផ្នែកម៉ាក្រូសេដ្ឋកិច្ចនៅកម្ពុជា។ របាយការណ៍បច្ចុប្បន្នភាពនេះត្រូវបានបោះពុម្ពផ្សាយ និងចែកចាយយ៉ាងទូលំទូលាយទៅកាន់អាជ្ញាធរកម្ពុជា សហគមន៍ដៃគូអភិវឌ្ឍន៍ វិស័យឯកជន ក្រុមអ្នកវិភាគ និង រៀបចំគោលនយោបាយ អង្គការសង្គមស៊ីវិល អង្គការមិនមែនរដ្ឋាភិបាល និងអ្នកសិក្សាស្រាវជ្រាវ ។ របាយការណ៍បច្ចុប្បន្នភាពនេះត្រូវបានកំណត់ពេលឲ្យស្របជាមួយនឹងការបោះពុម្ពផ្សាយបច្ចុប្បន្នភាពសេដ្ឋកិច្ចអាស៊ីបូព៌ារបស់ផ្នែកម៉ាក្រូសេដ្ឋកិច្ច និងការអនុវត្តការគ្រប់គ្រងសារពើពន្ធពិភពលោក (MFMGP)នៃធនាគារពិភពលោក។

យើងបានទទួលយោបល់ និងសំណើរដ៏មានតម្លៃពី (Ahmad Ahsan) ប្រធានអង្គភាពសេដ្ឋវិទូប្រចាំអាស៊ី បូព៌ា និងប៉ាស៊ីហ្វិក លោកស្រី រ៉ាឆាដា អនាន់តាវ៉ា ស៊ីលប៉ា (Ratchada Anantavrasilpa) ទទួលបន្ទុកផ្នែកការអនុវត្តផ្នែកហិរញ្ញវត្ថុ និងទីផ្សារពិភពលោក លោក គង់ មុនីច័ន្ទ (Munichan Kung) ទទួលបន្ទុកផ្នែកការអនុវត្តផ្នែកអភិវឌ្ឍសង្គម ជនបទ ទីប្រជុំជន ពិភពលោក និងលោកស្រី លា អេព្រិល (Leah April) ទទួលបន្ទុកផ្នែកការអនុវត្តផ្នែកអភិបាលកិច្ចពិភពលោក។ របាយការណ៍នេះក៏ទទួលបានការរួមចំណែកពីយោបល់ ការណែនាំ និងទស្សនៈរបស់ភាគីពាក់ព័ន្ធជាច្រើននៅក្នុងរាជរដ្ឋាភិបាលកម្ពុជា វិស័យឯកជន ស្ថាប័នដៃគូអភិវឌ្ឍន៍ និងអ្នកសិក្សាស្រាវជ្រាវ។ ក្រុមការងារសូមអរគុណចំពោះពួកគាត់ដែលបានចំណាយពេល និងផ្តល់ការរួមចំណែក។

យើងសូមថ្លែងនូវសេចក្តីដឹងគុណយ៉ាងខ្លាំងចំពោះអាជ្ញាធរកម្ពុជា ពិសេសក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និងធនាគារជាតិនៃកម្ពុជា ចំពោះកិច្ចសហប្រតិបត្តិការ និងការគាំទ្ររបស់គាត់ក្នុងការរៀបចំរបាយការណ៍បច្ចុប្បន្នភាពសេដ្ឋកិច្ចកម្ពុជានេះ។

ក្រុមការងារផ្នែកទំនាក់ទំនងនៅកម្ពុជាដែលរួមមានលោក ប៊ូ សារឿន (Saroeun Bou) និងលោកស្រី សុភានិត សំអឿន (Sophinith Sam Oeun) បាន រៀបចំអត្ថបទផ្សព្វផ្សាយតាមសារព័ត៌មាន អត្ថបទបង្ហាញតាមគេហទំព័រ និងតាមប្រព័ន្ធផ្សព្វផ្សាយ ផ្សេងទៀត។

សម្រាប់ព័ត៌មានអំពីធនាគារពិភពលោក និងសកម្មភាពរបស់ធនាគារនៅកម្ពុជា សូមចូលទៅមើលនៅ www.worldbank.org/cambodia។

ដើម្បីដាក់បញ្ចូលទៅក្នុងបញ្ជីចែកចាយបច្ចុប្បន្នភាពសេដ្ឋកិច្ចកម្ពុជាតាមអ៊ីម៉ែល និងឯកសារបោះពុម្ពផ្សាយពាក់ព័ន្ធ សូមទាក់ទង កញ្ញា គី លីនណា តាមសារអេឡិកត្រូនិច lky@worldbank.org។ សម្រាប់សំណួរស្តីពីខ្លឹមសានៃការបោះពុម្ពផ្សាយនេះ សូមទាក់ទងលោក ប៊ូ សារឿន (sbou@worldbank org)។

# មាតិកា

ក. សេចក្តីសង្ខេប ........ 1
ខ. វឌ្ឍនភាពផ្នែកសេដ្ឋកិច្ចនាពេលថ្មីៗនេះ ........ 6
ទិដ្ឋភាពទូទៅ ........ 6
វិស័យផលិតកម្ម ........ 8
ក) វិស័យសំណង់ និងអចលនទ្រព្យ ........ 8
ខ) វិស័យកាត់ដេរ ........ 9
គ) វិស័យទេសចរណ៍ ........ 11
ឃ) វិស័យកសិកម្ម ........ 14
ង) ប្រាក់ចំណូល ការប្រើប្រាស់ និងការងារ ........ 15
វិស័យទូទាត់ក្រៅប្រទេស ........ 17
ក) ការនាំចេញ ........ 18
ខ) ការនាំចូល ........ 19
អតិផរណា ........ 19
វិស័យរូបិយវត្ថុ ........ 20
ក) រូបិយវត្ថុសរុប អត្រាការប្រាក់ និងអត្រាប្តូរប្រាក់ ........ 20
ខ) វិស័យធនាគារ ........ 21
វិស័យសារពើពន្ធ ........ 23
ក) សមាសភាគចំណូល ........ 23
ខ) សមាសភាគចំណាយ ........ 25
គ) តុល្យភាពសារពើពន្ធ ........ 26
គ. សារគន្លឹះ និងអនុសាសន៍ ........ 27
ឃ. ប្រធានបទពិសេស ៖ អន្តរកាលនៃវិស័យកសិកម្មកម្ពុជា ៖ ហានិភ័យ និងកាលនុវត្តភាព ........ 29
សេចក្តីផ្តើម ........ 29
ប្រវត្តិកំណើនកសិកម្មកាលពីមួយទសវត្សរ៍កន្លងទៅនេះគឺជាជោគជ័យមួយក្នុងចំណោមជាច្រើន........ 29
... ប៉ុន្តែ មានបញ្ហាប្រឈមជាច្រើន ........ 31
អ្វីដែលដំណើរការល្អពីពេលមុន នឹងលែងគ្រប់គ្រាន់សម្រាប់ពេលអនាគតហើយ ........ 34
អនុសាសន៍ ៖ ........ 36

# ក. សេចក្តីសង្ខេប

*កំណើន ផសស ដ៏រឹងមាំនៅតែបន្តកើតមាន ហើយអាជ្ញាធរបានកែប្រែកំណើនពិតសម្រាប់ឆ្នាំ២០១៤ ទៅ ៧,១%លើសពីកម្រិតកំណើន ៧% ដែលបានប៉ាន់ស្មានកាលពីពេលមុន។ តម្រូវការក្នុងស្រុកខ្លាំងក្លា ដែលជំរុញដោយកំណើនខ្ពស់ផ្នែកសំណង់ និងជួយសម្រួលដោយកំណើនឥណទានក្នុងស្រុកច្រើន បានប៉ះប៉ូវចំពោះការថយចុះកំណើននៃការនាំចេញ ដោយក្នុងឆមាសទីមួយក្នុងឆ្នាំ ២០១៥ នេះ មានការថយចុះកំណើនក្នុងផ្នែកនាំចេញសម្លៀកបំពាក់ ទេសចរណ៍ និងកសិកម្ម។ ដោយសារជាប្រទេសនាំចូលប្រេងឥន្ធនៈ កម្ពុជាបានទទួលការ ចំណេញពីការធ្លាក់ចុះតម្លៃប្រេង ដែលបានរួមចំណែកចំពោះការសន្សំប្រាក់ពីការនាំចូលប្រេង។ ក្នុងស្ថានភាពនេះ កំណើនត្រូវបានព្យាករណ៍ថានឹងមានសន្ទុះថយចុះបន្តិចមកត្រឹម ៦,៩% ក្នុងឆ្នាំ ២០១៥។ ហានិភ័យមួយចំនួនដែលអាចធ្វើឲ្យប៉ះពាល់ដល់កំណើនសេដ្ឋកិច្ចរឹងមាំដែលបានប៉ាន់ស្មាននេះ រួមមាន លទ្ធភាពនៃការរំដើប រំជួលឡើងវិញនៃកម្លាំងពលកម្ម ការឡើងថ្លៃប្រាក់ដុល្លាអាមេរិកថែមទៀត ភាពយឺតយ៉ាវនៃការងើបឡើងវិញនៃសេដ្ឋកិច្ចនៅអឺរ៉ុប និងការធ្លាក់ចុះនៃសេដ្ឋកិច្ចប្រទេសចិន។*

### *វឌ្ឍនភាពនាពេលថ្មីៗកន្លងទៅ*

**កំណើន ផសស កាន់តែពឹងផ្អែកទៅលើការប្រើប្រាស់ និងការវិនិយោគ។** នៅក្នុងបរិបទនៃការធ្លាក់ចុះតម្លៃប្រេង និងកំណើនទំនុកចិត្តផ្នែកអាជីវកម្ម តម្រូវការក្នុងស្រុកបានកើនឡើង។ ស្ថានភាពនេះបានធ្វើឲ្យមានការប្រើប្រាស់សរុបច្រើន ដែលត្រូវបានសម្រួលដោយកំណើន ការប្រើប្រាស់ឥណទានលឿន ហើយធ្វើឲ្យមានការលូតលាស់ផ្នែកអាជីវកម្មលក់ដុំ និងលក់រាយ។ កំណើនទុនអចល័តដុលឆ្នាំ ២០១៤ កើនដល់ចំនួន ៩,១% បើធៀបនឹងឆ្នាំមុន ដែលជំរុញដោយសម្ភារៈដែលប្រើជាប់បានយូរ និងសំណង់។

**ទោះជាមានតម្រូវការក្នុងស្រុកច្រើនក្តី អតិផរណាបានថយចុះថែមទៀត បន្ទាប់ពីបានថយចុះយ៉ាងគំហុកក្នុងឆ្នាំ ២០១៤ ដែលបង្ហាញពីការថយចុះនៃតម្លៃអាហារ និងប្រេង។** នៅខែសីហា ឆ្នាំ ២០១៥ អតិផរណាប្រចាំឆ្នាំបានថយចុះមកត្រឹម ០,៨% ដោយអត្រានេះមាន ចំនួន ១,២ % នៅបំណាច់ឆ្នាំ ២០១៤ ដោយតម្លៃអាហារ និងប្រេងបានថយចុះ។

**នៅក្នុងស្ថានភាពនេះ ផ្នែកសំណង់ និងអចលនទ្រព្យបានក្លាយ ជាម៉ាស៊ីនជំរុញកំណើនសេដ្ឋកិច្ច ដែលស្វាហាប់បំផុត។** ការមានទំនុកចិត្តឡើងវិញរបស់អាជីវកម្ម និងអតិថិជន និងការរំពឹងទុកអំពីកាលានុវត្តភាពនៃសមាហរណកម្មតំបន់ ក្នុងសហគមន៍សេដ្ឋកិច្ចអាស៊ាន កំពុងជំរុញកំណើនយ៉ាងឆាប់រហ័សនៃផ្នែកសំណង់ និងអចលនទ្រព្យ។ ការនាំចូលសម្ភារសំណង់បានបន្តកើនឡើងយ៉ាងខ្លាំង ក្នុងអំឡុងឆមាសទីមួយក្នុងឆ្នាំ ២០១៥ ដោយអត្រាកំណើននៃការនាំចូលគ្រឿងសំណង់បានឡើងដល់ ៣៨,៩% ហើយអត្រាកំណើននៃការនាំចូលដែកមានចំនួន ៣២,៧% បើធៀបនឹងឆ្នាំមុន។

**ការបន្តកំណើនរូបិយវត្ថុទូទៅ ជាមួយនឹងការលូតលាស់យ៉ាងលឿននៃវិស័យធនាគារ និងហិរញ្ញវត្ថុបានសម្រួលដល់កំណើនសេដ្ឋកិច្ច។** ផ្អែកសំខាន់ទៅលើប្រាក់បញ្ញើបរទេស កំណើនរូបិយវត្ថុទូទៅ បានបន្តកើតមាន ដោយមានអត្រាកំណើនចំនួន ២០,៦% ត្រឹមខែ មិថុនា ឆ្នាំ ២០១៥ បើធៀបនឹងឆ្នាំមុន។ កំណើនប្រាក់បញ្ញើវិស័យឯកជន ក៏នៅតែមានភាពល្អប្រសើរដែរ ដោយមានអត្រាកំណើនចំនួន ២១,១% ធៀបនឹងឆ្នាំមុន ហើយកំណើននេះ បានជួយដល់កំណើនខ្ពស់នៃឥណទានវិស័យឯកជន ដែលមានចំនួន ២៨,១% នៅខែ មិថុនា ឆ្នាំ ២០១៥ បើធៀបនឹងឆ្នាំមុន។

**ចំពោះវិស័យក្រៅប្រទេសវិញ កំណើនតម្លៃប្រាក់ដុល្លាអាមេរិកនៅតែបន្តកើនឡើង ដែលធ្វើឲ្យប៉ះពាល់ដល់ការប្រកួតប្រជែង ដោយធ្វើឲ្យសន្ទុះកំណើននៃការនាំចេញសម្លៀកបំពាក់ និងវិស័យទេសចរណ៍ ថយចុះបន្តិច។** កំណើនតម្លៃប្រាក់ដុល្លាអាមេរិក ធៀបនឹងប្រាក់អឺរ៉ូ និងប្រាក់នៅក្នុងប្រទេសអាស៊ានផ្សេងទៀត ការលេចឡើងនៃអ្នកប្រកួតប្រជែង ដែលទទួលប្រាក់ឈ្នួលទាបផ្សេងទៀតក្នុងតំបន់ ដូចជា ប្រទេសភូមា និងភាពមិនប្រាកដប្រជាជុំវិញ ការចរចាប្រាក់ឈ្នួល កំពុងធ្វើឲ្យប៉ះពាល់ដល់ ការប្រកួតប្រជែងក្រៅប្រទេសរបស់កម្ពុជា។ ជាក់ស្តែង ក្នុងរយៈពេល ៦ខែ ក្នុងឆមាសទីមួយឆ្នាំ ២០១៥ កំណើនការនាំចេញសម្លៀកបំពាក់បានថយចុះបន្តិច ដោយអត្រាកំណើនប្រចាំឆ្នាំមានចំនួន ៧,៨% គិតជាតម្លៃ ហើយកំណើននេះ នៅឆ្នាំ ២០១៤ មានចំនួន ៩,២%។ នៅពេលជាមួយគ្នានេះដែរ វិស័យទេសចរណ៍នៅតែ ដំណើរការមិនបានពេញលេញ ដោយអត្រាកំណើន នៃចំនួនភ្ញៀវមកដល់ក្នុងអំឡុងឆមាស ទីមួយក្នុងឆ្នាំ ២០១៥ បានតែ ៤,៦% ប៉ុណ្ណោះ បើធៀបនឹងឆ្នាំមុន (ភ្ញៀវទេសចរចំនួន ២,៣ លាននាក់) ធៀបនឹង ៦,៩% ក្នុងឆ្នាំ ២០១៤។

**ការធ្លាក់ចុះតម្លៃប្រេង ជួយរឹតត្បិតកំណើននៃការនាំចូលក្នុងរយៈពេល ៦ខែ ដំបូងក្នុងឆ្នាំ ២០១៥ ដែលរួមចំណែកឲ្យមានភាពប្រសើរបន្តិច ចំពោះឱនភាពគណនីចរន្ត។** ការនាំចេញ និង ចំណូលពីភ្ញៀវទេសចរខ្សោយជាងមុន បានធ្វើឲ្យឱនភាពគណនីចរន្តធំជាងមុនដល់ ១០,៨ % នៃផសស ក្នុងឆ្នាំ ២០១៤។ ម្យ៉ាងវិញទៀត លំហូរនៃការវិនិយោគផ្ទាល់ពីបរទេស នៅតែមានភាពប្រសើរ ដែលផ្តល់ហិរញ្ញប្បទានភាគច្រើនដល់ ឱនភាពគណនីចរន្ត។

ការបន្តលំហូរនៃការវិនិយោគផ្ទាល់ពីបរទេស បានរួមចំណែក ឲ្យមានកំណើនប្រាក់បម្រុងអន្តរជាតិដុលដែលមានចំនួន ៥,២ ពាន់លានដុល្លាអាមេរិក ឬ ៤,១ខែនៃការនាំចេញ គិតត្រឹមពាក់កណ្តាល ឆ្នាំ ២០១៥។

**ភាពយឺតយ៉ាវក្នុងការដាំដុះ ដែលបណ្តាលមកពីការធ្លាក់ភ្លៀងមិនជាប់ជាប្រចាំ និងតម្លៃនាំចេញផលិតផលទាបជាងមុន បានបណ្តាលឲ្យមានការថយចុះក្នុងវិស័យកសិកម្ម។** គួរកត់សម្គាល់ថា ក្នុងអំឡុងពេលពីឆ្នាំ ២០០៤ ដល់ឆ្នាំ ២០១២ ផសស កសិកម្មកើនឡើងជាមធ្យមចំនួន ៥,៣% ក្នុងមួយឆ្នាំ ដែលស្ថិតក្នុងអត្រាកំណើនខ្ពស់ជាងគេបំផុតក្នុងពិភពលោក។ កំណើននេះត្រូវបានជំរុញមិនមែនតែដោយសារស្រូវទេ ប៉ុន្តែក៏ដោយសារ ពោត ដំឡូង អំពៅ និងបន្លែដែរ។ នៅពេលជាមួយគ្នានោះដែរ ក្នុងអំឡុងពេលមួយទសវត្សរ៍កន្លងមក វិស័យកសិកម្មបានជួបប្រទះការប្រែប្រួលផ្នែករចនាសម្ព័ន្ធយ៉ាងខ្លាំង ដោយចំណែកកសិកម្មនៃ ផសស និងកម្លាំងពលកម្មសរុបបានថយចុះ បើទោះជាមានកំណើនផ្ទៃដី និងផលិតភាពកម្លាំងពលកម្មក្តី។

**ចំពោះដំណើរការផ្នែកសារពើពន្ធវិញ ផ្នែកនេះនៅតែមានភាពរឹងមាំ ដោយសារតែកំណើនចំណូលខ្ពស់ និងការត្បិតត្បៀតចំណាយ ដែលរក្សាលំនឹងឱនភាពសារពើពន្ធរួម។** ក្នុងរយៈពេល ៧ខែដំបូងក្នុងឆ្នាំ ២០១៥ ចំណូលក្នុងស្រុក បន្តដំណើរការយ៉ាងល្អ ដោយមានកំណើនប្រចាំឆ្នាំប្រមាណ ១៨% ដោយសារតែមានការកែលម្អនៃរដ្ឋបាលចំណូល។ ការធ្វើវិភាជមានការកើនឡើងនាពេលថ្មីៗនេះ ហើយរំពឹងថានឹងឆ្លើយតបទៅនឹងគោលដៅថវិកា បន្ទាប់ពីការចាប់ផ្តើមយឺតដំបូងនៅក្នុងបរិបទនៃការផ្លាស់ប្តូរទៅកប្រព័ន្ធថវិកាកម្មវិធី។ អត្រាបំណុលនៅកម្ពុជានាពេលថ្មីៗនេះ ដែលបានកំណត់ក្នុងការវិភាគទៅលើនិរន្តភាពបំណុល របស់ធនាគារពិភពលោក និង មូលនិធិរូបិយវត្ថុអន្តរជាតិ (IMF) នៅតែមានកម្រិតទាបដដែល។

## *ស្ថានភាពនាពេលអនាគត*

**កំណើនត្រូវបានព្យាករណ៍ថា នឹងមានសន្ទុះថយចុះបន្តិចគឺ ៦,៩% ក្នុងឆ្នាំ ២០១៥។** តម្រូវការក្នុងស្រុកខ្ពស់ ដែលជំរុញដោយកំណើនវិស័យសំណង់ និងការធ្លាក់

ចុះតម្លៃប្រេង និងត្រូវបានសម្រួលដោយកំណើនខ្ពស់នៃឥណទានក្នុងស្រុក ហើយនឹងសង្ឃឹមថាប៉ះប៉ូវចំពោះការថយចុះបន្តិច នៃកំណើនការនាំចេញផ្នែកសម្លៀកបំពាក់ វិស័យទេសចរណ៍ និងកសិកម្ម។

ហានិភ័យមួយចំនួន ដែលអាចធ្វើឲ្យប៉ះពាល់ដល់កំណើនសេដ្ឋកិច្ចរឹងមាំដែលបានប៉ាន់ស្មាននេះ រួមមានលទ្ធភាពនៃការរំដើប រំជួលឡើងវិញនៃកម្លាំងពលកម្ម ការឡើងថ្លៃប្រាក់ដុល្លាអាមេរិកថែមទៀត ភាពយឺតយ៉ាវនៃការងើបឡើងនៃសេដ្ឋកិច្ចនៅអឺរ៉ុប និងការធ្លាក់ចុះសេដ្ឋកិច្ចនៅប្រទេសចិន។ ការធ្លាក់ចុះសេដ្ឋកិច្ចនៅប្រទេសចិន អាចធ្វើឲ្យកំណើនធ្លាក់ចុះសំខាន់ដោយសារចំនួនភ្ញៀវទេសចរពីប្រទេសចិន និងលំហូរនៃការវិនិយោគ ទោះបីជាការពឹងផ្អែករបស់កម្ពុជាទៅលើការនាំចេញទៅប្រទេសចិន មានកម្រិតទាបជាងមុន។ មានហានិភ័យមួយដែលថាគោលនយោបាយ "បង្កើន" អត្រាការប្រាក់របស់សហរដ្ឋអាមេរិក អាចធ្វើឲ្យមានប្រតិកម្មទីផ្សារភ្លាមៗ ដែលធ្វើឲ្យរូបិយប័ណ្ណធ្លាក់តម្លៃយ៉ាងខ្លាំង សញ្ញាប័ណ្ណ ឡើងខ្លាំង លំហូរទុនធ្លាក់ចុះខ្លាំង ហើយសន្ទនីយភាពរួមតូចចង្អៀត។ ទោះជាយ៉ាងណាក្នុងបរិបទនៃទីផ្សារទុនតូច ប្រទេសកម្ពុជាគួររួចផុតពីបញ្ហានៃការប្រែប្រួលផ្នែកហិរញ្ញវត្ថុ។ ប្រទេសកម្ពុជានៅតែរងការប៉ះពាល់ ពីការបាត់បង់ការប្រកួតប្រជែងដោយសារតែការឡើងថ្លៃប្រាក់ដុល្លាអាមេរិក ដែលធ្វើឲ្យកំណើនធ្លាក់ចុះ។

## *បញ្ហាប្រឈម និងអនុសាសន៍*

**មានតម្រូវការខ្លាំងក្នុងការបង្កើនភាពប្រកួតប្រជែងខាងក្រៅប្រទេស។** កម្ពុជាប្រហែលជាត្រូវពឹងផ្អែកលើការដោះស្រាយបញ្ហារាំងស្ទះ ដែលប៉ះពាល់ដល់កំណើនផលិតភាព និង ការកាត់បន្ថយការចំណាយក្នុងការនាំចេញ។ ការធ្វើឲ្យកម្លាំងពលកម្មមានការបណ្តុះបណ្តាលច្រើនជាងមុន និងមានជំនាញខ្ពស់ ពិតជានឹងជួយដល់បញ្ហានេះ។ ការកែលម្អ បរិយាកាសធុរៈកិច្ចនឹងជួយបង្កើនការប្រកួតប្រជែងតាមវិស័យផ្សេងៗ។ ជាចុងក្រោយ ជាការសំខាន់ត្រូវគាំទ្រដល់ការធ្វើពិពិធកម្មក្នុងវិស័យកម្មន្តសាល ដូចមានលើកឡើងនៅក្នុង គោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្ម ដែលទើបតែត្រូវបានផ្សព្វផ្សាយនាពេលថ្មីៗនេះ នៅខណៈពេលដែលត្រូវ ត្រៀមលក្ខណៈល្អក្នុងការចាប់ឱកាសពីទីផ្សារ និងមូលដ្ឋាន ផលិតកម្មតែមួយ ដែលជាទិសដៅនៃសហគមន៍សេដ្ឋកិច្ចអាស៊ាននោះ។ ដើម្បីពង្រឹងបរិយាកាសធុរៈកិច្ច បទពិសោធន៍អន្តរជាតិបង្ហាញថាត្រូវផ្តោតទៅចំណុចគន្លឹះមួយគឺ ក្របខណ្ឌច្បាប់ និងបទដ្ឋាន ដែលអាចព្យាករណ៍បាន និងផ្អែកទៅលើបទដ្ឋានអន្តរជាតិ។

**ដោយសារតែការវិនិយោគទុន ដែលផ្តល់ហិរញ្ញប្បទានពីខាងក្រៅ (ដៃគូអភិវឌ្ឍន៍) ធ្លាក់ចុះ ជាការសំខាន់ត្រូវជំរុញការ វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្នុងស្រុក។** ការប្រមូលចំណូលបានច្រើនជួយឲ្យអាចធ្វើការវិនិយោគដូច្នេះបាន។ ជាការចាំបាច់ត្រូវពង្រឹងបន្ថែមទៀតចំពោះច្បាប់ និងលិខិតបទដ្ឋានផ្សេងៗ ដែលគ្របដណ្តប់ទៅលើ ការគ្រប់គ្រងគម្រោងវិនិយោគទុនដែលមាននៅក្នុងកម្មវិធី កំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។ ការពង្រឹងបន្ថែមលើគុណភាព និងសមត្ថភាពស្ថាប័ន ដើម្បីគ្រប់គ្រងគម្រោងវិនិយោគសាធារណៈឲ្យបានប្រសើរ នឹងជួយពង្រឹង ប្រសិទ្ធភាពគោលនយោបាយសារពើពន្ធ។ បទពិសោធន៍អន្តរជាតិបានបង្ហាញពីសារៈសំខាន់ នៃការគោរពទៅគោការណ៍ធំៗបួនខាងក្រោម ដើម្បីបង្កើនការវិនិយោគសាធារណៈឲ្យបានជោគជ័យ៖ (១) ការសម្រេចនូវ "ប្រសិទ្ធផលនៃការបែងចែក" (២) ផ្អែកទៅលើ ក្របខណ្ឌម៉ាក្រូសារពើពន្ធល្អប្រសើរ (៣) ការមានប្រព័ន្ធគ្រប់គ្រងការវិនិយោគសាធារណៈល្អប្រសើរ និង (៤) មានសមត្ថភាពសមស្របដើម្បីស្រូបយកវិស័យសំណង់។

**ចាំបាច់ត្រូវពង្រឹងបន្ថែមទៅលើការគ្រប់គ្រង និងសម្របសម្រួល ដើម្បីធានាឲ្យមានស្ថិរភាពនៅក្នុងវិស័យធនាគារ និងសំណង់ ដែលកំពុងលូតលាស់យ៉ាងលឿន។** ជាការចាំបាច់ត្រូវបង្កើនសមត្ថភាពត្រួតពិនិត្យ

និងបង្កើតក្របខណ្ឌគ្រប់គ្រងវិបត្តិ ដោយមានការ គាំទ្រពីការអនុវត្តផ្នែកសវនកម្ម និងគណនេយ្យ និងការសម្របសម្រួលអន្តរក្រសួងបានល្អ។ ការយល់ដឹងឲ្យបានល្អអំពី "ច្រកបញ្ជូន" នៃវិបត្តិដែលអាចកើតមានមកក្នុងសេដ្ឋកិច្ចជាតិ និងទំនាក់ទំនងរវាងវិស័យហិរញ្ញវត្ថុ និង វិស័យផលិតកម្ម ជាពិសេសវិស័យសំណង់ និងអចលនទ្រព្យ នឹងជួយបង្កើនភាពរឹងមាំនៃសេដ្ឋកិច្ចក្នុងការទប់ទល់នឹងការប្រែប្រួលខាងក្រៅ និងចៀសវាងបញ្ហាពពុះនៃវិស័យសំណង់ និងអចលនទ្រព្យដែលអាចកើតមាន។ បទពិសោធន៍អន្តរជាតិបង្ហាញថា ត្រូវមានក្របខណ្ឌស្តង់ដាអប្បបរមាសម្រាប់ការអនុវត្តការត្រួតពិនិត្យធនាគារឲ្យបានល្អ ដែលអាចអនុវត្តជាទូទៅដែលត្រូវមាន (១) អំណាចត្រួតពិនិត្យដែលមានកំណត់យ៉ាងច្បាស់ (២) ការទទួលខុសត្រូវ និងគណនីយភាពក្នុងចំណោម អាជ្ញាធរត្រួតពិនិត្យ និង (៣) បទដ្ឋានប្រុងប្រយ័ត្នត្រឹមត្រូវ។ បុរេលក្ខខណ្ឌសម្រាប់ការត្រួតពិនិត្យធនាគារឲ្យមានប្រសិទ្ធភាពរួមមាន (១) ក្របខណ្ឌច្បាស់លាស់សម្រាប់ការបង្កើតគោល នយោបាយស្ថិរភាពហិរញ្ញវត្ថុ (២) ក្របខណ្ឌច្បាស់លាស់សម្រាប់ដោះស្រាយវិបត្តិ និង (៣) ប្រព័ន្ធការពារ (ឬបណ្តាញសុវត្ថិភាពសាធារណៈ) កម្រិតសមស្រប។

**ការពង្រឹងកំណើនវិស័យកសិកម្មឡើងវិញ និងការគាំទ្រការកែប្រែរចនាសម្ព័ន្ធបន្ថែមទៀតនៃ វិស័យកសិកម្មអាចសម្រេចទៅបាន ដោយសារមានគោលនយោបាយចំនួនបួន។** ទីមួយ គឺការរក្សាបរិយាកាសគោលនយោបាយកសិកម្ម ដែលសមស្របចំពោះវិស័យឯកជនដោយ ត្រូវផ្តោតបន្ថែមទៅលើការសម្រាលបន្ទុកផ្នែកបញ្ញត្តិចំពោះធាតុចូលនៅកសិដ្ឋាន។ ទីពីរ គឺការពង្រឹងនិរន្តរភាពបរិស្ថាននៃផលិតកម្ម កសិកម្ម។ ទីបី គឺការបង្កើនគុណភាពកម្មវិធីសាធារណៈផ្នែកកសិកម្ម និង (ទៅតាមលទ្ធភាពនៃថវិកាសរុបរបស់រដ្ឋាភិបាលកម្ពុជា) បង្កើនវិភាជថវិកាដល់កម្មវិធីដែលកាន់តែ មានប្រសិទ្ធភាព។ ទីបួន គឺការជួយអភិវឌ្ឍកសិអាជីវកម្ម និងឧស្សាហកម្មកែច្នៃកសិកម្ម។ ចំពោះព័ត៌មានលម្អិតបន្ថែម សូមមើលប្រធានបទពិសេស ស្តីពី "កសិកម្មកម្ពុជាក្នុងអន្តរកាលៈ កាលានុវត្តភាព និងហានិភ័យ"។

# និន្នាការរួមនៃសេដ្ឋកិច្ចកម្ពុជា

## កំណើន ផសស ខ្ពស់រយៈពេលយូរ...

ការរួមចំណែកចំពោះ ផសស ពិត (ជាភាគរយ)




p= ការព្យាករ

## ... បច្ចុប្បន្ននេះ ពឹងផ្អែកជាងមុនទៅលើកំណើនតម្រូវការក្នុងប្រទេស

កំណើននៃការប្រើប្រាស់ចុងក្រោយ និងការបង្កើតដើមទុនរួមជាមួយនឹងកំណើនឥណទានក្នុង ប្រទេស (ការប្រែប្រួលជាភាគរយធៀបនឹងឆ្នាំមុន តម្លៃបច្ចុប្បន្ន)




## ...ដោយសារការកើនឡើងនូវទំនុកចិត្តដែលជំរុញអោយវិស័យសំណង់រីកដុះដាលយ៉ាងឆាប់រហ័ស...

សំណង់មានភាពសកម្មបំផុត។ ការរួមចំណែកចំពោះកំណើនពិតប្រចាំឆ្នាំ (ជាភាគរយ)




## ...ប៉ះប៉ូវចំពោះកំណើនការនាំចេញ និងទេសចរណ៍ដែលធ្លាក់ចុះបន្តិច...

សម្លៀកបំពាក់ ទេសចរណ៍ និងកសិកម្ម មានសន្ទុះកំណើនថយចុះ។ ការរួមចំណែកចំពោះកំណើនពិត (ជាភាគរយ)




## ...នៅពេលដែលការវិនិយោគផ្ទាល់ពីបរទេសដែលមានភាពល្អប្រសើរជួយផ្តល់ហិរញ្ញប្បទានចំពោះគម្លាតវិស័យក្រៅប្រទេស...

ការវិនិយោគផ្ទាល់ពីបរទេសជួយផ្តល់ហិរញ្ញប្បទានចំពោះឱនភាពគណនីចរន្ត។ តុល្យភាពពាណិជ្ជកម្ម តុល្យភាពគណនីចរន្ត និងការវិនិយោគផ្ទាល់ពីបរទេស (ជាភាគរយនៃ ផសស)




p= ការព្យាករ

## ...ហើយកំណើននៃការប្រមូលចំណូល ធ្វើឲ្យមានភាពរឹងមាំផ្នែកសារពើពន្ធ

ឱនភាពសារពើពន្ធរបស់រដ្ឋាភិបាលជាទូទៅមានការថយចុះជាបន្តិចម្តងៗ (ភាគរយនៃ ផសស)




b = ថវិកា; p = ការព្យាករ

# ខ. វឌ្ឍនភាពផ្នែកសេដ្ឋកិច្ច នាពេលថ្មីៗនេះ

## ទិដ្ឋភាពទូទៅ

**កំណើន ផសស ពឹងផ្អែកលើតម្រូវការក្នុងប្រទេស។** ការទទួលបានទំនុកចិត្តឡើងវិញពីពាណិជ្ជករ និងអ្នកប្រើប្រាស់ បានជំរុញឲ្យមានតម្រូវការក្នុងស្រុក។ ហេតុដូច្នេះការប្រើប្រាស់ ដែលត្រូវបានសម្រួលដោយកំណើនយ៉ាងលឿននៃឥណទានក្នុងស្រុកនោះ បានកើន ឡើងយ៉ាងខ្លាំង ដែលបានបង្កើនការលូតលាស់សេដ្ឋកិច្ច។ ក្នុងបរិបទថ្លៃប្រេងទាប និងការ កើនឡើងនៃទំនុកចិត្ត ដែលជួយដល់ការលូតលាស់យ៉ាងលឿននៃវិស័យសំណង់ និង អចលនទ្រព្យនោះ តម្រូវការក្នុងស្រុកបន្តកើនឡើង។ ទិន្នន័យចុងក្រោយដែលមានបង្ហាញថា ការប្រើប្រាស់បានកើនឡើងក្នុងអត្រាល្អប្រសើរ គឺ ៤,៣ (ក្នុងអត្រាថេរ) ក្នុងឆ្នាំ២០១៤ ដោយសារតែតម្រូវការក្នុងស្រុក (តារាង ១)។ កំណើននៃមូលធនដុល មានកម្រិតខ្ពស់ក្នុងកម្រិត ៩,១ ភាគរយ (ក្នុងអត្រាថេរ) ក្នុងឆ្នាំ២០១៤ ដែលជំរុញដោយសម្ភារៈដែលប្រើជាប់បានយូរ និងសំណង់។

តារាង ១ ការបន្តកំណើននៃការចំណាយទៅលើការប្រើប្រាស់ និងមូលធនដុល (អត្រាកំណើន ជាភាគរយ ក្នុងតម្លៃឆ្នាំ២០០០ថេរ)

| | 2011 | 2012 | 2013 | 2014 |
|---|---|---|---|---|
| **ការប្រើប្រាស់ចុងក្រោយ** | 10.2 | 4.7 | 5.7 | 4.3 |
| គ្រួសារ | 10.5 | 4.6 | 5.8 | 4.5 |
| រដ្ឋាភិបាល | 7.8 | 5.7 | 5.2 | 2.4 |
| **ការបង្កើតទុនដុល** | 10.8 | 17.4 | 15.3 | 9.1 |
| សម្ភារប្រើជាប់បានយូរ | 7.9 | 15.7 | 12.9 | 11.9 |
| សំណង់ | 12.8 | 18.6 | 16.9 | 7.5 |

ប្រភព៖ អាជ្ញាធរ

**ការកើនឡើងនៃការប្រើប្រាស់ និងការវិនិយោគ ដែលត្រូវបានជំរុញដោយតម្រូវការក្នុងស្រុក ដែលកំណើនឥណទានក្នុងកម្រិតខ្ពស់ ប៉ះប៉ូវចំពោះការថយចុះនៃសន្ទុះកំណើននៃការនាំចេញ ជាមួយនឹងការថយចុះល្បឿនកំណើនក្នុង វិស័យកាត់ដេរ ទេសចរណ៍ និងកសិកម្ម។** ក្រៅពីវិស័យសំណង់ និងអចលនទ្រព្យ ដែលនៅតែមានភាពរឹងមាំ (តារាង២) ការនាំចេញសម្លៀកបំពាក់ ដែលមានចំនួនស្មើរតែបីភាគបួននៃការនាំចេញទំនិញសរុបនោះ បានបន្ថយល្បឿនបន្តិច។ វិស័យទេសចរណ៍ក៏បានបន្ថយល្បឿនបន្តិចផងដែរ ចំណែកឯកំណើន កសិកម្មនៅតែមានភាពទន់ខ្សោយ។

**តារាង ២៖ វិស័យសំណង់ និងអចនទ្រព្យ រួមចំណែកច្រើនជាងគេ ចំនួន ២ ភាគរយ ក្នុងឆ្នាំ ២០១៤។** ការរួមចំណែកចំពោះកំណើន ផសស ពិត ប្រចាំឆ្នាំ (គិតជាភាគរយ)

| វិស័យចូលរួមចំណែកសំខាន់ៗ | 2011 | 2012 | 2013 | 2014 |
|---|---|---|---|---|
| ដំណាំ | 0.6 | 0.7 | 0.1 | 0.1 |
| សម្លៀកបំពាក់ និងស្បែកជើង | 3.1 | 1.1 | 1.8 | 1.2 |
| **សំណង់ និងអចលនទ្រព្យ** | **0.6** | **1.6** | **1.3** | **2.0** |
| ពាណិជ្ជកម្ម | 0.4 | 0.5 | 0.7 | 0.8 |
| សណ្ឋាគារ និងភោជនីយដ្ឋាន | 0.3 | 0.6 | 0.7 | 0.4 |

ប្រភព៖ អាជ្ញាធរ

ដូចបង្ហាញនៅក្នុងតារាង ២ ខាងលើ ការរួមចំណែកនៃដំណាំចំពោះកំណើន ផសស បានធ្លាក់ចុះយ៉ាងគួរឲ្យកត់សម្គាល់ក្នុងឆ្នាំ ២០១៣ នៅពេលដែលកំណើនវិស័យទេសចរណ៍ បានបន្ថយល្បឿនបន្តិច ក្នុងឆ្នាំ២០១៤ ដូចដែលបង្ហាញក្នុងផ្នែកសណ្ឋាគារ និងភោជនីយដ្ឋាន។

**ជាលទ្ធផល កំណើនត្រូវបានព្យាករណ៍ថានឹងថយចុះបន្តិចមកត្រឹម ៦ ៩,ភាគរយក្នុងឆ្នាំ ២០១៥ (រូប១)។**

**រូប ១៖ ការរួមចំណែករបស់កសិកម្មចំពោះកំណើនពិតបានថយចុះ**
ការរួមចំណែកចំពោះកំណើនពិត ផសស ប្រចាំឆ្នាំ (ជាភាគរយ)




ប្រភព៖ អាជ្ញាធរ និងការប៉ាន់ស្មានរបស់បុគ្គលិកធនាគារ

**ទោះជាយ៉ាងណា ហានិភ័យមួយចំនួនដែលអាចធ្វើឲ្យប៉ះពាល់ដល់កំណើនសេដ្ឋកិច្ចរឹងមាំ ដែលបានប៉ាន់ស្មាន** រួមមាន ការរំជើបរំជួលរបស់កម្លាំង ពលកម្មសាជាថ្មី ដែលអាចកើតឡើងនាពេលខាងមុខ ការបន្តឡើងថ្លៃនៃប្រាក់ដុល្លាអាមេរិក ភាពយឺតយ៉ាវនៃការងើបឡើងវិញនៃសេដ្ឋកិច្ចនៅអឺរ៉ុប និងការធ្លាក់ចុះនៃសេដ្ឋកិច្ចរបស់ប្រទេសចិន។ ការធ្លាក់ចុះនៃសេដ្ឋកិច្ចរបស់ប្រទេសចិន អាចប៉ះពាល់ដល់ក្ដីសង្ឃឹមថានឹង មានកំណើនដោយសារតែអាចមានការថយចុះនៃការមកដល់របស់ភ្ញៀវទេសចរ និងលំហូរវិនិយោគ ខណៈដែលការពឹងផ្អែក លើការនាំចេញមានកម្រិតទាប។ មានហានិភ័យដែលថា គោលនយោបាយ "បង្កើន" អត្រាការប្រាក់របស់សហរដ្ឋអាមេរិក អាចនាំឲ្យមានប្រតិកម្មទីផ្សារភ្លាមៗ ដែលធ្វើឲ្យរូបិយប័ណ្ណធ្លាក់ថ្លៃខ្លាំង សញ្ញាប័ណ្ណឡើងខ្ពស់ លំហូរទុនធ្លាក់ចុះខ្លាំង ហើយ សន្ទនីយភាពរួមតូចចង្អៀត។ ប្រទេសដែលមានការប្រឈមខ្ពស់បំផុតនោះគឺប្រទេសដែល ពឹងផ្អែកលើលំហូរផលបត្រ និងកម្ចីរយៈពេលខ្លី ដើម្បី ផ្ដល់ហិរញ្ញប្បទាន ដល់ឱនភាពគណនី ចរន្ត ឬការដោះបំណុល ដូចជា ករណីប្រទេសឥណ្ឌូនេស៊ី ដែលមាន បំណុលខាងក្រៅច្រើន ដូចជាប្រទេសម៉ាឡេស៊ី និងម៉ុងហ្គូលី មានចំណែករូបិយប័ណ្ណកាន់កាប់នៅក្រៅប្រទេស ដូចជាប្រទេសម៉ាឡេស៊ី និងឥណ្ឌូនេស៊ី ឬមានបំណុល លក្ខណៈគ្រួសារច្រើន ដូចជា ប្រទេសម៉ាឡេស៊ី និងប្រទេសថៃ[1]។ ទោះជាយ៉ាងណាក៏ដោយ ក្នុងបរិបទនៃទីផ្សារមូលធនតូច ប្រទេសកម្ពុជាគួរគេចផុតពីការប្រែប្រួលផ្នែកហិរញ្ញវត្ថុ ទោះបីជាប្រទេសនេះនឹងនៅតែទទួលរងបញ្ហាពីការឡើងថ្លៃប្រាក់ដុល្លាអាមេរិកក៏ដោយ។ ក្រោយវិបត្តិហិរញ្ញវត្ថុសាកលឆ្នាំ ២០០៨ កំណើនមានភាពប្រែប្រួលជាងមុន ប៉ុន្តែទាបជាងកំណើនមុនមានវិបត្តិ។

**កំណើនក្នុងប្រទេសដែលមានសេដ្ឋកិច្ចតូចៗ ក្នុងអាស៊ាននៅតែជាទូទៅមានកម្រិតខ្ពស់** (រូប ២)។ បើទោះជាកំណើនជាទូទៅក្នុងតំបន់អាស៊ីបូព៌ា និងប៉ាស៊ីហ្វិក ត្រូវបានរំពឹងថា នឹងថយចុះ បន្តិចពី៦,៨ភាគរយ ក្នុងឆ្នាំ ២០១៤ មកត្រឹម៦,៥ភាគរយ ក្នុងឆ្នាំ២០១៥ និង ៦,៣ ភាគរយនៅចន្លោះឆ្នាំ ២០១៦-១៧ ដែលបញ្ជាំងអំពីការថយចុះសន្ទុះកំណើនតិចតួចនៅ ប្រទេសចិន[2]។

**រូប ២៖ កំណើនរឹងមាំត្រូវបានព្យាករណ៍ថានឹងបន្តមាននៅក្នុងប្រទេសនានាជាសមាជិកអាស៊ានដែល មានសេដ្ឋកិច្ចតូច។** កំណើនពិត ផសស




ប្រភព៖ បន្តអនុវត្តន៍ ៖បច្ចុប្បន្នភាពសេដ្ឋកិច្ចអាស៊ីបូព៌ា និងប៉ាស៊ីហ្វិក ខែតុលា ឆ្នាំ២០១៥ ធសស

**ដូចប្រទេសផ្សេងៗទៀតក្នុងតំបន់ដែរ កម្ពុជាពឹងផ្អែកលើទេសចរណ៍ និងការវិនិយោគផ្ទាល់ពី ប្រទេសចិន** ដែលមានសារៈសំខាន់ចំពោះកំណើន ការងារ និងរូបិយប័ណ្ណបរទេស (រូប ៣ និង ៤)។

**រូប ៣៖ កម្ពុជាពឹងផ្អែកទៅលើទេសចរណ៍ចិន ដូចប្រទេសជាច្រើនក្នុងតំបន់ដែរ។** លំហូរទេសចរពីប្រទេសចិន (២០១៣ ជាភាគរយ)




ប្រភព៖ បន្តអនុវត្តន៍ ៖បច្ចុប្បន្នភាពសេដ្ឋកិច្ចអាស៊ីបូព៌ា និងប៉ាស៊ីហ្វិក ខែតុលា ឆ្នាំ២០១៥ របស់ធនាគារពិភពលោក

[1] បន្តអនុវត្តន៍៖ បច្ចុប្បន្នភាពសេដ្ឋកិច្ចអាស៊ីបូព៌ា និងប៉ាស៊ីហ្វិក ខែតុលា ឆ្នាំ ២០១៥ ធនាគារពិភពលោក

[2] បន្តអនុវត្តន៍៖ បច្ចុប្បន្នភាពសេដ្ឋកិច្ចអាស៊ីបូព៌ា និងប៉ាស៊ីហ្វិក ខែតុលា ឆ្នាំ ២០១៥ ធនាគារពិភពលោក

**រូប ៩៖ កម្ពុជា ម៉ុងហ្គូលី និងឡាវ ស្ថិតក្នុងចំណោមប្រទេសដែលទទួលការវិនិយោគ ផ្ទាល់ពីបរទេសពីប្រទេសចិនច្រើនជាងគេបង្អស់។** ដូច្នេះ ប្រទេសទាំងនេះងាយរងការ ប៉ះពាល់ដោយសារតែការប្រែប្រួល (គិតជាភាគរយនៃ ផសស)




ប្រភព៖ បន្តអនុវត្តន៍ ៖បច្ចុប្បន្នភាពសេដ្ឋកិច្ចអាស៊ីបូព៌ា និងប៉ាស៊ីហ្វិក ខែតុលា ឆ្នាំ២០១៥ របស់ធនាគារពិភពលោក

## វិស័យផលិតកម្ម

### ក) វិស័យសំណង់ និងអចលនទ្រព្យ



ការលូតលាស់នៃវិស័យសំណង់បន្តគាំទ្រដល់កំណើន។

វិស័យសំណង់ នៅតែជាម៉ាស៊ីនជំរុញកំណើនយ៉ាងសកម្មនៅក្នុងអំឡុងឆមាសទីមួយ ក្នុងឆ្នាំ ២០១៥។ វិស័យសំណង់បន្តរីកលូតលាស់ សំខាន់ដោយសារតែការទទួលបានទំនុកចិត្ត ឡើងវិញពីធុរៈកិច្ច និងអតិថិជន និងការរំពឹងថានឹងមានឱកាសនានា ដែលកើតចេញពីការធ្វើ សមាហរណកម្មតំបន់នៃសហគមន៍សេដ្ឋកិច្ចអាស៊ាន[3]។ សកម្មភាពសំណង់ ដែលភាគច្រើន ត្រូវបានផ្តល់ហិរញ្ញប្បទាន ដោយការវិនិយោគផ្ទាល់ពីបរទេស ផ្តោតជាពិសេសលើការសង់ អាគារពាណិជ្ជកម្ម និងអាគារស្នាក់នៅខ្ពស់ៗទំនើប ដែលមានទីតាំងនៅក្នុងរាជធានីភ្នំពេញ នៅតែមានភាពរឹងមាំដដែល។ កំណើននេះត្រូវបានបង្ហាញតាមរយៈ ការកើនឡើងយ៉ាងរហ័សនៃការនាំចូលសម្ភារៈសំណង់ រួមទាំងស៊ីមង់ត៍ និងផលិតផលដែក (តារាង៣)។ ទោះជាយ៉ាងណាក៏ដោយ តម្លៃនៃគម្រោងសាងសង់ ដែលត្រូវបានអនុម័តក្នុងអំឡុងឆមាសទីមួយក្នុងឆ្នាំ ២០១៥ បានថយចុះបន្តិច។

**តារាង ៣៖ ការនាំចូលសម្ភារៈសំណង់កំពុងកើនឡើងដោយសារតែការបន្តកំណើនយ៉ាងរហ័យនៃការសាងសង់**

| មុខទំនិញនាំចូល | មករា-មិថុនា២០១៤ | | មករា-មិថុនា២០១៥ | |
|---|---|---|---|---|
| | បរិមាណ (តោន) | ការប្រែប្រួលប្រចាំឆ្នាំ % | បរិមាណ (តោន) | ការប្រែប្រួលប្រចាំឆ្នាំ % |
| សម្ភារៈសំណង់ | 220,929 | 41.0 | 306,855 | 38.9 |
| ស៊ីម៉ង់ត៍ | 751,813 | 72.3 | 814,884 | 8.4 |
| ដែក | 77,882 | 28.2 | 103,339 | 32.7 |

ប្រភព៖ អាជ្ញាធរ

3 យោងតាមការប្រកាសស្តីពីផែនការរបស់សហគមន៍សេដ្ឋកិច្ចអាស៊ានប្រទេសជាសមាជិករបស់អាស៊ាន ទាំងអស់ត្រូវគោរពតាម និងអនុវត្តសហគមន៍សេដ្ឋកិច្ចអាស៊ាននៅចុងឆ្នាំ២០១៥។ សហគមន៍ សេដ្ឋកិច្ចអាស៊ាននឹងជាគោលដៅនៃសមាហរណកម្មសេដ្ឋកិច្ចនៅចុងឆ្នាំ ២០១៥ ដែលចង់បាន៖ (i) មូលដ្ឋានផលិតកម្ម និងទីផ្សារតែមួយ (ii) តំបន់សេដ្ឋកិច្ចដែលមានការប្រកួតប្រជែងខ្ពស់ (iii) តំបន់ អភិវឌ្ឍសេដ្ឋកិច្ចដោយសមធម៌ និង (iv) តំបន់ដែលបានធ្វើសមាហរណកម្មយ៉ាងពេញលេញ ទៅក្នុងសេដ្ឋកិច្ចពិភពលោក (សូមមើលប្រអប់ ២ សម្រាប់ព័ត៌មានលម្អិតអំពីសហគមន៍ សេដ្ឋកិច្ចអាស៊ាន)។ ជាមួយនឹងគម្រោងលុបបំបាត់ពន្ធនាំចូលខាងក្រោម៖ (i) លុបបំបាត់ពន្ធនាំចូល រាល់ផលិតផលទាំងអស់លើកលែងតែទំនិញអនុវត្តបន្តិចម្តងៗនៅក្នុងបញ្ជីទំនិញប៉ះពាល់ និង ទំនិញប៉ះពាល់ខ្លាំងក្នុងឆ្នាំ ២០១០ សម្រាប់អាស៊ាន-6 និង ឆ្នាំ២០១៥ ដោយមានការបត់បែនមួយចំនួនសម្រាប់ទំនិញប៉ះពាល់ក្នុងឆ្នាំ ២០១៨ សម្រាប់ប្រទេសកម្ពុជា ឡាវ មីយ៉ាន់ម៉ា និង វៀតណាម អនុលោមតាមបទប្បញ្ញត្តិនៃពិធីសារកែប្រែកិច្ចព្រមព្រៀងគម្រោងអនុគ្រោះពន្ធពិសេសដែលមានប្រសិទ្ធភាពរួម (CEPT) សម្រាប់ការលុបបំបាត់ពន្ធនាំចូល និង (ii) បញ្ចប់ការអនុវត្តបន្តិចម្តងៗនៃទំនិញដែលនៅសេសសល់នៅក្នុងបញ្ជីទំនិញប៉ះពាល់ នៅក្នុង គម្រោង CEPT និងកាត់បន្ថយពន្ធលើទំនិញទាំងនេះមកត្រឹម 0-៥% នៅថ្ងៃទី ១ ខែមករា ឆ្នាំ២០១០ សម្រាប់អាស៊ាន-6 នៅថ្ងៃទី១ ខែមករា ឆ្នាំ២០១៣ សម្រាប់ប្រទេសវៀតណាម នៅថ្ងៃទី១ ខែមករា ឆ្នាំ២០១៥ សម្រាប់ប្រទេសឡាវ និងមីយ៉ាន់ម៉ា និងនៅថ្ងៃទី១ ខែមករា ឆ្នាំ២០១៧ សម្រាប់ប្រទេសកម្ពុជា អនុលោមតាមបទប្បញ្ញត្តិនៃពិធីសារស្តីពីកិច្ចព្រមព្រៀងពិសេសសម្រាប់ទំនិញប៉ះពាល់ និងទំនិញប៉ះពាល់ខ្លាំង។

ក្នុងឆ្នាំ ២០១៤ ក្នុងចំណោម ៧,១ ភាគរយនៃកំណើនពិត វិស័យសំណង់ និងវិស័យអចលន ទ្រព្យរួមចំណែកច្រើនជាងគេបំផុត គឺ ២ ភាគរយ (តារាង ២)។

**បទពិសោធន៍អន្តរជាតិ**បង្ហាញថា វិស័យសំណង់ដើរតួនាទីពិសេសមួយនៅក្នុងកំណើន សេដ្ឋកិច្ច និងជានិច្ចជាកាល ជាប៉ារ៉ាម៉ែត្រសំខាន់មួយនៃស្ថានភាពសេដ្ឋកិច្ច។ វិស័យ សំណង់បង្កើនហេដ្ឋារចនាសម្ព័ន្ធរូបវន្តរបស់ប្រទេស ដែលជាកត្តាសំខាន់សម្រាប់កំណើនរយៈពេលយូរ។ ដំណើរការវិស័យសំណង់ប៉ះពាល់ដល់ និងទទួលរងឥទ្ធិពលពីស្ថានភាព សេដ្ឋកិច្ចទូទៅដែរ។ បើទោះបីជា ជាទូទៅ មានទំហំតូច បើប្រៀបទៅនឹងវិស័យផ្សេងៗទៀត ក៏ដោយ ក៏សកម្មភាពរបស់វិស័យសំណង់មានផលប៉ះពាល់យ៉ាងខ្លាំងលើផ្នែកទិន្នផល និង ចំនួនការងារក្នុងសេដ្ឋកិច្ចទាំងមូល ដោយសារតែទំនាក់ទំនងទៅវិញទៅមកយ៉ាងជិតស្និទ្ធ ជាមួយនឹងវិស័យផ្សេងៗទៀត[4]។

**ហានិភ័យពាក់ព័ន្ធនឹងការលូតលាស់យ៉ាងរហ័ស នៃវិស័យសំណង់ និងអចលនទ្រព្យ កំពុងកើនឡើង** ដោយសារតែវាធ្វើឲ្យថ្លៃផ្ទះ និងដីកើនឡើងពេញទូទាំងទីក្រុងភ្នំពេញ និងតំបន់ទីប្រជុំជនផ្សេងទៀត ក៏ដូចជាកំណើនឥណទានយ៉ាងឆាប់រហ័យ ដែលចុងក្រោយ អាចនាំឲ្យមានការលេចឡើងនូវបញ្ហាពពុះដែលជំរុញ ដោយការឡើងថ្លៃដោយប្រថុយប្រថាន។ ទិន្នន័យគណនីជាតិបង្ហាញថា កំណើនវិស័យអចលនទ្រព្យ (និងពាណិជ្ជកម្ម) (ក្នុងតម្លៃ បច្ចុប្បន្ន) បានឡើងដល់ចំណុចខ្ពស់បំផុត ចំនួន ២៥,៩ ភាគរយ ក្នុងឆ្នាំ ២០១៤ ធៀបទៅនឹង ៩,៩ ភាគរយក្នុងឆ្នាំ ២០១៣។ **របបពាណិជ្ជកម្ម និងវិនិយោគបើកទូលាយរបស់ប្រទេសកម្ពុជាបច្ចុប្បន្ន កំពុងតែទាក់ទាញធុរកិច្ច និងការវិនិយោគ ដែលកំពុងតែមើលឃើញឱកាសដែលកើតចេញពីសមាហរណកម្មតំបន់ ដែលកំណត់នៅក្នុងសហគមន៍សេដ្ឋកិច្ចអាស៊ាន។** ដូចបានពិភាក្សាខាងលើ កត្តានេះបាន នាំឲ្យមានការរីកចម្រើនខ្លាំងក្នុងការអភិវឌ្ឍផ្នែកពាណិជ្ជកម្ម និងលំនៅដ្ឋានទំនើបៗនៅ ទីក្រុងភ្នំពេញ។ ក្នុងខែធ្នូ ឆ្នាំ២០១៥ សហគមន៍សេដ្ឋកិច្ចអាស៊ាននឹងត្រូវបានបង្កើតឡើងជាផ្លូវការ។ ដំណើរការសមាហរណកម្មតំបន់ ដែលពាក់ព័ន្ធបានផ្តល់ជាប្រយោជន៍សំខាន់ៗជាច្រើនរួច មកហើយ ៖ ពន្ធអាស៊ានត្រូវបានកាត់បន្ថយយ៉ាងខ្លាំង ពាណិជ្ជកម្មតំបន់ត្រូវបានសម្រួល ពាណិជ្ជកម្មផ្នែកសេវាកម្មត្រូវបានធ្វើសេរីភាវូបនីយកម្ម ហើយការវិនិយោគផ្ទាល់ពីបរទេស ត្រូវបានជំរុញ។ មានផលចំណេញជាច្រើនដែលអាចមានចេញពីការអនុវត្តយ៉ាងពេញលេញ និងការពង្រីកកម្មវិធីសមាហរណកម្ម នៃសហគមន៍សេដ្ឋកិច្ចអាស៊ាន[5] (សូមមើលប្រអប់ ២ សម្រាប់ព័ត៌មានលម្អិតស្តីពី សហគមន៍សេដ្ឋកិច្ចអាស៊ាន ឆ្នាំ ២០១៥)។

## ខ) វិស័យកាត់ដេរ



ការកែលម្អផលិតភាព និងការពង្រឹងការប្រកួតប្រជែង អាចចាប់ផ្តើមពីនិយោជិតដែលមកធ្វើការទាន់ពេលវេលា មានការទទួលខុសត្រូវ ស្មោះត្រង់ និងឧស្សាហ៍ព្យាយាម។

**ការនាំចេញសម្លៀកបំពាក់ ដែលជាកម្លាំងជំរុញដ៏សំខាន់មួយនៃកំណើនសេដ្ឋកិច្ចបានថយចុះបន្តិច** មកត្រឹម កំណើន ៧,៨ ភាគរយ (ឬ ២,៨ ពាន់លានដុល្លាអាមេរិក) គិតជាតម្លៃ និង ៧,៩ ភាគរយ គិតជាបរិមាណ

---

[4] កត្តាជំរុញនៅពីក្រោយការលូតលាស់ និងការផ្ទុះក្នុងវិស័យសំណង់នៅអឺរ៉ុប *Yan Sun, Pritha Mitra, និង Alejandro Sunone, ឯកសារស្រាវជ្រាវរបស់ IMF* WP/13/181

[5] បន្តអនុវត្តន៍៖ បច្ចុប្បន្នភាពសេដ្ឋកិច្ចអាស៊ីបូព៌ា និងប៉ាស៊ីហ្វិក ខែតុលា ឆ្នាំ ២០១៥ ធនាគារពិភពលោក

ក្នុងឆមាសទីមួយក្នុងឆ្នាំ ២០១៥ ដែលបានថយចុះពី ៩,២ ភាគរយគិតជាតម្លៃ និង ១១,២ ភាគរយគិតជាបរិមាណ ក្នុងឆ្នាំ ២០១៤ (រូប ៥)។ ដូចដែលបង្ហាញក្នុងតារាង ១ ក្នុងកំណើនពិត ៧,១ ភាគរយ នៅឆ្នាំ ២០១៤ វិស័យកាត់ដេរសម្លៀកបំពាក់ និងស្បែកជើង គឺជាវិស័យដែលរួមចំណែកច្រើនជាងគេបង្អស់ទីពីរ ដែលមានចំនួន ១,២ ភាគរយ បន្ទាប់ពីវិស័យសំណង់ និងអចលនទ្រព្យ។

**រូប ៥ ៖ កំណើនការនាំចេញសម្លៀកបំពាក់បានថយចុះ បើធៀបនឹងឆ្នាំមុន**
(គិតពីដើមឆ្នាំរហូតដល់ពេលនេះ % ប្រែប្រួលធៀបនឹងឆ្នាំមុន)




**តម្លៃផលិតផលសម្លៀកបំពាក់ដែលនាំចេញ មានចំនួន ៧២,៥ ភាគរយនៃការនាំចេញ ទំនិញសរុប បានបន្តថយចុះ។** នេះគឺដោយសារតែការប្រកួតប្រជែងខ្លាំងជាងមុននៅក្នុងបរិបទ នៃការឡើងថ្លៃប្រាក់ដុល្លាអាមេរិក។ ជាពិសេស តម្លៃនៃការនាំចេញសម្លៀកបំពាក់ទៅសហគមន៍អឺរ៉ុប ដែលជាទីផ្សារនាំចេញដ៏ធំបំផុតរបស់កម្ពុជា ដែលទិញផលិតផលកាត់ដេររបស់កម្ពុជា ៤០ ភាគរយ (រូប ៦) បានថយចុះចំនួន ១៥,៧ ភាគរយ មកត្រឹម ៣៥,៤ ដុល្លាអាមេរិក/ឡូ នៅពាក់កណ្តាលឆ្នាំ ២០១៥ ពី ៤២,០ ដុល្លាអាមេរិក/ឡូ នៅបំណាច់ឆ្នាំ ២០១១ (តារាង ៤)។ ការឡើងថ្លៃប្រាក់ដុល្លាអាមេរិក និងវត្តមានគូប្រកួតប្រជែង ក្នុងតំបន់ដែលមានប្រាក់ឈ្នួលទាប ដូចជា មីយ៉ាន់ម៉ា និងភាពមិនប្រាកដប្រជានៃការចរចាប្រាក់ឈ្នួលអប្បបរមា បន្តដាក់សម្ពាធលើវិស័យកាត់ដេរ។

**រូប ៦ ៖ តម្លៃផលិតផលសម្លៀកបំពាក់ដែលនាំចេញទៅទីផ្សារសហគមន៍អឺរ៉ុបបានថយចុះយ៉ាងលឿន។** (ដុល្លា អាមេរិក/ឡូ)




ប្រភព ៖ អាជ្ញាធរ និងការប៉ាន់ស្មានរបស់បុគ្គលិកធនាគារពិភពលោក

**តារាង ៤ ៖ តម្លៃផលិតផលសម្លៀកបំពាក់ដែលនាំចេញបានថយចុះនៅទីផ្សារនាំចេញសំខាន់ៗ** ដោយសារកំណើនការប្រកួតប្រជែងនៃតម្លៃ។ តម្លៃនាំចេញផលិតផលកាត់ដេរ (ដុល្លាអាមេរិក/ឡូ)

| | សហរដ្ឋអាមេរិក | សហភាពអឺរ៉ុប | ជប៉ុន |
|---|---|---|---|
| 2011 | 29.7 | 42.0 | 66.7 |
| 2012 | 29.0 | 43.7 | 59.9 |
| 2013 | 28.0 | 41.9 | 68.8 |
| 2014 | 26.8 | 38.0 | 65.5 |
| 2015 | 26.3 | 35.4 | 60.1 |

ប្រភព ៖ ការគណនារបស់បុគ្គលិកធនាគារពិភពលោកដោយប្រើប្រាស់ទិន្នន័យពីអាជ្ញាធរ

បច្ចុប្បន្ននេះ កម្ពុជាទទួលបានអត្ថប្រយោជន៍ពីប្រព័ន្ធអនុគ្រោះ "អ្វីៗគ្រប់យ៉ាងលើកលែងតែអាវុធ" របស់អឺរ៉ុបសម្រាប់ការនាំចេញសម្លៀកបំពាក់[6]។ យ៉ាងណាក៏ដោយ គេរំពឹងថានឹងមានការប្រកួតប្រជែងកាន់តែខ្លាំងនៅពេលដែលការលើកលែងពន្ធលើផលិតផលសម្លៀកបំពាក់ ចូលជាធរមានក្រោមកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីរវាងសហគមន៍អឺរ៉ុប និងវៀតណាម[7]។ ក្នុងបរិបទ

[6] ប្រទេស ១០ ដែលមានការអភិវឌ្ឍតិចជាងគេនៅអាស៊ី រួមមាន អាហ្វហ្គានីស្ថាន បង់ក្លាដេស ប៊ុយតង់ ឡាវ ម៉ាល់ឌីវ កម្ពុជា មីយ៉ាន់ម៉ា នេប៉ាល់ ទីម័រ និងយេមែន សុទ្ធតែជាប្រទេសទទួលផលពីប្រព័ន្ធអនុគ្រោះនេះ (សម្រាប់ព័ត៌មានលម្អិតសូមមើល http://trade.ec.europa.eu/doclib/docs/2013/april/tradoc_150983.pdf)។ ការអនុវត្តឡើងវិញកាលពីខែ កក្កដា ឆ្នាំ ២០១៣ នៃកម្មវិធីអនុគ្រោះពន្ធរបស់សហភាពអឺរ៉ុប បានផ្តល់លទ្ធភាពឲ្យប្រទេសមីយ៉ាន់ម៉ាទទួលបានអត្ថប្រយោជន៍ពីប្រព័ន្ធអនុគ្រោះនេះ (សម្រាប់ព័ត៌មានលម្អិត សូមមើល http://eeas.europa.eu/delegations/myanmar/documents/page_content/gsp_guidance_en.pdf)។

[7] តាមគោលការណ៍ កិច្ចព្រមព្រៀងនេះត្រូវបានធ្វើឡើងនៅថ្ងៃទី ៤ ខែ សីហា ឆ្នាំ ២០១៥ ស្តីពីពាណិជ្ជកម្មសេរីដែលរួមទាំងការលុបបំបាត់ពន្ធស្ទើរតែទាំងអស់ (ជាង ៩៩%)។ វៀតណាមនឹងលើកលែងពន្ធក្នុងរយៈពេល ១០ ឆ្នាំ

នេះ ដើម្បីធ្វើពិពិធកម្មវិស័យកម្មន្តសាលឲ្យលើសពីវិស័យកាត់ដេរ នៅខែសីហា អាជ្ញាធរបានបង្កើតគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជា (IDP) ឆ្នាំ ២០១៥-២០២៥ សំដៅបង្កើនកម្រិតឧស្សាហូបនីយកម្មត្រឹមឆ្នាំ ២០២៥ (សម្រាប់ព័ត៌មានលម្អិត សូមមើលប្រអប់ ១ ស្តីពីគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្ម)។

**ការងើបឡើងវិញបន្តិច នៅប្រទេសដែលមានចំណូលខ្ពស់កំពុងកើតមាន ដែលមានភាពវិជ្ជមានចំពោះសេដ្ឋកិច្ចប្រទេសកម្ពុជានៅខណៈ ដែលសហរដ្ឋអាមេរិក និងសហគមន៍អឺរ៉ុប គឺជាទីផ្សារនាំចេញសំខាន់ពីរ ដែលស្រូបយក ៣២ ភាគរយ និង ២៣,៥ ភាគរយ នៃការនាំចេញសរុប។** នៅសហរដ្ឋអាមេរិក កំណើនគួរបង្កើនបន្តិចចំពោះចំនួន២,៧ ភាគរយ ជាមធ្យម ក្នុងឆ្នាំ ២០១៥ ដល់ ២០១៦។ សេដ្ឋកិច្ចសហរដ្ឋអាមេរិកកើនឡើងចំនួន ៣,៧ ភាគរយ នៅត្រីមាសទី២ (អត្រាប្រចាំឆ្នាំកែសម្រួលតាមរដូវតាម ត្រីមាស [qoq SAAR])។ នៅខណៈដែលកំណើន នៅតំបន់អឺរ៉ុបថយចុះបន្តិចមកត្រឹម ១,៦ ភាគរយនៅ ត្រីមាសទី ២ បន្ទាប់ពីការកើនទៅ ២,២ ភាគរយនៅត្រីមាសទី១ មានការគាំទ្រដោយកម្មវិធីគោលនយោបាយរូបិយវត្ថុបើកទូលាយ របស់ធនាគារ កណ្តាលអឺរ៉ុប ដែលជួយកែលម្អស្ថានភាពឥណទាន និងធ្វើឲ្យប្រាក់អឺរ៉ូចុះខ្សោយ និងជួយសេដ្ឋកិច្ចតូចៗឲ្យរួចផុតពីហានិភ័យពីប្រទេសក្រិច។

## គ) វិស័យទេសចរណ៍



អេកូទេសចរណ៍កំពុងជួយធ្វើពិពិធកម្មវិស័យទេសចរណ៍ និងការពារបរិស្ថាន។

**វិស័យទេសចរណ៍នៅតែដំណើរការមិនបានពេញលេញ ទោះបីជាមានការស្តារឡើងវិញ នៃវិស័យទេសចរណ៍ក្នុងតំបន់** (រូប ៧)។ ការចូលមកនៃភ្ញៀវទេសចរក្នុងអំឡុងឆមាសទីមួយក្នុងឆ្នាំ ២០១៥ បានកើនឡើងត្រឹមតែ ៤,៦ ភាគរយប៉ុណ្ណោះ (មានភ្ញៀវទេសចររហូតដល់ ២,៣ លាននាក់) ទាបជាងឆ្នាំ ២០១៤ ដែលមានកំណើន ៦,៩ ភាគរយ។ ការចូលមកទស្សនាតាមផ្លូវអាកាសមានការថយចុះបន្តិចថែមទៀត ដោយបានកើនឡើងចំនួន ៧,៣ ភាគរយក្នុងអំឡុងឆមាសទី ១ ក្នុងឆ្នាំ ២០១៥ ធៀបនឹងឆ្នាំ ២០១៤ កំណើននេះមានចំនួន ១២,៧ ភាគរយ។ ក្នុងរយៈពេល ៨ ខែដំបូងក្នុងឆ្នាំ ២០១៥ ភ្ញៀវទេសចរអន្តរជាតិ ដែលមកទស្សនាតំបន់ប្រាង្គប្រាសាទអង្គរដែលជាតំបន់ទាក់ទាញភ្ញៀវទេសចរបំផុតនៅកម្ពុជា មានកំណើនតិចតួច ដោយកើនឡើងចំនួន ១,៩ ភាគរយ រហូតដល់ ១,៤ លាននាក់។ ប្រាក់ចំណូលដុលពីថ្លៃចូលទស្សនាតំបន់អង្គរ ស្ទើរតែនៅទ្រឹង ដោយកើនឡើងត្រឹមតែ ០,០៣ ភាគរយ បើធៀបនឹងឆ្នាំមុន ដែលស្មើនឹង ៣៩,៨ លានដុល្លាអាមេរិក[9]។

ចំណែកសហគមន៍អឺរ៉ុបនឹងលើកលែងពន្ធក្នុងរយៈពេល ៧ ឆ្នាំ។ សម្រាប់ព័ត៌មានលម្អិត សូមមើល http:// ec.europa.eu/trade/policy/countries-and-regions/countries/vietnam/។

[8] បន្តអនុវត្តន៍៖ បច្ចុប្បន្នភាពសេដ្ឋកិច្ចអាស៊ីបូព៌ា និងប៉ាស៊ីហ្វិក ខែតុលា ឆ្នាំ ២០១៥ ធនាគារពិភពលោក

[9] យោងតាមអាជ្ញាធរអប្សរា។ សម្រាប់ព័ត៌មានបន្ថែម សូមមើល ៖ http://apsaraauthority.gov.kh/?page=detail&ctype=article&id=974&lg=kh។

**បន្ទាប់ពីទទួលបានកំណើនពីរខ្ទង់ នៃការចូលមកទស្សនារបស់ភ្ញៀវទេសចរចាប់ពីឆ្នាំ ២០១០ មក វិស័យទេសចរណ៍បានចុះថយបន្តិចពីឆ្នាំ ២០១៤** ដោយមានកំណើនត្រឹមតែ ៦,៩ ភាគ រយ ដោយរយៈពេលស្នាក់នៅជាមធ្យមបានថយចុះដល់ ៦,៥ ថ្ងៃ ចុះពី ៦,៨ ថ្ងៃនៅឆ្នាំ ២០១៣។ ជាលទ្ធផល អត្រាមធ្យមនៃការស្នាក់នៅក្នុងសណ្ឋាគារបានថយចុះមកត្រឹម ៦៧,៥ ភាគរយ នៅឆ្នាំ ២០១៤ ចុះពី ៦៩,៥ ភាគរយ នៅឆ្នាំ ២០១៣[10]។ ចំណាយមធ្យមប្រចាំថ្ងៃសម្រាប់ ភ្ញៀវទេសចរម្នាក់បានថយចុះមកត្រឹម ៩៣,៤ ដុល្លាអាមេរិក នៅឆ្នាំ ២០១៤ ចុះពី ១២០,៧ ដុល្លាអាមេរិកនៅឆ្នាំ ២០១៣។ ទោះបីជាវិស័យនៅកម្ពុជាមានកំណើនថយចុះបន្តិចក៏ដោយ ប៉ុន្តែវិស័យទេសចរណ៍សកលមានការកើនឡើង11។ ការរួមចំណែកចំពោះកំណើនពិតក្នុងឆ្នាំ ២០១៤ ដោយវិស័យសណ្ឋាគារ និងភោជនីយដ្ឋាន ដែលរងឥទ្ធិពលផ្ទាល់ពីការចូលមកនៃភ្ញៀវទេសចរ ក៏បានបន្ថយល្បឿនដែរ (តារាង ១)។

គំនិតផ្តួចផ្តើមបច្ចុប្បន្ន ស្តីពីកិច្ចសហការទ្វេភាគីជាមួយប្រទេសថៃ "រាជាណាចក្រពីរ ទិសដៅតែមួយ" និង កិច្ចសហប្រតិបត្តិការវិស័យទេសចរណ៍តំបន់ ឬពហុភាគី និងការបង្កើតជើងហោះហើរដោយផ្ទាល់ រួមទាំងការរៀបចំយុទ្ធសាស្ត្រទីផ្សារវិស័យទេសចរណ៍ ឆ្នាំ ២០១៥-២០២០ ដោយអាជ្ញាធរ នឹងអាចជួយបង្កើនចំនួនភ្ញៀវទេសចរបាន។ កិច្ចសហការរវាងវិស័យសាធារណៈ និងឯកជន ត្រូវបានពង្រឹងបន្ថែមដោយមានការបង្កើត ក្រុមការងារកែលម្អផលិតផលជាប្រចាំការស្វែងយល់ពីទីផ្សារ និងការគ្រប់គ្រងក្នុងវិស័យទេសចរណ៍[12]។

[10] របាយការណ៍ឆ្នាំ ២០១៤ និង ២០១៥ របស់ក្រសួងទេសចរណ៍។

[11] ការទទួលបានភ្ញៀវទេសចរអន្តរជាតិកើនឡើងនៅគ្រប់តំបន់ ៖ អឺរ៉ុប ដែលមានប្រមាណ ៤១ ភាគរយនៃភ្ញៀវទេសចរអន្តរជាតិសរុប ទទួលបានកំណើនប្រាក់ចំណូលពីវិស័យទេសចរណ៍ ដោយកើនពី ១៧ ពាន់លានដុល្លា អាមេរិករហូតដល់ ៥០៩ ពាន់លានដុល្លាអាមេរិក (៣៨៣ ពាន់លានអឺរ៉ូ)។ អាស៊ី និងប៉ាស៊ីហ្វិក (៣០ ភាគរយនៃចំណែកទីផ្សារ) មានកំណើន ១៦ ពាន់លានដុល្លាអាមេរិក ដែលបានកើនឡើងរហូតដល់ ៣៧៧ ពាន់លានដុល្លាអាមេរិក (២៨៤ ពាន់លានអឺរ៉ូ)។ នៅតំបន់អាមេរិក (២២ ភាគរយ) ចំណូលទេសចរណ៍បានកើនឡើង ១០ ពាន់លានដុល្លាអាមេរិករហូតដល់ ២៧៤ ពាន់លានដុល្លាអាមេរិក (២០៦ ពាន់លានអឺរ៉ូ)។ ក្នុងតំបន់មជ្ឈិមបូព៌ា (៤ ភាគរយ) ចំណូល ទេសចរណ៍បានកើនឡើង ៤ ពាន់លានដុល្លាអាមេរិករហូតដល់ ៤៩ ពាន់លានដុល្លាអាមេរិក (៣៧ ពាន់លានអឺរ៉ូ) និងអាហ្វ្រិក (៣ ភាគរយ) ចំណូលទេសចរណ៍កើនឡើងពី ១ ពាន់លានដុល្លាអាមេរិករហូតដល់ ៣៦ ពាន់ លានដុល្លាអាមេរិក (២៧ ពាន់លានអឺរ៉ូ)។ សូមមើល ៖ http://media.unwto.org/press-release/2015-04-15/exports-international-tourism-rise-us-15-trillion-2014។

[12] សម្រាប់ព័ត៌មានលម្អិត សូមមើល ៖ http://www.tourismcambodia.org/news/index.php?view=detail&nw=233#comp។

## ប្រអប់ ១ ៖ ខ្លឹមសារសង្ខេបនៃគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជា ឆ្នាំ ២០១៥-២០២៥

**គោលនយោបាយ និងយុទ្ធសាស្ត្រ**

បន្ទាប់ពីប្រកាសជាផ្លូវការនៅខែ សីហា ឆ្នាំ ២០១៥ គោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជា ឆ្នាំ ២០១៥-២០២៥ (IDP) មានគោលបំណងជាយុទ្ធសាស្ត្រក្នុងការ (១) ទាក់ទាញការវិនិយោគ (២) ធ្វើទំនើបកម្មសហគ្រាសខ្នាតតូច និងមធ្យម (៣) កែលម្អក្របខ័ណ្ឌគតិយុត្តិ និង (៤)សម្របសម្រួលគោលនយោបាយគាំទ្រ។

**គោលដៅសំខាន់ៗ**

(១) បង្កើនចំណែកនៃ ផសស ពីវិស័យឧស្សាហកម្មឲ្យបាន ៣០ ភាគរយក្នុងឆ្នាំ ២០២៥ ពី ២៤,១ ភាគរយនៅឆ្នាំ ២០១៣ ទន្ទឹមនឹងការបង្កើនកំណើនវិស័យកម្មន្តសាលប្រចាំឆ្នាំពី ១៥,៥ ភាគរយ នៅឆ្នាំ២០១៣ ឆ្នាំរហូតដល់ ២០ ភាគរយនៅឆ្នាំ២០២៥។

(២) បង្កើនការនាំចេញផលិតផលកម្មន្តសាល (ផលិតផលក្រៅពីវាយនភ័ណ្ឌ) រហូតដល់ ១៥ ភាគរយនៃការនាំចេញសរុប ត្រឹមឆ្នាំ ២០២៥ (ពី ១ ភាគរយនៅឆ្នាំ ២០១៣) និងបង្កើនការនាំចេញផលិតផលកសិកម្មកែច្នៃ រហូតដល់ ១២ ភាគរយត្រឹមឆ្នាំ ២០២៥ (ពី ៧,៩ ភាគរយនៅឆ្នាំ ២០១៣) និង

(៣) ចុះបញ្ជីជាផ្លូវការចំពោះសហគ្រាសខ្នាតតូច និងមធ្យមក្នុងប្រទេសពី ៨០ ទៅ ៩៥ ភាគរយ ត្រឹមឆ្នាំ ២០២៥ ហើយសហគ្រាសពី ៥០ ទៅ ៧០ ភាគរយនឹងមានគណនី និងតារាងតុល្យការត្រឹមត្រូវ។

**វិស័យអាទិភាព**

(១) ឧស្សាហកម្មថ្មីៗដែលមានសមត្ថភាពចូលទៅក្នុងទីផ្សារថ្មីដែលមានតម្លៃបន្ថែមខ្ពស់ ផលិតផលប្រកួតប្រជែងខ្ពស់ និងច្នៃប្រឌិត ដែលផ្តោតលើផលិតផលប្រើប្រាស់ និងការតំឡើងគ្រឿងម៉ាស៊ីន ការតំឡើងសម្ភារ/ឧបករណ៍ម៉ាស៊ីន/អេឡិចត្រូនិក/អគ្គិសនី មធ្យោបាយដឹកជញ្ជូន និងការកែច្នៃធនធានធម្មជាតិ។

(២) សហគ្រាសខ្នាតតូច និងមធ្យមសម្រាប់ផលិតឱសថ ថ្នាំពេទ្យ និងសម្ភារវេចខ្ចប់សម្រាប់នាំចេញ និងសម្ភារសំណង់។

(៣) ផលិតកម្មកសិឧស្សាហកម្មសម្រាប់ទីផ្សារនាំចេញ និងទីផ្សារក្នុងស្រុក។

(៤) គាំទ្រឧស្សាហកម្មសម្រាប់វិស័យកសិកម្ម ទេសចរណ៍ និងវិស័យវាយនភ័ណ្ឌ និងគាំទ្រខ្សែសង្វាក់តម្លៃសកល និងតំបន់ ដែលជួយដល់ផ្នែកពាក់ព័ន្ធផ្សេងទាំងផ្នែកខាងមុខ និងក្រោយ និង

(៥) ឧស្សាហកម្មជួយដល់បណ្តាញផលិតកម្មតំបន់ និងឧស្សាហកម្មយុទ្ធសាស្ត្រ ដូចជា ប្រព័ន្ធព័ត៌មានវិទ្យា និងអគ្គិសនី ទូរគមនាគមន៍ ឧស្សាហកម្មធុនធ្ងន់។ល។

**ការដឹកនាំ ការសម្របសម្រួល និងការអនុវត្ត**

(១) ពង្រឹងការដឹកនាំរបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា។

(២) កែលម្អមុខងារ និងសមត្ថភាពរបស់គណៈកម្មាធិការវិនិយោគកម្ពុជា។

(៣) កែសម្រួលមុខងាររបស់គណៈកម្មាធិការនីតិសម្បទា និងអភិវឌ្ឍន៍កម្ពុជា។

(៤) ពង្រឹងវេទិការដ្ឋាភិបាល និងវិស័យឯកជន និង

(៥) បង្កើតយន្តការពិនិត្យតាមដាន និងវាយតម្លៃ។

---

ប្រភព ៖ គោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជា ឆ្នាំ ២០១៥-២០២៥

## ប្រអប់ ២ ៖ សហគមន៍សេដ្ឋកិច្ចអាស៊ាន (AEC)

**ការបង្កើតទីផ្សារ និងមូលដ្ឋានផលិតកម្មតែមួយ**គឺជាគោលបំណងដ៏សំខាន់បំផុតមួយក្នុង ចំណោមគោលបំណងនៃសហគមន៍នេះ។ ដើម្បីសម្រេចគោលបំណងនេះ ត្រូវមានការអនុវត្តដោយជោគជ័យនូវសមាសធាតុសំខាន់ៗទាំង ៥ គឺ (១) លំហូរទំនិញដោយសេរី (២) លំហូរសេវាកម្មដោយសេរី (៣) លំហូរការវិនិយោគដោយសេរី និង (៤) លំហូរមូលធនដោយសេរី (៥) លំហូរពលកម្មជំនាញដោយសេរី ។ សហគមន៍នេះក៏នឹងសម្របសម្រួលការបង្កើតបណ្តាញផលិតកម្មក្នុងតំបន់ និងពង្រឹងសមត្ថភាពរបស់អាស៊ានក្នុងការប្រែក្លាយជាមជ្ឈមណ្ឌលផលិតកម្មសកល និង/ឬ ជាផ្នែកមួយនៃខ្សែសង្វាក់ផ្គត់ផ្គង់សកល។

**លំហូរសេវាពាណិជ្ជកម្មដោយសេរី ៖** នឹងស្ទើរតែលែងមានការរឹតត្បិតលើក្រុមហ៊ុនផ្គត់ផ្គង់សេវាអាស៊ានដែលផ្តល់សេវា និងការបង្កើតក្រុមហ៊ុនតាមប្រទេសក្នុងតំបន់ ដែលត្រូវអនុលោមតាមច្បាប់ក្នុងប្រទេសសាមី។

**លំហូរមូលធនដោយសេរី ៖** ពង្រឹងការបង្កើតទីផ្សារមូលធនអាស៊ាន និងការធ្វើសមាហរណកម្មដែលមានការបន្សុីគ្នា និងមានស្តង់ដា។

**លំហូរពលកម្មជំនាញដោយសេរី ៖** សម្របសម្រួលការផ្តល់ទិដ្ឋាការ និងលិខិតអនុញ្ញាតឲ្យ បំពេញការងារសម្រាប់អ្នកជំនាញឯកទេស និងពលកម្មជំនាញអាស៊ាន ដែលពាក់ព័ន្ធក្នុងពាណិជ្ជកម្មឆ្លងដែន និងសកម្មភាពពាក់ព័ន្ធនឹងការវិនិយោគ។

**កម្ពុជាអាចនឹងទទួលអត្ថប្រយោជន៍ជាច្រើនពីសហគមន៍នេះ ប្រសិនបើសម្រេចបានគោលដៅទីផ្សារ និងមូលដ្ឋានផលិតកម្មតែមួយ។** ការធ្វើបែបនេះនឹងផ្តល់នូវសេដ្ឋកិច្ចមាត្រដ្ឋាន (economies of scale) ដោយនៅពេលនោះ ទីផ្សារក្នុងស្រុកដ៏តូចរបស់កម្ពុជានឹងលែងចោទជាបញ្ហាទៀតហើយ។ ជាមួយនឹងលំហូរពលកម្មជំនាញ ការពង្រីកផលិតកម្មក្នុងស្រុកដែលមានតម្លៃបន្ថែមខ្ពស់ ដូចជា ឧស្សាហកម្មកែច្នៃកសិកម្ម នឹងត្រូវបានអភិវឌ្ឍ និងពង្រឹងបន្ថែមទៀត នៅខណៈដែលពលកម្មគ្មានជំនាញដែលមានប្រាក់ឈ្នួលទាបរបស់កម្ពុជា គួរតែអាចបន្តជួយដល់វិស័យឧស្សាហកម្មដែលប្រើប្រាស់កម្លាំងពលកម្ម ច្រើនរបស់កម្ពុជា ដូចជា សម្លៀកបំពាក់ និងស្បែកជើង។ របបវិនិយោគ និងពាណិជ្ជកម្មបើកចំហររបស់កម្ពុជា អាចនឹងមិនរងផលប៉ះពាល់ខ្លាំងពីលំហូរសេវាពាណិជ្ជកម្មសេរី និងមូលធនទេ ប៉ុន្តែពលកម្មជំនាញរបស់កម្ពុជា អាចនឹងត្រូវប្រកួតប្រជែងនឹងលំហូរកម្លាំងពលកម្មជំនាញខ្ពស់ជាច្រើន ពីសមាជិកអាស៊ានផ្សេងទៀត។ ដូច្នេះ កម្ពុជាត្រូវបង្កើនគុណភាពអប់រំ និងជំនាញសមស្របនៃកម្លាំងពលកម្មរបស់ខ្លួន ដើម្បីត្រៀមលក្ខណៈសម្រាប់ការប្រកួតប្រជែងក្នុងតំបន់។ ដោយមានការ វិនិយោគដ៏ល្អដូចមានកំណត់នៅក្នុងគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្ម លំហូរពលកម្ម ជំនាញដោយសេរី គួរតែជាឱកាសមួយដើម្បីបន្ថយចំណាយផលិតកម្ម និងកាន់តែមានភាពប្រកួតប្រជែងទៀតផង។

ការស្រាវជ្រាវបានបង្ហាញពីផលប្រយោជន៍យ៉ាងច្រើនពីការអនុវត្ត និងការពង្រីកកម្មវិធីធ្វើសមាហរណកម្មនេះ។[១] ជាពិសេស ត្រឹមឆ្នាំ ២០២៥ ការអនុវត្តសហគមន៍អាស៊ាននេះ អាចធ្វើឲ្យមាន កំណើន ផសស ចំនួន ៧,១ ភាគរយ បើធៀបនឹងទិន្នន័យគោល ដោយផលប្រយោជន៍ភាគច្រើនមាន ចំពោះសមាជិកអាស៊ានដែលមានប្រាក់ចំណូលទាប។ ដូចគ្នាដែរ ការងារនៅក្នុងសេដ្ឋកិច្ចនៃបណ្តា ប្រទេសអាស៊ានទាំង ៦ ដែលរួមមាន កម្ពុជា ឥណ្ឌូនេស៊ី ឡាវ ហ្វីលីពីន ថៃ និងវៀតណាម នឹងកើនឡើងចំនួន ១៤ លាន ឬ ២ ភាគរយ នៅ(ឥណ្ឌូនេស៊ី) ១០ ភាគរយ នៅ (កម្ពុជា)នៃកម្លាំងពលកម្មសរុប ។

---

[១] បន្តអនុវត្តន៍៖សូមមើលរបាយការណ៍ បន្តអនុវត្តន៍៖ បច្ចុប្បន្នភាពសេដ្ឋកិច្ចតំបន់អាស៊ីបូព៌ា និងប៉ាស៊ីហ្វិក ខែ តុលា ឆ្នាំ ២០១៥ របស់ធនាគារពិភពលោក ៖ http://www.asean.org/communities/asean-economic-community

ប្រភព ៖ http://www.asean.org/communities/asean-economic-community។

**ចំនួនភ្ញៀវទេសចរមកពីប្រទេសវៀតណាម ចិន និងកូរ៉េ នៅតែបន្តឈានមុខគេ** ហើយចំនួនភ្ញៀវទេសចរសរុបមកពីប្រទេសទាំងបីនេះមានចំនួនជាង ៤៥ ភាគរយនៃចំនួនភ្ញៀវទេសចរសរុប។ ចំនួនភ្ញៀវទេសចរថៃមកកាន់កម្ពុជា បានកើនឡើងចំនួន ៣០,៨ ភាគរយ ក្នុងអំឡុងឆមាសទី ១ ក្នុងឆ្នាំ ២០១៥ បើធៀបនឹងឆ្នាំ ២០១៤[13] នេះដោយសារតែស្ថិរភាពមានភាពប្រសើរឡើងនៅក្នុងប្រទេសជិតខាងនេះ។

**រូប ៧ ៖ ចំនួនភ្ញៀវទេសចរដែលចូលមកទស្សនាកម្ពុជានៅតែមានកំណើនទាប ខណៈពេលដែលចំនួនភ្ញៀវទេសចរទៅកាន់ប្រទេសថៃបានកើនឡើងនៅពាក់កណ្ដាលឆ្នាំ ២០១៥ ចំណែកឯចំនួនភ្ញៀវទេសចរទៅកាន់ប្រទេសវៀតណាមមានការថយចុះ** (៣ mma % ប្រែប្រួលធៀបនឹងឆ្នាំមុន)




ប្រភព ៖ អាជ្ញាធរ, អាជ្ញាធរទេសចរណ៍ (ថៃ) និងក្រសួងវប្បធម៌ កីឡា និងទេសចរណ៍ (វៀតណាម)

## ឃ) វិស័យកសិកម្ម



ផ្លូវទឹកជាមធ្យោបាយធ្វើដំណើរដែលមានតម្លៃថោកបំផុត។

**វិស័យកសិកម្មនៅតែមានភាពយឺតយ៉ាវ ដោយសារតែការដាំដុះដំណាំពឹងផ្អែកខ្លាំងលើទឹកភ្លៀង។** ទោះបីជាមានកិច្ចខិតខំប្រឹងប្រែង ក្នុងការកែលម្អប្រព័ន្ធធារាសាស្ត្រកម្ពុជាក្តី ប៉ុន្តែ វិស័យកសិកម្មនៅតែពឹងផ្អែកខ្លាំងលើការដាំដុះស្រូវនៅរដូវវស្សា ដែលពឹងផ្អែកយ៉ាងខ្លាំងទៅលើទឹកភ្លៀង។

**តារាង ៥ ៖ ការដាំដុះកសិកម្ម និងផលិតផលមានភាពយឺតយ៉ាវនៅក្នុងឆ្នាំ ២០១៥ ត្រឹមខែកក្កដា ២០១៤ ត្រឹមខែកក្កដា ២០១៥**

| | គិតត្រឹម ខែកក្កដា ឆ្នាំ២០១៤ | គិតត្រឹម ខែកក្កដា ឆ្នាំ២០១៥ | ការប្រែប្រួល (%) |
|---|---|---|---|
| ការដាំស្រូវវស្សា (ហិកតា) | 1,842,460 | 1,737,046 | -5.7 |
| ការប្រមូលផលស្រូវ (តោន) | 284,390 | 191,263 | -32.7 |
| ការដាំដំឡូង (ហិកតា) | 477,679 | 527,705 | 10.5 |
| ដំណាំឧស្សាហកម្មផ្សេងទៀត (ហិកតា) | 152,705 | 130,734 | -14.4 |

ប្រភព៖ អាជ្ញាធរ

**នៅឆ្នាំ ២០១៥ ការធ្លាក់ភ្លៀងយឺតបានធ្វើឲ្យការដាំដុះស្រូវរដូវវស្សាចាប់ផ្តើមយឺត** (តារាង ៥)។ ការប្រមូល ផលស្រូវរដូវវស្សាក៏បានថយចុះ។ ការដាំដុះដំណាំផ្សេងទៀត (លើកលែងតែដំឡូង) ដូចជា ពោត សណ្តែក និងបន្លែផ្សេងទៀត ក៏មានភាពយឺតយ៉ាវដែរ។ ដើម្បីដោះស្រាយបញ្ហានេះ មានកិច្ចខិត ខំប្រឹងប្រែងមួយចំនួនដើម្បីពន្លឿនការដាំដុះ បន្ទាប់ពីមានភ្លៀងគ្រប់គ្រាន់នៅខែកក្កដា នៅពេលមាន ការណែនាំ និងការគាំទ្រផ្នែកបច្ចេកទេស ដើម្បីទប់ទល់នឹងការប៉ះពាល់ដែលបណ្តាល មកពីគ្រោះរាំងស្ងួត។

នៅឆ្នាំ ២០១៤ ការធ្លាក់ភ្លៀងយឺត បានធ្វើប៉ះពាល់ផ្ទៃដីដាំដុះស្រូវវស្សា ហើយគ្រោះរាំងស្ងួតបានធ្វើឲ្យទិន្នផលទាប។ ជាលទ្ធផល ទិន្នផលជាមធ្យមនៃស្រូវវស្សាបានថយចុះ ៣,៨ ភាគរយ នៅត្រឹម ២,៨១ តោនក្នុងមួយហិកតា (រូប ៨) ដែលបានកាត់បន្ថយទិន្នផលចំនួន ១,៧៥ ភាគរយ មក ៧,១៩ លានតោន[14]។ ផលិតផលស្រូវសរុបឆ្នាំ ២០១៤ ទាំងស្រូវរដូវវស្សា និងរដូវប្រាំង

[13] កំណើននេះកើតឡើងមុនពេលមានការផ្ទុះគ្រាប់បែកនៅទីក្រុងបាងកកកាលពីខែ សីហា ឆ្នាំ ២០១៥។

[14] សម្រាប់ព័ត៌មានបន្ថែម សូមមើលរបាយការណ៍ប្រចាំឆ្នាំរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ឆ្នាំ២០១៤-២០១៥ និងទិសដៅឆ្នាំ ២០១៥-២០១៦។

បានថយចុះមកត្រឹម ៩,៣៣ លានតោន ចុះពី ៩,៣៩ លានតោននៅឆ្នាំ ២០១៣។ ការចូលរួមចំណែកនៃវិស័យនេះចំពោះ ផសស ពិត បានថយចុះយ៉ាងលឿនក្នុងអំឡុងឆ្នាំ ២០១៣ ដល់ ២០១៤ (តារាង ២)។

**រូប ៨ ៖ ការដាំដុះ ផលិតផល និងកំណើនទិន្នផលស្រូវរដូវវស្សា បានថយចុះនៅឆ្នាំ ២០១៤** (% ប្រែប្រួលធៀបនឹងឆ្នាំមុន)




ប្រភព ៖ អាជ្ញាធរ

**តម្លៃអង្ករថយចុះ។** ការធ្លាក់ចុះតម្លៃផលិតផលកសិកម្ម បានជះឥទ្ធិពលអវិជ្ជមានទៅលើផលិតកម្មកសិកម្ម និងចំណូលពីការនាំចេញ ជាពិសេសសម្រាប់អង្ករ និងកៅស៊ូ។ ដូចបង្ហាញក្នុងតារាង៦ "ថ្លៃទំនិញដឹកដល់លើនាវា" (FOB) របស់អង្ករប្រភេទផ្សេងៗ បានថយចុះ។

**ក្នុងរយៈពេលជាងមួយទសវត្សរ៍កន្លងមក វិស័យកសិកម្មនៅកម្ពុជា បានជួបប្រទះការកែប្រែរចនាសម្ព័ន្ធយ៉ាងខ្លាំង។** បើទោះជានៅតែដើរតួនាទីយ៉ាងសំខាន់ វិស័យកសិកម្មបានដើរតួនាទី "សំខាន់" តិច ជាងមុននៅក្នុង ផសស ជារួម និងកម្លាំងពលកម្មសរុប ប៉ុន្តែ "មានផលិតភាព" ខ្ពស់ជាងមុន មានន័យថា ដីកសិកម្ម និងផលិតភាពកម្លាំងពលកម្ម បានកើនឡើង។ ការប្រែប្រួលនេះត្រូវបានជំរុញដោយ កំណើនកសិកម្មដ៏ល្អ និងជួយគាំទ្រដល់ជនក្រីក្រ។ ក្នុងអំឡុងឆ្នាំពី ២០០៤ ដល់ ២០១២ កំណើនប្រចាំឆ្នាំ នៃផលិតផលដុលមានចំនួន ៨,៧ ភាគរយ។ ផសស កសិកម្ម កើនឡើងជាមធ្យមក្នុងមួយឆ្នាំចំនួន ៥,៣ ភាគរយ នៅក្នុងអំឡុងពេលនេះ។

អត្រាកំណើនខ្លាំងនេះ ដែលស្ថិតក្នុងចំណោមអត្រាខ្ពស់បំផុត ក្នុងពិភពលោក ត្រូវបានជំរុញដោយផលិតផលដំណាំ ជាពិសេសដំណាំស្រូវ (កំណើនប្រចាំឆ្នាំជាមធ្យមចំនួន ៩ ភាគរយ) ប៉ុន្តែក៏មានពោត (២០ ភាគរយ) ដំឡូង (៥១ ភាគរយ) អំពៅ (២២ ភាគរយ) និងបន្លែ (១០ ភាគរយ)។ កំណើនការចិញ្ចឹមសត្វ និងនេសាទ មានតិចតួចប៉ុណ្ណោះ។

សូមមើលប្រធានបទពិសេសស្តីពី "វិស័យកសិកម្មកម្ពុជាក្នុងអន្តរកាល ៖ កាលានុវត្តភាព និងហានិភ័យ" ដើម្បីស្វែងយល់បន្ថែមពីកាលានុវត្តភាព និង បញ្ហាប្រឈមក្នុងវិស័យកសិកម្ម។

**តារាង ៦ ៖ ថ្លៃទំនិញដឹកដល់លើនាវារបស់អង្ករកំពុងថយចុះ** (ដុល្លារអាមេរិក/តោន)

| | មករា-១៤ | មីនា-១៤ | មិថុនា-១៤ | កញ្ញា-១៤ | ធ្នូ-១៤ | មករា-១៥ | មីនា-១៥ | មិថុនា-១៥ | សីហា-១៥ |
|---|---|---|---|---|---|---|---|---|---|
| **ភ្នំពេញ** | | | | | | | | | |
| អង្ករក្រអូប 5 | 870 | 880 | 850 | 885 | 815 | 795 | 800 | 790 | 830 |
| អង្ករចម្រុះ5 | 490 | 470 | 460 | 470 | 460 | 450 | 450 | 440 | 430 |
| IRRI66 5 | 490 | 460 | 440 | 452 | 460 | 435 | 435 | 425 | 420 |
| **ក្រុងព្រះសីហនុ** | | | | | | | | | |
| អង្ករក្រអូប 5 | 875 | 885 | 855 | 890 | 820 | 805 | 810 | 800 | 840 |
| អង្ករចម្រុះ5 | 495 | 475 | 465 | 475 | 465 | 458 | 460 | 450 | 440 |
| IRRI66 5 | 495 | 565 | 445 | 457 | 465 | 443 | 445 | 435 | 430 |

FOB = ថ្លៃទំនិញដឹកដល់លើនាវា, អង្ករម្លិះ 5 = អង្ករម្លិះដែលបែកបាក់ ៥ ភាគរយ

ប្រភព ៖ របាយការណ៍ពិនិត្យតាមដានអង្ករ ឆ្នាំ ២០១៥ ធនាគារពិភពលោក។

## ង) ប្រាក់ចំណូល ការប្រើប្រាស់ និងការងារ

**កំណើនយ៉ាងរឹងមាំនៃប្រាក់ចំណូល និងការប្រើប្រាស់ ក៏ត្រូវបានរកឃើញដោយការអង្កេតសេដ្ឋកិច្ចសង្គមកម្ពុជា ដែលបានធ្វើឡើងនៅឆ្នាំ ២០១៣ ដែលមានភាពស៊ីសង្វាក់ជាមួយនឹងទិន្នន័យគណនីជាតិ។** ការអង្កេតសេដ្ឋកិច្ចសង្គមកម្ពុជាឆ្នាំ ២០១៣ ក៏បានបង្ហាញថា ប្រាក់ចំណូលមធ្យម ប្រចាំខែរបស់គ្រួសារកម្ពុជាត្រូវបានប៉ាន់ស្មានថាបានកើនដល់ ១.២៣៦.០០០ រៀល នៅឆ្នាំ ២០១៣ ដែលកើនឡើងចំនួន ២១ ភាគរយ បើធៀបនឹងឆ្នាំ ២០១២ (តារាង ៧[15])។ ក្នុងចំណោមក្រុមគ្រួសារចំនួន

[15] ការអង្កេតសេដ្ឋកិច្ចសង្គម ឆ្នាំ ២០១៣ វិទ្យាស្ថានជាតិស្ថិតិ ក្រសួងផែនការ ខែកក្កដា ឆ្នាំ ២០១៤។

បី ដែលត្រូវបានបែងចែកទៅតាមភូមិសាស្ត្រ (ក្រុងភ្នំពេញ តំបន់ទីប្រជុំជនផ្សេងទៀត និងតំបន់ជនបទផ្សេងៗ) ប្រាក់ចំណូលរបស់ក្រុមគ្រួសារទីប្រជុំជនផ្សេងទៀត បានកើនឡើងយ៉ាងលឿនបំផុត រហូតដល់ ៤០,៤ ភាគរយក្នុងអំឡុងពេលនោះ[16]។ កំណើន ប្រាក់ចំណូលខ្ពស់ បានបង្កើនការប្រើប្រាស់ដែលបានកើនឡើងចំនួន ១៥ ភាគរយនៅឆ្នាំ ២០១៣ បើធៀបនឹងឆ្នាំ ២០១២ (តារាង ៨)។ ការប្រើប្រាស់របស់ "ក្រុមគ្រួសារទីក្រុងភ្នំពេញ" បានកើនឡើងលឿនជាងគេ ដោយកើនចំនួន ២១ ភាគរយក្នុងអំឡុងពេលនោះ។ កំណើនវិស័យសំណង់ និងអចលនទ្រព្យ កំពុងកើតមានភាគច្រើននៅទីក្រុងភ្នំពេញ ហើយកំណើននេះអាចជំរុញកំណើននៃការប្រើប្រាស់យ៉ាងលឿននៅទីនោះ។

**តារាង ៧ ៖ ប្រាក់ចំណូលរបស់ក្រុមគ្រួសារ "ទីប្រជុំជនផ្សេងទៀត" បានកើនឡើងច្រើនជាងគេ។** ប្រាក់ចំណូលគ្រួសារ (មធ្យមប្រចាំខែ គិតជាពាន់រៀល)

| | 2009 | 2010 | 2011 | 2012 | 2013 |
|---|---|---|---|---|---|
| កម្ពុជា | 747.0 | 901.0 | 888.0 | 1,019.0 | 1,236.0 |
| (% ប្រែប្រួល) | | 20.6 | -1.4 | 14.8 | 21.3 |
| ភ្នំពេញ | 2,039.0 | 1,987.0 | 1,819.0 | 1,886.0 | 2,517.0 |
| (% ប្រែប្រួល) | | -2.6 | -8.5 | 3.7 | 33.5 |
| **ទីក្រុងផ្សេងៗ** | **1,101.0** | **1,504.0** | **1,172.0** | **1,504.0** | **2,112.0** |
| (% ប្រែប្រួល) | | 36.6 | -22.1 | 28.3 | 40.4 |
| តំបន់ជនបទផ្សេងៗ | 563.0 | 697.0 | 728.0 | 816.0 | 931.0 |
| (% ប្រែប្រួល) | | 23.8 | 4.4 | 12.1 | 14.1 |

ប្រភព ៖ ការអង្កេតសេដ្ឋកិច្ចសង្គមកម្ពុជា ឆ្នាំ ២០១៣

**តារាង ៨ ៖ ការប្រើប្រាស់របស់គ្រួសារទីក្រុងភ្នំពេញបានកើនឡើងយ៉ាងលឿនបំផុត។** ការប្រើប្រាស់ប្រចាំខែ (គិតជាពាន់រៀល)

| | 2010 | 2011 | 2012 | 2013 |
|---|---|---|---|---|
| កម្ពុជា | 3,273 | 3,483 | 3,794 | 4,365 |
| (% ប្រែប្រួល) | | 6 | 9 | 15 |
| **ក្រុងភ្នំពេញ** | **688** | **794** | **721** | **876** |
| (% ប្រែប្រួល) | | 15 | -9 | 21 |
| ទីក្រុងផ្សេងៗ | 478 | 431 | 665 | 625 |
| (% ប្រែប្រួល) | | -10 | 54 | -6 |
| តំបន់ជនបទផ្សេងៗ | 2,107 | 2,258 | 2,409 | 2,864 |
| (% ប្រែប្រួល) | | 7 | 7 | 19 |

ប្រភព ៖ ការអង្កេតសេដ្ឋកិច្ចសង្គមកម្ពុជា ឆ្នាំ ២០១៣

**កម្ពុជាកំពុងមាន កំណើនកម្លាំងពលកម្មយ៉ាងលឿន ដែល ជួយគាំទ្រដល់ការពង្រីកផលិតកម្មក្នុងប្រទេស។** ចំនួនមនុស្សវ័យក្មេងច្រើន នៅកម្ពុជាបានធ្វើឲ្យមានកំណើនប្រជាជនដែលមានអាយុធ្វើការ (ក្រុមអាយុ ១៥-៦៤ ឆ្នាំ) ចំនួន ២ លាននាក់ពីឆ្នាំ ២០០៤ រហូតដល់ឆ្នាំ ២០១៣។ ជាលទ្ធផល អនុបាតនៃការពឹងផ្អែកបានថយចុះមក ៨៣ ភាគរយ នៅឆ្នាំ ២០១៣ ចុះពី ៨៩,៤ ភាគរយ នៅឆ្នាំ ២០០៩[17]។ កំណើនកម្លាំងពលកម្មហាក់ត្រូវបានស្រូបដោយកំណើនការងារខ្ពស់ ដោយមានកំណើនតម្រូវការកម្លាំងពលកម្ម ជាពិសេសក្នុង "តំបន់ទីប្រជុំជនផ្សេងទៀត" និង "តំបន់ជនបទផ្សេងទៀត"។

**ការអង្កេតសេដ្ឋកិច្ចសង្គម ក៏បានបង្ហាញនូវភាពប្រសើរឡើងនៃរចនាសម្ព័ន្ធការងារនៅកម្ពុជា ដោយមានកំណើននៃសមាសភាគនៃប្រភេទ "អ្នកធ្វើការដោយទទួលបានប្រាក់កម្រៃ" និង "អ្នកប្រកបការងារដោយខ្លួនឯង" និងការថយចុះនៃសមាសភាគ "អ្នកធ្វើការនៅផ្ទះដែលមិនបានទទួលប្រាក់កម្រៃ"។** "តំបន់ទីប្រជុំជនផ្សេងទៀត" មានកំណើនខ្ពស់បំផុតនៃសមាសភាគនៃអ្នកប្រកបការងារខ្លួនឯង ដែលបានកើនឡើងរហូតដល់ ៥២,៨ ភាគរយនៅឆ្នាំ ២០១៣ កើនពី ៤៧,៨ ភាគរយនៅឆ្នាំ ២០១១ នៅពេលដែលសមាសភាគអ្នកធ្វើការនៅផ្ទះដែលមិនទទួលបានប្រាក់កម្រៃ ដែលបានថយចុះដល់ ២,២ ភាគរយនៅ ឆ្នាំ ២០១៣ ចុះពី ១១,៣ ភាគរយនៅឆ្នាំ ២០១១ (តារាង ៩)។ ចំណុចនេះឆ្លុះបញ្ចាំងពីកំណើនសកម្មភាពសេដ្ឋកិច្ចនៅតំបន់ប្រជុំជន និងហាក់ដូចជាស៊ីសង្វាក់ទៅនឹងកំណើនប្រាក់ចំណូលយ៉ាងលឿននៃក្រុមគ្រួសារ "តំបន់ទីប្រជុំជនផ្សេងទៀត" ដែលបានពិភាក្សាខាងលើ។

[16] ប៉ុន្តែ សូមកត់សម្គាល់ថា មានកំហុសឆ្គងខ្លាំងចំពោះសំណាកគំរូតំបន់ទីប្រជុំជនផ្សេងទៀត។

[17] អនុបាតនៃការពឹងផ្អែកត្រូវបានកំណត់ថាជា ចំនួនកុមារ (០-១៤ ឆ្នាំ) និងមនុស្សចាស់ (៦៥ ឆ្នាំឡើងទៅ) ចែកនឹងចំនួនមនុស្ស (១៥-៦៤ ឆ្នាំ)។

**តារាង ៩ ៖ សម្រាប់ "តំបន់ទីប្រជុំជនផ្សេងទៀត" ការធ្វើការងារខ្លួនឯងបានកើនឡើងយ៉ាងច្រើនដោយអ្នកធ្វើការងារផ្ទះដែលមិនទទួលបានប្រាក់កម្រៃថយចុះ។**

ការងារតាមបំណែងចែកភូមិសាស្ត្រ និងប្រភេទ (គិតជា ១.០០០ និងភាគរយ)

| | 2011 | | | 2012 | | | 2013 | | |
|---|---|---|---|---|---|---|---|---|---|
| | ភ្នំពេញ | ទីក្រុងផ្សេងៗ | តំបន់ជនបទផ្សេងៗ | ភ្នំពេញ | ទីក្រុងផ្សេងៗ | តំបន់ជនបទផ្សេងៗ | ភ្នំពេញ | ទីក្រុងផ្សេងៗ | តំបន់ជនបទផ្សេងៗ |
| (១.០០០) ចំនួនអ្នកមានការងារ ធ្វើ | 770 | 793 | 6,328 | 848 | 950 | 5,908 | 942 | 810 | 6,199 |
| (ភាគរយ) អ្នកទទួលបានប្រាក់ កម្រៃ | 64.0 | 39.9 | 26.4 | 55.5 | 42.9 | 31.8 | 63.6 | 45.0 | 36.6 |
| អ្នកធ្វើការងារខ្លួនឯង | 26.9 | 48.7 | 57.2 | 33.9 | 50.3 | 59.0 | 30.6 | 52.8 | 58.6 |
| អ្នកធ្វើការងារផ្ទះដែលមិនទទួលបានប្រាក់កម្រៃ | 9.0 | 11.3 | 16.3 | 10.5 | 6.6 | 9.2 | 5.8 | 2.2 | 4.8 |

**ក្រុម "តំបន់ទីប្រជុំជនផ្សេងទៀត" មានកំណើនខ្ពស់នៃសមាសភាគការងារដែលទទួលបានប្រាក់កម្រៃ** ដែលបានកើនឡើងដល់ ៣៦,៦ ភាគរយ នៅឆ្នាំ ២០១៣ កើនពី ២៦,៤ ភាគរយនៅឆ្នាំ២០១១ នៅពេលដែលសមាសភាគនៃអ្នកធ្វើការងារផ្ទះ ដែលមិនទទួលបានប្រាក់កម្រៃ ថយចុះមក ៤,៨ ភាគរយ នៅឆ្នាំ ២០១៣ ចុះពី ១៦,៣ ភាគរយ នៅឆ្នាំ ២០១១។ ស្ថានភាពនេះបង្ហាញពីលទ្ធភាពបង្កើនការងារទទួលបាន ប្រាក់កម្រៃក្នុងតំបន់ជនបទ។ ប៉ុន្តែ "ទីក្រុងភ្នំពេញ" មានកំណើនទាបជាងគេក្នុងចំណោមតំបន់ទាំងបី។ ខុសពី "តំបន់ជនបទផ្សេងទៀត" និង "តំបន់ទីប្រជុំជនផ្សេងទៀត" "ទីក្រុងភ្នំពេញ" មានសមាសភាគការងារ ដែលទទួលបានប្រាក់កម្រៃថយចុះ មកត្រឹម ៦៣,៦ ភាគរយនៅឆ្នាំ ២០១៣ ចុះពី ៦៤ ភាគរយនៅឆ្នាំ ២០១១។

នៅឆ្នាំ ២០១៣ ចំនួនប្រជាជនសរុបដែលមានការងារធ្វើគឺ ៧.៩៥១.០០០ នាក់ក្នុងចំណោមកម្លាំងពលកម្មសរុបចំនួន ៧.៩៧៤.០០០នាក់ និងប្រជាជនដែលមានអាយុធ្វើការ (១៥-៦៤ ឆ្នាំ) សរុបចំនួន ៩.៦០៤.០០០ នាក់។ អត្រាចូលរួមក្នុងកម្លាំងពលកម្មគឺ ៧៤ ភាគរយ សម្រាប់ "ទីក្រុងភ្នំពេញ" ៧៧ ភាគរយសម្រាប់ "តំបន់ទីប្រជុំជនផ្សេងទៀត" និង ៨៥,៥ ភាគរយសម្រាប់ "តំបន់ជនបទផ្សេងទៀត" នៅឆ្នាំ ២០១៣ ចំណែកអត្រាការងារគឺ ៧៣,៩ ភាគរយសម្រាប់ "ទីក្រុងភ្នំពេញ" ៧៦,៦ ភាគរយសម្រាប់ "តំបន់ទីប្រជុំជនផ្សេងទៀត" និង ៨៥,២ ភាគរយសម្រាប់ "តំបន់ជនបទផ្សេង ទៀត[18]"។ ដូច្នេះ "តំបន់ជនបទផ្សេងទៀត" មានអត្រាចូលរួមក្នុងកម្លាំងពលកម្ម និងអត្រាការងារខ្ពស់បំផុត។

## វិស័យទូទាត់ក្រៅប្រទេស

**លំហូរវិនិយោគផ្ទាល់ពីបរទេសល្អប្រសើរ នៅតែជួយដល់វិស័យទូទាត់ក្រៅប្រទេសរបស់កម្ពុជា និងជួយជំរុញការប្រើប្រាស់។** តម្លៃប្រេងថយចុះក៏មានឥទ្ធិពលវិជ្ជមានដល់តុល្យភាពគណនីចរន្តកម្ពុជាដែរ ដោយសារតែកម្ពុជាជាប្រទេសនាំចូលប្រេង។ តម្លៃប្រេងថយចុះជួយសម្រួលដល់កំណើន នៃការនាំចូលក្នុងអំឡុងឆមាសទីមួយក្នុងឆ្នាំ ២០១៥ ដែលជួយមួយផ្នែក ប៉ះប៉ូវដល់ការបន្ថយល្បឿននៃការនាំចេញទំនិញ ដោយសារតែការនាំចេញសម្លៀកបំពាក់យឺតជាងមុន[19]។ ដូច្នេះ ឱនភាពគណនីចរន្ត ត្រូវបានព្យាករថាល្អប្រសើរបន្តិចរហូតដល់ ១០,៥ ភាគរយនៃផសស នៅឆ្នាំ ២០១៥ ធៀបនឹងឆ្នាំ ២០១៤ កំណើននេះ មានចំនួន ១០,៨% នៃផសស (រូប ៩)។ មានភាពប្រសើរឡើងផ្នែកសមតុល្យគណនីសេវា និងសមតុល្យគណនីបង្វែរចរន្ត ដោយសារតែការមានទំនុកចិត្តច្រើនជាងមុន សកម្មភាពសេដ្ឋកិច្ច

[18] យោងតាមការអង្កេតសេដ្ឋកិច្ចសង្គមកម្ពុជា ឆ្នាំ ២០១៣ ៖ ប្រជាជនដែលមានអាយុធ្វើការ (១៥-៦៤ ឆ្នាំ) ត្រូវបានបែងចែកជា (១) ប្រជាជនស្ថិតក្នុងកម្លាំងពលកម្ម (សកម្ម) និង (២) ប្រជាជនមិនស្ថិតក្នុងកម្លាំងពលកម្ម (មិនសកម្ម)។ កម្លាំងពលកម្មត្រូវបានបែងចែកជា (ក) មានការងារធ្វើ និង (ខ) គ្មានការងារធ្វើ។ អនុបាតនៃកម្លាំងពលកម្មដែលមានអាយុធ្វើការ គឺជាអត្រាចូលរួមក្នុងកម្លាំងពលកម្ម ចំណែកអនុបាតនៃការងារ និងកម្លាំងពលកម្ម គឺជាអត្រាការងារ។

[19] បើធៀបនឹងឆ្នាំ ២០១៤ បរិមាណនៃការនាំចូលសាំង និងម៉ាស៊ូត ត្រូវបានព្យាករថាកើនឡើងចំនួន ១២ ភាគរយក្នុងឆ្នាំ ២០១៥ នៅខណៈដែលតម្លៃនៃការនាំចូលត្រូវបានរំពឹងថានឹងកើនឡើងចំនួន ១០ ភាគរយ ដោយសារតែតម្លៃ ប្រេងថយចុះ។

ល្អជាបន្ត និងកំណើនបញ្ញើប្រាក់ក្នុងអំឡុងឆមាសទីមួយក្នុងឆ្នាំ ២០១៥[20]។ ឱនភាពពាណិជ្ជកម្ម ចំណូលដុលអវិជ្ជមាន នៅបន្តកើតមាន។ ដោយសារតែលំហូរនៃការវិនិយោគផ្ទាល់ពីបរទេស ល្អដែលកើតមានជាបន្ត ទុនបម្រុងអន្តរជាតិដុលមានភាពប្រសើរឡើង ដោយបានកើនឡើងដល់ ៥,២ ពាន់លានដុល្លាអាមេរិក ឬ ៤,១ ខែនៃការនាំចេញ ត្រឹមពាក់កណ្តាលឆ្នាំ ២០១៥។

**រូប៩ ៖ ការវិនិយោគផ្ទាល់ពីបរទេសបានផ្តល់ហិរញ្ញប្បទានភាគច្រើនដល់ឱនភាពគណនីចរន្ត។** ជញ្ជីងពាណិជ្ជកម្ម តុល្យភាពគណនីចរន្ត និងការវិនិយោគផ្ទាល់ពីបរទេស (គិតជាភាគរយនៃ ផសស)




ប្រភព ៖ អាជ្ញាធរ និងការប៉ាន់ស្មានរបស់បុគ្គលិកធនាគារពិភពលោក
p = ការព្យាករ

## ក) ការនាំចេញ

**ទោះបីជាមានការជោគជ័យពីដំបូងមួយចំនួន ក្នុងផ្នែកពិពិធកម្មផលិតផលនាំចេញ ការនាំចេញសម្លៀកបំពាក់នៅតែមានចំនួនជិតបីភាគបួន នៃការនាំចេញទំនិញសរុបនៅឆ្នាំ២០១៤។** កំណើនការប្រកួតប្រជែងទីផ្សារជាគោលដៅ បានទប់កំណើនការនាំចេញសម្លៀកបំពាក់ ខណៈដែលការធ្លាក់ចុះតម្លៃផលិតផលកសិកម្មបានជះឥទ្ធិពលលើចំណូលពីការនាំចេញកសិកម្ម ជាពិសេសការនាំចេញអង្ករ និងកៅស៊ូ ដែលធ្វើឲ្យមានកំណើនទាបនៃការនាំចេញទំនិញនៅឆ្នាំ ២០១៤។ នៅឆមាសទី ១ ក្នុងឆ្នាំ ២០១៥ កំណើនការនាំចេញស្បែកជើង និងកំណើនជាថ្មីនៃការនាំចេញអង្ករ និងកៅស៊ូ បានផ្តល់ជាសញ្ញាវិជ្ជមាន។ យ៉ាងណាក៏ដោយ សមាសភាគសរុបនៃផ្នែកទាំងនេះ នៅតែតិច ដែលមានប្រមាណ ១១ ភាគរយនៃការនាំចេញទំនិញសរុប។



រយៈពេលចំណាយលើការជំរះបញ្ជីថយចុះពី ៦ ថ្ងៃ (ឆ្នាំ ២០១០) មកនៅត្រឹម ១,៤ ថ្ងៃ (ឆ្នាំ ២០១៤) ដោយសារតែការធ្វើស្វ័យប្រវត្តិកម្មនៃនីតិវិធីគយ និងការកែលម្អហេដ្ឋារចនាសម្ព័ន្ធ។

**ការនាំចេញស្រូវ និងអង្ករសរុប ដែលបន្ទាប់ពីការនាំចេញសម្លៀកបំពាក់ មានចំនួនប្រមាណ ៩,៥ ភាគរយនៃការនាំចេញសរុបនៅឆ្នាំ ២០១៤។** កម្ពុជានៅតែត្រូវសម្រេចឲ្យបាននូវអត្ថប្រយោជន៍ ពីការនាំចេញអង្ករជំនួសឲ្យការនាំចេញស្រូវ។ នៅឆ្នាំ ២០១៤ ការនាំចេញអង្ករមានចំនួន ០,៣៧ លានតោន ស្មើនឹង ២១០ លានដុល្លាអាមេរិក។ កម្ពុជាបាននាំចេញស្រូវក្រៅផ្លូវការប្រមាណ ២,៣ លានតោន ស្មើនឹង ៥១២ លានដុល្លាអាមេរិក[21]។ ប្រសិនបើកម្ពុជាកិនស្រូវទាំង ២,៣ លានតោន និងនាំចេញជាអង្ករទាំងអស់ កម្ពុជានឹងទទួលបានចំណូល ៧៦១ លានដុល្លា។

[20] យោងតាមជញ្ជីងទូទាត់ក្នុងត្រីមាសទីពីរក្នុងឆ្នាំ ២០១៥។

[21] ការនាំចេញស្រូវសរុបនៅឆ្នាំ២០១៤ មានយ៉ាងហោចណាស់ ២,៨៦ លានតោន ក្នុងនោះ ស្រូវប្រមាណ ២,៣ លានតោន ត្រូវបាននាំចេញក្រៅផ្លូវការ ហើយអង្ករ ០,៣៧ លានតោន (ឬស្មើនឹងស្រូវ ០,៥៦ លានតោន) ត្រូវបាននាំចេញជាផ្លូវការ។ ក្នុងចំណោមស្រូវទាំង ២,៨៦ លានតោននោះ ស្រូវក្រអូបមាន ១ ភាគ ៣។ ដោយអង្ករក្រអូបមានពាក់កណ្តាលនៃអង្ករនាំចេញជាផ្លូវការសរុប ការនាំចេញស្រូវក្រអូបក្រៅផ្លូវការមាន ០,៦៧ លានតោន (២,៨៦ x១/៣- ០,៥៦ x១/២) ឬ ១៨៧ លានដុល្លាអាមេរិក ដោយមានតម្លៃ ២៨០ ដុល្លា/តោន។ ក្នុងចំណោមស្រូវទាំង ២,៨៦ លានតោន អង្ករផ្សេងៗមាន ២ ភាគ ៣។ ដោយអង្ករផ្សេងៗទៀតស្មើនឹងពាក់កណ្តាលនៃបរិមាណអង្ករនាំចេញជាផ្លូវការសរុប ការនាំចេញស្រូវផ្សេងទៀតក្រៅផ្លូវការមាន ១,៦៣ លានតោន (២,៨៦x២/៣-០,៥៦ x១/២) ឬ ៣២៥ លានដុល្លា ដោយមានតម្លៃ ២០០ ដុល្លា/តោន។ ការនាំចេញស្រូវក្រៅផ្លូវការសរុបគឺ ៥១២ លានដុល្លា (១៨៧+៣២៥)។ ប្រសិនបើកម្ពុជាកិនស្រូវទាំង ២,៣ លានតោន ហើយនាំចេញជាអង្ករទាំងអស់ កម្ពុជានឹងទទួល បានចំណូល ៧៦១ លានដុល្លា ក្នុងនោះ ៣២១ លានដុល្លា (០,៦៧ លានតោនx ៦០%x៨០០ដុល្លា/តោន) ពីអង្ករក្រអូប និង ៤៤០ លានដុល្លា (១,៦៣x៦០%x ៤៥០ ដុល្លា/តោន) ពីអង្ករផ្សេងទៀត។

ការនាំចេញស្រូវជាច្រើន (បរិមាណ ៨០ ភាគរយ) នៃការនាំចេញ (ស្រូវ និងអង្ករ) សរុប បង្ហាញពីភាពប្រកួតប្រជែងតម្លៃនាំចេញខ្លាំងក្លាចំពោះតម្លៃដើមពីកសិដ្ឋាន។ ដោយសារតែមានការចំណាយខ្ពស់ លើការកិនស្រូវ និងភស្តុភារ ស្រូវកម្ពុជាតែងតែបាត់បង់ការប្រកួតប្រជែងតម្លៃនៅពេលនាំចេញជាអង្ករ។ វិធានការកែលម្អការនាំចេញអង្ករសមស្រប គឺការផ្តោតលើការសម្របសម្រួលការកាត់បន្ថយចំណាយក្នុងការកិនអង្ករ និងភស្តុភារ ទន្ទឹមនឹងការបន្តអនុញ្ញាតឲ្យនាំស្រូវចេញ។ រាល់ការប៉ុនប៉ងដាក់ការរឹតត្បិត លើការនាំចេញស្រូវដើម្បីសម្រួលដល់ការនាំចេញអង្ករ នឹងផ្តល់ផលអវិជ្ជមានដល់កសិករ ផលិតកម្មស្រូវ និងសេដ្ឋកិច្ចទាំងមូល។

### ខ) ការនាំចូល



ស្វ័យប្រវត្តិកម្ម និងការគ្រប់គ្រងហានិភ័យ ជួយសម្រួលលំហូរពាណិជ្ជកម្ម។

**តម្រូវការខ្ពស់ក្នុងស្រុក បន្តជំរុញកំណើននៃការនាំចូល។** ទោះជាសន្ទុះកំណើនវិស័យសំណង់ បច្ចុប្បន្នបានរួមចំណែកដល់កំណើន នៃការនាំចូលសម្ភារសំណង់ក្តី ក៏ការថយចុះនៃតម្លៃប្រេងនាពេលថ្មីៗនេះ ជួយដល់កំណើនតម្រូវការប្រេង និងការនាំចូលយានយន្ត (តារាង ១០)[22]។ តម្រូវការក្នុងស្រុកក៏បានជំរុញការនាំចូលទំនិញប្រើប្រាស់ ដូចជា អាហារ និងភេសជ្ជៈផងដែរ។

តារាង ១០ ៖ កំណើននៃការនាំចូលយានយន្ត និងផលិតផលប្រេង ដោយសារតែកំណើនតម្រូវការក្នុងស្រុក និងការថយចុះតម្លៃប្រេង

| នាំចូល (លានដុល្លា) | 2013 | | 2014 | | 2015 (៦ខែ) | |
|---|---|---|---|---|---|---|
| | តម្លៃ | ការប្រែប្រួលធៀបនឹងឆ្នាំមុន | តម្លៃ | ការប្រែប្រួលធៀបនឹងឆ្នាំមុន | តម្លៃ | ការប្រែប្រួលធៀបនឹងឆ្នាំមុន |
| យានយន្ត | 543.9 | 25.8 | 645.4 | 21.0 | 398.5 | 77.9 |
| ផលិតផលប្រេង | 1,052.0 | 10.6 | 1,036.6 | 0.5 | 554.7 | 11.0 |

## អតិផរណា

**អតិផរណាបានថយចុះបន្ថែមទៀត បន្ទាប់ពីថយចុះយ៉ាងខ្លាំងនៅត្រឹមឆ្នាំ ២០១៤ ដែលបង្ហាញពីការថយចុះនៃតម្លៃអាហារ និងប្រេង។** អតិផរណាធៀបនឹងឆ្នាំមុន បានថយចុះត្រឹមតែ ០,៨ ភាគរយនៅខែ សីហា ឆ្នាំ ២០១៥ បើធៀបនឹង ១,២ ភាគរយ នៅបំណាច់ឆ្នាំ ២០១៤ នៅពេលដែលមានការថយចុះតម្លៃអាហារ និងប្រេង (រូប ១០)។ រាល់សន្ទស្សន៍រងសំខាន់ៗ នៃអតិផរណា (លើកលែងតែសន្ទស្សន៍រងអាហារ) ដូចជា លំនៅដ្ឋាន ទឹកភ្លៀង និងមធ្យោបាយដឹកជញ្ជូន ស្ថិតក្នុងកម្រិតអវិជ្ជមាន។

រូប ១០ ៖ សន្ទស្សន៍រងនៃមធ្យោបាយដឹកជញ្ជូន លំនៅដ្ឋាន និងទឹកភ្លើង មានកម្រិតអវិជ្ជមាន ខណៈដែលសន្ទស្សន៍រងអាហារថយចុះថែមទៀត ដោយសារការថយចុះនៃតម្លៃអាហារ និងតម្លៃប្រេង ។ ការរួមចំណែកនៃអតិផរណារយៈពេល ១២ ខែ (គិតជា%)




ប្រភព ៖ អាជ្ញាធរ

**អតិផរណារបស់ប្រទេសក្នុងតំបន់ ក៏ថយចុះផងដែរ។** អតិផរណាក្នុងបណ្តាប្រទេសក្នុងតំបន់មួយ ចំនួនដូចជា ថៃ និងសិង្ហបុរី ស្ថិតក្នុងកម្រិតអវិជ្ជមាន នៅពាក់កណ្តាល

[22] ទំនិញនាំចូលសំខាន់មួយទៀតគឺក្រណាត់ដែលប្រើប្រាស់ក្នុងវិស័យកាត់ដេរ ហើយត្រូវបាននាំចេញស្ទើរតែទាំងអស់។

ឆ្នាំ ២០១៥ (រូប ១១)។ ស្ថានភាពនេះបង្ហាញពីការថយចុះជារួមនៃតម្លៃទំនិញ ដែលរួមមាន អាហារ និងប្រេងផងដែរ។ អតិផរណាទាបក្នុងប្រទេសចិន រួមនឹងកំណើនសេដ្ឋកិច្ចទាបជាងមុន ក៏បានជួយកាត់បន្ថយអតិផរណា ក្នុងតំបន់ដែរ។

**រូប ១១ ៖ អតិផរណាក្នុងបណ្តាប្រទេសក្នុងតំបន់បានថយចុះ។** អតិផរណាក្នុងបណ្តាប្រទេសក្នុងតំបន់ (ប្រែប្រួលធៀបនឹងឆ្នាំមុន)




ប្រភព ៖ អាជ្ញាធរ និងស្ថិតិប្រទេសក្នុងតំបន់

**ទន្ទឹមនឹងការជួយបន្ថយអតិផរណា ការថយចុះនៃតម្លៃផលិតផលកសិកម្ម បានប៉ះពាល់ដល់ប្រាក់ចំណូលរបស់អ្នកផលិត និងអ្នកនាំចេញស្រូវនៅកម្ពុជា។** ថ្លៃទំនិញដឹកដល់លើនាវាសម្រាប់ ការនាំចេញអង្ករក្រអូប (តារាង ៦) ដែលមានចំនួនប្រមាណពាក់កណ្តាលនៃការនាំចេញអង្ករសរុប បានរងការប៉ះពាល់ខ្លាំងបំផុត ដោយតម្លៃនេះបានថយចុះចំនួន ៧ ភាគរយនៅខែ មិថុនា ឆ្នាំ ២០១៥ បើធៀបនឹងឆ្នាំមុន។ យ៉ាងណាក៏ដោយ ដោយសារ តែកម្ពុជាជាប្រទេសនាំចូល ការថយចុះយ៉ាងខ្លាំងនាពេលថ្មីៗនេះនៃតម្លៃផលិតផលប្រេង បានផ្តល់លទ្ធភាពឲ្យប្រជាជនកម្ពុជាចំណាយតិច លើការដឹកជញ្ជូន។

## វិស័យរូបិយវត្ថុ



កំណើនរូបិយវត្ថុទូទៅបានបន្តជួយដល់កំណើនផលិតកម្ម។

### ក) រូបិយវត្ថុសរុប អត្រាការប្រាក់ និងអត្រាប្តូរប្រាក់

**កំណើនរូបិយវត្ថុទូទៅ ដែលជួយដល់កំណើនសេដ្ឋកិច្ចនៅតែបន្តកំណើន ទោះបីជាក្នុងកម្រិតយឺតជាងមុនក្តី ខណៈដែលវិស័យធនាគារ និងហិរញ្ញវត្ថុមានការលូតលាស់យ៉ាងលឿន។** ទោះជាមានការរីកលូតលាស់ជាបន្ត កំណើនរូបិយវត្ថុទូទៅបានថយចុះមកត្រឹម ២០,៦ ភាគរយនៅខែ មិថុនា ឆ្នាំ ២០១៥ ធៀបនឹងអត្រាកំណើន ២៩,៩ ភាគរយនៅឆ្នាំ ២០១៤ ហើយកំណើននេះនៅតែត្រូវបាន ជំរុញដោយប្រាក់បញ្ញើជារូបិយប័ណ្ណបរទេស(រូប១២)។

**រូប ១២ ៖ រូបិយវត្ថុទូទៅនៅតែបន្តមានកំណើន ទោះបីជាក្នុងកម្រិតយឺតជាងមុន ហើយត្រូវបានជំរុញដោយកំណើនប្រាក់បញ្ញើជារូបិយប័ណ្ណបរទេស។** ការរួមចំណែកនៃកំណើនរូបិយវត្ថុទូទៅ (% ប្រែប្រួលធៀបនឹងឆ្នាំមុន)




ប្រភព ៖អាជ្ញាធរ

**ទាំងអត្រាការប្រាក់កម្ចី និងប្រាក់បញ្ញើ បានកើនឡើងតិចតួចនៅឆ្នាំ ២០១៤ និងឆមាសទីមួយក្នុង ឆ្នាំ ២០១៥ ដោយសារតែ កំណើនឥណទានក្នុងស្រុកយ៉ាងលឿន។** និន្នាការនេះត្រូវតែពិនិត្យមើល នៅពេលដែលការប្រកួតប្រជែងខ្លាំងក្នុងចំណោមធនាគារ បានធ្វើឲ្យអត្រាប្រាក់កម្ចីជាដុល្លាអាមេរិករយៈពេលខ្លី ថយចុះយ៉ាងខ្លាំង ចាប់ពីឆ្នាំ ២០១២ មក (រូប ១៣)។ ជាលទ្ធផល គម្លាតអត្រាការប្រាក់ គឺជាភាពខុសគ្នារវាងអត្រាប្រាក់កម្ចីជាក់ស្តែង និងអត្រាប្រាក់បញ្ញើ រួមតូចច្រើនក្រាស់ក្រាល។

**រូប ១៣ ៖ ការប្រកួតប្រជែងក្នុងចំណោមធនាគារបានធ្វើឲ្យមានស្ថិរភាពអត្រាការប្រាក់ នៅពេល ដែលមានកំណើនឥណទានយ៉ាងលឿន។** មធ្យមភាគ ១២ ខែនៃអត្រាការប្រាក់ដុល្លាអាមេរិក។




ប្រភព ៖ អាជ្ញាធរ

**រូប ១៤ ៖ ប្រាក់រៀលឡើងថ្លៃបើធៀបនឹងប្រាក់បាត និងប្រាក់ដុង ប៉ុន្តែធ្លាក់ថ្លៃវិញ បើធៀបនឹងប្រាក់ដុល្លា។** អត្រាប្តូរប្រាក់ជាក់ស្តែងនៃប្រាក់រៀល ធៀបនឹងប្រាក់ដុល្លា ប្រាក់បាត និងប្រាក់ដុង។




ប្រភព ៖អាជ្ញាធរកម្ពុជា ធនាគារថៃ និងការិយាល័យស្ថិតិវៀតណាម

**ជាការសំខាន់ត្រូវកត់សម្គាល់ថា ការបន្តការដាក់សម្ពាធលើអត្រាការប្រាក់រយៈពេលខ្លី កំណើនឥណទានយ៉ាងលឿន និងកំណើនតម្រូវការនាំចេញ មិនបានបង្កជាសម្ពាធអតិផរណាក្នុងបរិបទដុល្លារូបនីយកម្មដែលប្រាក់ដុល្លាអាមេរិកកើនតម្លៃនោះទេ។** យ៉ាងណាក៏ដោយ នេះមិនមានន័យថា មិនមានឱកាសសម្រាប់គោលនយោបាយសម្រួលរូបិយវត្ថុទេ ដោយសារតែកំណើនឥណទានក្នុង ស្រុកខ្ពស់ជាបន្តក្នុងរយៈពេលប៉ុន្មានឆ្នាំកន្លងមក។

**អត្រាប្តូរប្រាក់រៀល និងប្រាក់ដុល្លាអាមេរិក នៅតែជាទូទៅមានស្ថិរភាព និងជួយទ្រទ្រង់ដល់ស្ថិរភាពតម្លៃ។** ប្រាក់រៀលធ្លាក់ថ្លៃបន្តិច ដោយមួយដុល្លាប្តូរបាន ៤.០៩៨ រៀល នៅពាក់កណ្តាលឆ្នាំ ២០១៥ ដែលបានជួយកាត់បន្ថយការខាតបង់មួយចំនួន នៃការប្រកួតប្រជែងក្រៅប្រទេស សម្រាប់ផលិតផលកសិកម្ម[23]។ យ៉ាងណាក៏ដោយ ប្រាក់រៀលបានឡើងថ្លៃបន្តិច បើធៀបនឹងប្រាក់បាតថៃ និងប្រាក់ដុងវៀតណាម (រូប ១៤) ក្នុងអំឡុងឆមាសទីមួយក្នុងឆ្នាំ២០១៥។

## ខ) វិស័យធនាគារ



ឥណទានក្នុងស្រុកដែលផ្តល់ដោយវិស័យធនាគារ បានជួយទ្រទ្រង់វិស័យសំណង់ និងអចលនទ្រព្យ។

**ភាពស៊ីជម្រៅហិរញ្ញវត្ថុយ៉ាងលឿនបានបន្តកើតមាន។** កំណើនឥណទានវិស័យឯកជន បានកើនឡើងថែមទៀត រហូតដល់ ២៨,១ ភាគរយ បើធៀបនឹងឆ្នាំមុន ឬ ៨,៦ ពាន់លានដុល្លា ត្រឹមខែ មិថុនា ឆ្នាំ២០១៥ ធៀបនឹង ២៤,៨ ភាគរយនៅបំណាច់ឆ្នាំ ២០១៤ (រូប ១៥)។ កំណើនប្រាក់បញ្ញើវិស័យឯកជន បានថយចុះមកត្រឹម ២១,១ ភាគរយ ឬ ៩,៦ ពាន់លានដុល្លា ត្រឹមខែ មិថុនា ឆ្នាំ ២០១៥ ធៀបនឹង ៣០,៦ ភាគរយ នៅបំណាច់ឆ្នាំ ២០១៤។ អនុបាតឥណទានធៀបនឹងប្រាក់បញ្ញើបានកើនឡើងដល់ ៨៩ ភាគរយ។

[23] ជាពិសេសទំនិញកសិកម្មដែលតម្លៃរបស់វាគិតជារូបិយប័ណ្ណក្នុងស្រុក។

**រូប ១៥ ៖ កំណើនឥណទានវិស័យឯកជន នៅខណៈពេលដែលកំណើនប្រាក់បញ្ញើវិស័យឯកជន បានថយចុះបន្តិច** (%ប្រែប្រួលធៀបនឹងឆ្នាំមុន)




ប្រភព ៖ អាជ្ញាធរកម្ពុជា

**រូប ១៦ ៖ ប្រាក់កម្ចីចំពោះវិស័យសំណង់ និងអចលនទ្រព្យ បានកើនឡើងចាប់តាំងពីអំឡុងពេលក្រោយកើតមានវិបត្តិហិរញ្ញវត្ថុសកល។** ឥណទានក្នុងស្រុកគិតតាមប្រភេទអាជីវកម្ម (ភាគរយសរុប)




ប្រភព ៖ អាជ្ញាធរកម្ពុជា

**ក្នុងរូប ១៦ វិស័យសំណង់ និងអចលនទ្រព្យទទួលបានចំណែកកាន់តែធំនៃឥណទានក្នុងស្រុកសរុប ក្នុងអំឡុងក្រោយវិបត្តិហិរញ្ញវត្ថុសកល។** វិស័យនេះមានចំនួន ១៩ ភាគរយនៃឥណទាន ក្នុងស្រុកសរុបត្រឹមពាក់កណ្ដាលឆ្នាំ ២០១៥ បើធៀបនឹងឆ្នាំ ២០១០ វិស័យនេះមានតែ ១៦ ភាគរយ ប៉ុណ្ណោះ។ យ៉ាងណាក៏ដោយ ចំណែកនេះនៅតែទាបជាងភាគរយខ្ពស់បំផុត ដែលមានចំនួន ២៣ ភាគរយនៅឆ្នាំ ២០០៨ ក្នុងពេលជិតមានវិបត្តិហិរញ្ញវត្ថុសកល នៅពេលដែលមានបញ្ហាពពុះនៃថ្លៃលំនៅដ្ឋាន។ ជាការជួយដល់គោលនយោបាយអង្គរ របស់អាជ្ញាធរកម្ពុជាឆ្នាំ ២០១០ ចំណែកនៃឥណទានក្នុងស្រុកសម្រាប់វិស័យកសិកម្មបានកើនឡើងដល់ ១១,៦ ភាគរយនៅខែ មិថុនា ឆ្នាំ ២០១៥ កើនពី ៦,៨ ភាគរយនៅឆ្នាំ ២០១០។ ចំណែកឥណទានក្នុងស្រុក ដែលផ្ដល់ដល់វិស័យកម្មន្ត សាល បានថយចុះជាបន្តបន្ទាប់ មានចំនួន ៧,៩ ភាគ រយក្នុងខែមិថុនា ឆ្នាំ ២០១៥ ចុះពី ១១,៥ ភាគរយនៅឆ្នាំ ២០១៣។ ស្ថានភាពនេះមិនមែនជាសញ្ញាល្អចំពោះការពន្លឿនវិស័យកម្មន្តសាលដែលជាគោលដៅ ដូចមានចែងក្នុង គោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មឡើយ។ វិស័យលក់រាយ លក់ដុំ សំណង់ កសិកម្ម និងកម្មន្តសាល រួមគ្នា មានចំនួនស្ទើរតែ ៣ ភាគ ៤ នៃឥណទានក្នុងស្រុកសរុប ដែលជំរុញ ដោយសកម្មភាពធុរកិច្ចដ៏ល្អ។

**ការលូតលាស់នៃវិស័យធនាគារបានធ្វើឲ្យ មានការធ្លាក់ចុះនៃទ្រព្យសកម្មបរទេសសរុបរបស់ធនាគារ** ដោយសារតែកំណើនបំណុលបរទេស មានច្រើនជាងកំណើនទ្រព្យសកម្មបរទេស (រូប ១៧)។ ប្រាក់បញ្ញើជារូបិយប័ណ្ណបរទេស ដែលមិនត្រូវរឹតត្បិតដោយធនាគារនៅធនាគារជាតិក៏បានថយចុះផងដែរ។ លំហូរវិនិយោគផ្ទាល់ពីបរទេស បានធ្វើឲ្យមានកំណើនទុនបម្រុងអន្តរជាតិដុលរបស់ធនាគារ ជាតិ ដែលបានកើនឡើងដល់ ៥,២ ពាន់លានដុល្លា (ឬ ៤,១ ខែនៃការនាំចូល) ត្រឹមខែមិថុនា ឆ្នាំ ២០១៥[24] ដែលច្រើនជាងបំណាច់ឆ្នាំ ២០១៤ ដែលមានចំនួន ៤,៦ ពាន់លានដុល្លា។

**រូប ១៧ ៖ ទ្រព្យសកម្មសរុបរបស់ធនាគារកំពុងថយចុះ ដោយកំណើនបំណុលបរទេសមានចំនួន ច្រើនជាងកំណើនទ្រព្យសកម្មបរទេស** (គិតជាលានដុល្លារអាមេរិក)




Note: FC: foreign currency, GIR: gross internatinal reserves, NFA: net foreign assets, and DMB: deposit money banks.
ប្រភព ៖អាជ្ញាធរកម្ពុជា

[24] រូមបញ្ចូលរាល់រូបិយប័ណ្ណទាំងអស់ រួមទាំង ប្រាក់យ័នរបស់ចិនដែលប្រើប្រាស់ជាទុនបម្រុង។

## ទិស័យសារពើពន្ធ



ការសិក្សាក្រៅម៉ោងសាលាអាចជួយបង្កើនពិន្ទុប្រឡង។

**ការពង្រឹងផ្នែកសារពើពន្ធបានបន្ត នៅពេលដែលកំណើនចំណូលខ្ពស់ និងការចំណាយដែល ភាគច្រើនត្រូវបានត្បិតត្បៀត នៅបន្តរឹតត្បិតឱនភាពសារពើពន្ធរួម។** ក្នុងរយៈពេល ៧ ខែដំបូងក្នុងឆ្នាំ ២០១៥ ចំណូលក្នុងស្រុកបានបន្តដំណើរការយ៉ាងល្អ ដោយកើនឡើងប្រមាណ ១៨ ភាគរយ បើធៀប នឹងឆ្នាំមុន។ តាមការព្យាករណ៍ ការប្រមូលចំណូលនឹងកើនដល់ ១៧ ភាគរយ នៃ ផសស (រូប ១៨) ហើយការចំណាយនឹងកើនឡើងបន្តិចដល់ ២១ ភាគរយនៃ ផសស (រូប ២០) ដែលជំរុញដោយ កំណើននៃការចំណាយទៅលើប្រាក់បៀវត្សរ៍ ដែលធ្វើឲ្យមានកំណើនឱនភាពសារពើពន្ធរួមធំជាងមុនបន្តិច (គិតរួមទាំងជំនួយឥតសំណង) ចំនួន ១,៦ ភាគរយនៃ ផសស (រូប ២១)។

### ក) សមាសភាគចំណូល



ការប្រមូលប្រាក់ចំណូលតាមរយៈប្រព័ន្ធធនាគារបានកាត់បន្ថយការបាត់បង់និងបង្កើនតម្លាភាព។

**ការបន្តពង្រឹងការគ្រប់គ្រងចំណូល ធ្វើឲ្យអាចរក្សាកំណើនប្រាក់ចំណូលក្នុងស្រុកខ្ពស់។** ជាលទ្ធផល ប្រាក់ចំណូលក្នុងស្រុកបានកើនដល់ ១៦,៦ ភាគរយនៃ ផសស នៅឆ្នាំ ២០១៤ ធៀបនឹង ឆ្នាំ ២០១៣ ចំនួននេះមានតែ ១៥,១ ភាគរយនៃ ផសស ប៉ុណ្ណោះ ដែលច្រើនជាងកំណើនប្រចាំឆ្នាំជា គោលដៅចំនួន ០,៥ ភាគរយនៃ ផសស នៅក្រោមកម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។ ការណែនាំ និងការអនុវត្តយុទ្ធសាស្ត្រប្រមូលប្រាក់ចំណូល (២០១៤-២០១៨) បានកំណត់ផ្នែកអាទិភាពមួយ ដែលជា ការគ្រប់គ្រងប្រាក់ចំណូល ដោយសារតែសមត្ថភាពបច្ចុប្បន្នរបស់ស្ថាប័នប្រមូលប្រាក់ចំណូល។

**រូប ១៨ ៖ ការប្រមូលប្រាក់ចំណូលក្នុងស្រុកបានកើនឡើងយ៉ាងខ្លាំងនៅឆ្នាំ ២០១៤ និងត្រូវបានព្យាករថានឹងដំណើរការល្អនៅឆ្នាំ ២០១៥។** ប្រាក់ចំណូលទូទៅរបស់រដ្ឋាភិបាល (ភាគរយនៃ ផសស)




b=ថវិកា p=ការប៉ាន់ស្មាន

ប្រភព ៖ អាជ្ញាធរកម្ពុជា និងការប៉ាន់ស្មានរបស់បុគ្គលិកធនាគារ

**រចនាសម្ព័ន្ធរួមនៃប្រាក់ចំណូលក្នុងស្រុក បានប្រែប្រួលយ៉ាងខ្លាំងដោយមានកំណើនយ៉ាងលឿន នៃចំណែកពន្ធផ្ទាល់ទោះបីជាមានមូលដ្ឋានទាបក៏ដោយ។** ចំណែកនៃពន្ធផ្ទាល់ក្នុងប្រាក់ចំណូលក្នុង ស្រុក បានកើនឡើងលើសទ្វេដងក្នុងអំឡុងមួយទសវត្សរ៍កន្លងមក[25] ដោយបានកើនឡើងរហូតដល់ ១៧,៥ ភាគរយនៅឆ្នាំ ២០១៤ កើនឡើងពី ៧,១ ភាគរយនៅឆ្នាំ ២០០៤ ទោះបីជាមិនមានការផ្លាស់ប្តូរបទប្បញ្ញត្តិ ស្តីពីការអនុគ្រោះពន្ធនៅក្រោមច្បាប់ស្តីពីការវិនិយោគក៏ដោយ (រូប ១៩)។ ទោះបីជាការប្រមូលពន្ធផ្ទាល់ នៅតែមានកម្រិតទាបប្រមាណ ៣ ភាគរយនៃ ផសស ធៀបនឹង ៣,៨ ភាគរយនៃផសស ដែលប្រមូលបានក្នុងប្រទេសឡាវ និង ៥,៦ ភាគរយនៃ ផសស ក្នុងប្រទេសឥណ្ឌូនេស៊ី និង ៧,៤ ភាគរយនៃ ផសស នៅប្រទេសថៃ ប៉ុន្តែការកែលម្អយ៉ាងលឿនបានបង្ហាញពីវឌ្ឍនភាពល្អប្រសើរក្នុងការគ្រប់គ្រងពន្ធផ្ទាល់[26]។ ទោះនៅតែជាចំណែកធំជាងគេបង្អស់ ចំណែកនៃពន្ធប្រយោល បានកើនឡើងបន្តិចប៉ុណ្ណោះ ទៅដល់ ៤៧,៥ ភាគរយ កើនពី ៤០,៥ ភាគរយក្នុងរយៈពេលដូចគ្នានេះ រីឯ ចំណែកនៃពន្ធពាណិជ្ជកម្មបានថយចុះមកត្រឹម ១៦,៣ ភាគរយ ចុះពី ២៣,២ ភាគរយ[27]។ កិច្ចខិតខំប្រឹងប្រែងរបស់អាជ្ញាធរកម្ពុជា ក្នុងការផ្លាស់ប្តូររចនាសម្ព័ន្ធពន្ធពីមុន ដែលពឹងផ្អែកខ្លាំងលើពន្ធពាណិជ្ជកម្ម ទៅជាប្រព័ន្ធពន្ធទំនើប ដោយផ្អែកលើពន្ធផ្ទាល់ និងពន្ធក្នុងស្រុក នឹងជួយរក្សាការប្រមូលពន្ធ ខណៈពេលដែលកម្ពុជាកំពុងព្យាយាមសម្រេចគោលបំណងផ្សេងៗនៃគោលនយោបាយពាណិជ្ជកម្មសេរី ដូចជា គោលបំណងដែលមានចែងក្នុងសហគមន៍សេដ្ឋកិច្ចអាស៊ានជាដើម។

**ប្រអប់ ៣ ៖ កម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (PFMRP)**
**ការអនុវត្តប្រព័ន្ធគ្រប់គ្រងព័ត៌មានវិទ្យាហិរញ្ញវត្ថុ (FMIS)**

ប្រព័ន្ធគ្រប់គ្រងព័ត៌មានវិទ្យាហិរញ្ញវត្ថុគឺជាឧបករណ៍ថវិកា គណនេយ្យ និងរាយការណ៍ទំនើប ដែលផ្តល់ដំណោះស្រាយស្វ័យប្រវត្តិជាច្រើនដែលអាចឲ្យអាជ្ញាធរកម្ពុជារៀបចំផែនការ អនុវត្ត និងពិនិត្យតាមដានថវិកា។ ដំណោះស្រាយនេះអាចជួយដល់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការផ្តោតអាទិភាព អនុវត្ត និងរាយការណ៍ពីចំណាយ និងការគ្រប់គ្រង ការប្រើប្រាស់ និងការរាយការណ៍ពីប្រាក់ចំណូល។

**"ការអនុវត្តដំណាក់កាលទី ១"** នៃប្រព័ន្ធគ្រប់គ្រងព័ត៌មានហិរញ្ញវត្ថុ ត្រូវបានប្រកាសដោយជោគជ័យនៅថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ២០១៥។ នេះសមិទ្ធផលនៃដំណាក់កាលអនុវត្តសំខាន់ទីមួយ ដោយមានការអនុវត្ត*កម្មវិធីបញ្ជីធំ និងវិភាជថវិកា* សម្រាប់អគ្គនាយកដ្ឋានសំខាន់ៗជាច្រើនក្នុងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ ជាលទ្ធផល ការផ្លាស់ប្តូរថវិកាក្នុងរយៈពេលមួយឆ្នាំ ដូចជា ការផ្ទេរ និងការផ្លាស់ប្តូរក្នុងរយៈពេលមួយឆ្នាំផ្សេងទៀត នឹងត្រូវបានអនុវត្តដោយផ្ទាល់ក្នុងប្រព័ន្ធគ្រប់គ្រងព័ត៌មានហិរញ្ញវត្ថុ។

**"ការអនុវត្តដំណាក់កាលទី ២"** ដែលជាដំណាក់កាលដ៏សំខាន់ទីពីរ សម្រាប់ថ្ងៃទី ២១ ខែ តុលា ឆ្នាំ ២០១៥ ពាក់ព័ន្ធនឹង*គណនីត្រូវបង់ ការបញ្ជាទិញ គណនីត្រូវទទួល និងការគ្រប់គ្រងសាច់ប្រាក់*។ បន្ទាប់ពីដំណាក់កាលទីពីរនេះ មុខងារស្នូលនៃប្រព័ន្ធគ្រប់គ្រងព័ត៌មានហិរញ្ញវត្ថុដែលពាក់ព័ន្ធនឹងការប្រើប្រាស់ថវិកានឹងត្រូវបានអនុវត្ត។ នៅដំណាក់កាលនេះ អ្នកប្រើប្រាស់ចុងក្រោយក្នុងនាយកដ្ឋានពាក់ព័ន្ធនឹងចាប់ផ្តើមប្រើប្រាស់ប្រព័ន្ធនេះសម្រាប់ការងារប្រចាំថ្ងៃ ហើយការកែសម្រួលសំខាន់ៗលើវិធីបំពេញដំណើរការការងាររបស់ពួកគេនឹងត្រូវបានអនុវត្ត។

**តើប្រព័ន្ធគ្រប់គ្រងព័ត៌មានហិរញ្ញវត្ថុផ្តល់ផលប្រយោជន៍អ្វីខ្លះ?**
ប្រព័ន្ធគ្រប់គ្រងព័ត៌មានហិរញ្ញវត្ថុជួយដល់ការសម្រួល និងដំណើរការ ឬកត់ត្រាការទូទាត់ ការប្រមូលប្រាក់ចំណូល និងការទទួលប្រាក់ចំណូល និងការរៀបចំគណនេយ្យ និងការរាយការណ៍ពីរតនាគារជាតិ និងរតនាគារខេត្ត។ ក្រសួងដែលធ្វើការចំណាយនៅថ្នាក់ជាតិ និងមន្ទីរដែលធ្វើការចំណាយនៅតាមខេត្ត នឹងដាក់សំណើការទូទាត់របស់ខ្លួន និងការទទួលបានប្រាក់ចំណូលទៅរតនាគារជាតិ ឬរតនាគារខេត្តពាក់ព័ន្ធដើម្បីដំណើរការ។ ក្រសួងមន្ទីរនឹងមានភាពងាយស្រួល និងទាន់ពេលវេលាក្នុងការទទួលបានព័ត៌មានហិរញ្ញវត្ថុ ដែលពួកគេនឹងអាចបង្កើតជារបាយការណ៍ហិរញ្ញវត្ថុ និងគ្រប់គ្រង។ ប្រព័ន្ធនេះនឹងផ្តល់កម្មវិធីល្អ និងព័ត៌មានហិរញ្ញវត្ថុដល់ប្រធានកម្មវិធី ដែលអាចឲ្យពួកគេប្រើប្រាស់ ឬបែងចែកធនធានកាន់តែមានប្រសិទ្ធភាព ប្រសិទ្ធផល និងតម្លាភាព និងសម្របសម្រួលការទទួលមូលនិធិឲ្យបានទាន់ពេលវេលា ដូចជា ការិយាល័យអប់រំស្រុក និងមន្ទីរអប់រំខេត្ត និងមណ្ឌលសុខភាព និងមន្ទីរពេទ្យ។ ជារួម ប្រព័ន្ធគ្រប់គ្រងព័ត៌មានហិរញ្ញវត្ថុនឹងផ្តល់ផល ប្រយោជន៍ផ្ទាល់តាមរយៈការកែលម្អវិធីដែលរដ្ឋាភិបាលពិនិត្យតាមដាន កែសម្រួល និងរាយការណ៍ពីថវិកាតាមឆ្នាំ។

ប្រភព ៖ អាជ្ញាធរកម្ពុជា និងបុគ្គលិកធនាគារពិភពលោក

[25] ក្នុងប្រព័ន្ធពន្ធកម្ពុជា ពន្ធផ្ទាល់រួមមាន ពន្ធប្រាក់ចំណូលក្រុមហ៊ុន (ពន្ធប្រាក់ចំណេញ) ពន្ធប្រាក់បៀវត្សរ៍ និងពន្ធលើអចលនទ្រព្យ។

[26] ឆ្នាំសារពើពន្ធ 2012/13 សម្រាប់ប្រទេសឡាវ ឆ្នាំសារពើពន្ធ 2013 សម្រាប់ប្រទេសឥណ្ឌូណេស៊ី ឆ្នាំសារពើពន្ធ 2013/14 សម្រាប់ប្រទេសថៃ។ សូមមើល ការពិគ្រោះយោបល់ មាត្រា IV IMF ឆ្នាំ ២០១៥។ របាយការណ៍របស់បុគ្គលិកសម្រាប់ ឡាវ ឥណ្ឌូណេស៊ី និងថៃ។

[27] ពន្ធប្រយោលរួមមាន ពន្ធផលចំណូល ពន្ធតម្លៃបន្ថែម និងពន្ធអាករ។ ពន្ធពាណិជ្ជកម្មរួមមាន ពន្ធនាំចូល និងពន្ធនាំចេញ។

**រូប ១៩ ៖ ការប្រមូលពន្ធផ្ទាល់មានភាពប្រសើរច្រើន ទោះបីជាចេញពីមូលដ្ឋានទាបក៏ដោយ ចំណែកការប្រមូលពន្ធពាណិជ្ជកម្មបានថយចុះក្នុងអំឡុងទសវត្សរ៍កន្លងទៅ**
(ភាគរយប្រាក់ចំណូលក្នុង ស្រុកសរុប)



ប្រភព ៖ អាជ្ញាធរកម្ពុជា

## ខ) សមាសភាគចំណាយ



ការសិក្សារៀនសូត្រដើម្បីប្រកួតប្រជែងថ្នាក់តំបន់ និងសាកល ជាការសំខាន់។

**ទោះបីជាការចំណាយសរុបរឹតត្បិត កំណើនការចំណាយលើប្រាក់បៀវត្សរ៍យ៉ាងលឿន អាចប៉ះពាល់ដល់កិច្ចខិតខំប្រឹងប្រែងពង្រឹកសារពើពន្ធ។** បន្ទាប់ពីការតំឡើងប្រាក់បៀវត្សរ៍គោល ប្រាក់បៀវត្សរ៍បានកើនឡើង ៦,៤ ភាគរយនៃ ផសស ក្នុងឆ្នាំ ២០១៥ បើធៀបនឹងឆ្នាំ ២០១៤ ភាគរយ នេះមានតែ ៥,៥ ភាគរយប៉ុណ្ណោះ។ ប្រាក់បៀវត្សរ៍នឹងនៅតែបន្តកើនឡើងដោយសារតែប្រាក់បៀវត្សរ៍គោលអប្បបរមា ត្រូវបានគ្រោងថានឹងបង្កើនជាបន្តបន្ទាប់ ហើយនឹងកើនឡើងដល់ ១ លានរៀល (ស្មើនឹង ២៥០ ដុល្លាអាមេរិក) នៅឆ្នាំ ២០១៨[28]។ ដូច្នេះ ជាការសំខាន់ត្រូវធានានូវលទ្ធភាពចំណាយទៅលើប្រាក់បៀវត្សរ៍ និងភ្ជាប់ការចំណាយនេះទៅការកែលម្អការគ្រប់គ្រងធនធានមនុស្ស និងការផ្តល់សេវាកម្មសាធារណ:។ ការផ្តួចផ្តើមកំណែទម្រង់ រដ្ឋបាលស៊ីវិល ដែលមានបំណងដោះស្រាយការចំណាយទៅ លើការងារក្នុងវិស័យសាធារណ: តាមរយ:ការកាត់បន្ថយចំនួន និងការកែរចនាសម្ព័ន្ធ រួមទាំងការ គ្រប់គ្រងគ្រឹះស្ថាន ដែលបច្ចុប្បន្ន កំពុងអនុវត្តគឺជាផ្នែកមួយនៃការប្រឹងប្រែងកែលម្អការបំពេញមុខងារការងារ ក្នុងវិស័យសាធារណ: ដែលជាវិធានការមួយដ៏ត្រឹមត្រូវ។ បទពិសោធន៍អន្តរជាតិបង្ហាញថា កត្តាស្ថាប័ន ដូចតទៅនេះ អាចកែលម្អការអនុវត្តការងារក្នុងវិស័យសាធារណ: ដែលរួមមាន (១) កំណត់ តួនាទី ការទទួលខុសត្រូវ និងគណនីយភាព ច្បាស់លាស់ (២) ការអនុវត្តផ្នែកគ្រប់គ្រងធនធាន មនុស្សបានសមស្រប (៣) វិស័យអប់រំ និងសុខាភិបាល ដែលមានភស្តុតាងបង្ហាញថា កំណើនប្រតិបត្តិ ការអាចជួយប្រសិទ្ធផល[29]។

ម្យ៉ាងវិញទៀត ចំណាយមូលធនបានថយចុះ ដោយសារតែការថយចុះ នៃសមាសភាគហិរញ្ញប្បទានក្រៅប្រទេស ចាប់តាំងពីការបញ្ចប់គោលនយោបាយពង្រឹកសារពើពន្ធ ដែលត្រូវបានអនុវត្ត សំដៅកាត់បន្ថយផលអវិជ្ជមាននៃវិបត្តិហិរញ្ញវត្ថុសកល។ ស្ថានភាពនេះអាចបង្កជាបញ្ហាប្រឈមនៅថ្ងៃខាងមុខ ព្រោះថា ចាំបាច់ត្រូវមានការកែលម្អហេដ្ឋារចនាសម្ព័ន្ធ ដើម្បីបង្កើនការប្រកួតប្រជែងរបស់កម្ពុជា និងសម្រេចបានការអភិវឌ្ឍសេដ្ឋកិច្ចដែលកាន់តែមានតុល្យភាព។

**គួរកត់សម្គាល់ថា កម្ពុជាបានខិតខំកែលម្អប្រសិទ្ធភាព និងលទ្ធផលនៃចំណាយ។** ឧទាហរណ៍ ការងារនេះត្រូវបានបង្ហាញឲ្យឃើញតាមរយ: ការអនុវត្តកម្មវិធីសាកល្បងការរៀបចំថវិកានៅក្រសួងសំខាន់ៗ ចំនួន ១០[30]

[28] កំពុងអនុវត្តកំណែទម្រង់ទូលំទូលាយ និងជាបណ្តើរៗនៃកំណែទម្រង់រដ្ឋបាលស៊ីវិលដែលមានគោលដៅទប់ការចំណាយទៅលើ កម្លាំងពលកម្មក្នុងវិស័យសាធារណ: តាមរយ:ការកាត់បន្ថយចំនួន និងកែរចនាសម្ព័ន្ធ រួមទាំងការគ្រប់ គ្រងគ្រឹះស្ថាន (អនុក្រឹត ១១៩ ថ្ងៃទី ៧ ខែកញ្ញា ឆ្នាំ ២០១៥)

[29] ការកែលម្អប្រសិទ្ធផលវិស័យសាធារណ:៖ បញ្ហាប្រឈម និងឱកាស ដោយ Teresa Curristine និងអ្នកផ្សេងទៀត OECD Journal on Budgeting Volume 7 – No. 1, 2007

[30] ក្រសួងទាំងនោះរួមមាន ក្រសួងអប់រំ យុវជន និងកីឡា ក្រសួងសុខាភិបាល ក្រសួងអភិវឌ្ឍន៍ជនបទ ក្រសួងកសិកម្ម ក្រសួងកិច្ចការនារី ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវ: ក្រសួងរៀបចំដែនដី នគររូបនីយកម្ម និងសំណង់

និង ការប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងព័ត៌មានវិទ្យាហិរញ្ញវត្ថុ (FMIS) សម្រាប់ការកត់ត្រា និងរាយការណ៍ឲ្យទាន់ពេលវេលា និងគ្រប់ជ្រុងជ្រោយពីប្រសិទ្ធភាព និងលទ្ធផលថវិការដ្ឋាភិបាល ដោយផ្អែកលើបទដ្ឋានគណនេយ្យវិស័យសាធារណៈអន្តរជាតិ ក្នុងចំណោមវិធានការនានាក្រោម កម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (PFMRP) ។ សូមមើលប្រអប់ ៣ ដើម្បីស្វែង យល់ពីសមិទ្ធភាពនៃកម្មវិធីនេះ។ ប្រសិទ្ធភាពចំណាយ នឹងជួយដល់កិច្ចខិតខំប្រឹងប្រែងក្នុងការពង្រីកការវិនិយោគមូលធន ដែលទទួលបានហិរញ្ញវត្ថុពីក្នុងស្រុក។

**រូប ២០ ៖ ការវិនិយោគសាធារណៈដែលទទួលបានហិរញ្ញប្បទានពីដៃគូអភិវឌ្ឍន៍ កំពុងថយចុះ ចំណែកការចំណាយលើប្រាក់បៀវត្សរ៍កំពុងកើនឡើង។** ចំណាយទូទៅរបស់រដ្ឋាភិបាល (ភាគរយនៃ ផសស)។




b=ថវិកា p=ការប៉ាន់ស្មាន

ប្រភព ៖ អាជ្ញាធរកម្ពុជា

## គ) តុល្យភាពសារពើពន្ធ

**ទោះជាការប្រមូលប្រាក់ចំណូល ដែលមានភាពប្រសើរនៅតែបន្តមាន គេឃើញមានកំណើនឱនភាពសារពើពន្ធបន្តិច** (មិនរាប់បញ្ចូលជំនួយឥតសំណង) ចំនួន ៣,៧ ភាគរយនៃ ផសស ក្នុងឆ្នាំ ២០១៥ ធៀបនឹងចំនួន ៣,៥ ភាគរយនៃ ផសស ក្នុងឆ្នាំ ២០១៤ ដោយសារកំណើនចំណាយចរន្ត។ រួមទាំងជំនួយឥតសំណង ឱនភាពសារពើពន្ធត្រូវបានព្យាករថានឹងកើនឡើងដល់ ១,៦ ភាគរយនៃផសស នៅ ឆ្នាំ ២០១៥ បើធៀបនឹងឆ្នាំ ២០១៤ ចំនួននេះមានតែ ០,៣ ភាគរយនៃ ផសស ប៉ុណ្ណោះ។ ឱនភាពសារពើពន្ធបន្តទទួលបានហិរញ្ញប្បទានពីមូលនិធិក្រៅប្រទេស។

ទន្ទឹមនឹងនេះ ប្រាក់បញ្ញើរដ្ឋាភិបាលបានកើនឡើង ៨,៧ ភាគរយនៃ ផសស ឬ ១,៤ ពាន់លានដុល្លានៅបំណាច់ខែ មិថុនា ឆ្នាំ ២០១៥។ ការកើនឡើងនៃប្រាក់បញ្ញើរដ្ឋាភិបាល បានផ្តល់ការការពារដល់រដ្ឋាភិបាលក្នុងពេលមានវិបត្តិ។ ឧទាហរណ៍ កម្ពុជាអនុវត្តការជំរុញសារពើពន្ធ ដែលមានប្រមាណ ២ ភាគរយនៃ ផសស ដើម្បីកាត់បន្ថយផលប៉ះពាល់អវិជ្ជមាន នៃវិបត្តិហិរញ្ញវត្ថុសកល។ គោលនយោបាយសារពើពន្ធ គឺជាឧបករណ៍គោលនយោបាយតែមួយគត់ ដើម្បីរក្សាស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និងទប់ ទល់នឹងការប៉ះពាល់ នៅពេលដែលគោលនយោបាយរូបិយវត្ថុក្នុងប្រទេស មិនមានភាពបត់បែន ដោយសារតែដុល្លារូបនីយកម្មខ្ពស់។

**រូប ២១ ៖ ឱនភាពសារពើពន្ធមានភាពប្រសើរឡើងជាបន្តបន្ទាប់ ដោយសារការខិតខំពង្រឹងសារពើពន្ធក្រោយការបញ្ចប់ការជំរុញសារពើពន្ធ ដែលសំដៅកាត់បន្ថយផលប៉ះពាល់អវិជ្ជមាននៃវិបត្តិហិរញ្ញវត្ថុសកល។** ឱនភាពសារពើពន្ធរបស់រដ្ឋាភិបាល (ភាគរយនៃ ផសស)។




b=ថវិកា p=ការប៉ាន់ស្មាន

ប្រភព ៖ អាជ្ញាធរកម្ពុជា

**ការវិភាគរួមគ្នាចុងក្រោយ ដោយធនាគារពិភពលោក និងមូលនិធិរូបិយវត្ថុអន្តរជាតិ(IMF) អំពីនិរន្តរភាពនៃបំណុល (DSA) បង្ហាញថា ចំណាត់ថ្នាក់ភាពតានតឹងផ្នែកបំណុលរបស់កម្ពុជានៅតែមាន កម្រិតទាបដែល** ដោយសូចនាករស្តីពី បន្ទុកបំណុលទាំងអស់ត្រូវបានព្យាករថានៅតែស្ថិតនៅក្រោមកម្រិតកំណត់។ លទ្ធផល

ក្រសួងមុខងារសាធារណៈ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ សម្រាប់ព័ត៌មានបន្ថែម សូមមើល ៖ www.pfm.org.gov។

ក៏បានបង្ហាញដែរថា និរន្តរភាពបំណុលនៅតែងាយរងគ្រោះដោយសារ កំណើន ការនាំចេញ និងវិបត្តិសារពើពន្ធ ដែលត្រូវមានការធ្វើកំណែទម្រង់រចនាសម្ព័ន្ធដើម្បីបង្កើនភាពរឹងមាំ នៃសេដ្ឋកិច្ចចំពោះវិបត្តិក្រៅប្រទេស និងការប្រមូលប្រាក់ចំណូលក្នុងស្រុក។ នៅបំណាច់ឆ្នាំ ២០១៤ បរិមាណបំណុលបរទេសរបស់កម្ពុជាដែលបានប៉ាន់ស្មាន រួមទាំងបំណុលកកស្ទះដែលមិនទាន់បានបង់តាមកាលកំណត់ មានចំនួន ៥,៥ ពាន់លានដុល្លា ឬ ៣៣ ភាគរយនៃ ផសស។

## គ. សារគន្លឹះ និងអនុសាសន៍

**ចាំបាច់ត្រូវពង្រឹងការប្រកួតប្រជែងក្រៅប្រទេស។** នៅក្នុងបរិបទនៃការកើនឡើងតម្លៃប្រាក់ដុល្លា អាមេរិក (និងប្រាក់រៀល) ធៀបនឹងប្រាក់អឺរ៉ូ និងប្រាក់នៅប្រទេសជិតខាង និងកំណើននៃការ ប្រកួតប្រជែង កម្ពុជាត្រូវដោះស្រាយបញ្ហាប្រឈមសំខាន់ៗ ដែលប៉ះពាល់ដល់កំណើនផលិតភាព និងការចំណាយលើការនាំចេញ។ កម្លាំងពលកម្មដែលមានការបណ្តុះបណ្តាល និងជំនាញល្អ ប្រាកដជាអាចជួយដល់ការប្រកួតប្រជែងក្នុងរយៈពេលខ្លី។ ការផ្តួចផ្តើមនាពេលថ្មីៗក្នុងការបង្កើតវិទ្យាស្ថានបណ្តុះបណ្តាលទ្រង់ទ្រាយធំ ផ្នែកកាត់ដេរសម្លៀកបំពាក់ គឺជាការងារដ៏ល្អ។ លើសពីនេះទៀត ការកែលម្អបន្ថែមចំពោះបរិយាកាសធុរៈកិច្ច តាមរយៈការធ្វើសាមញ្ញកម្ម និងស្វ័យប្រវត្តិកម្មដំណើរការចុះបញ្ជីអាជីវកម្ម ការសម្របសម្រួលពាណិជ្ជកម្ម និងការពង្រឹងច្បាប់វិនិយោគ នឹងជួយសំរួចភាពប្រកួតប្រជែងរបស់កម្ពុជាលើគ្រប់វិស័យ។ ចុងក្រោយ ជាការសំខាន់ត្រូវគាំទ្រការធ្វើពិពិធកម្មក្នុង វិស័យកម្មន្តសាល ដូចកំណត់នៅក្នុងគោលនយោបាយអភិវឌ្ឍន៍ វិស័យឧស្សាហកម្ម ហើយនៅពេលជាមួយគ្នានោះ ត្រូវរៀបចំកម្ពុជាឲ្យទទួលបានផលប្រយោជន៍ពីឱកាសនានា ដែលលេចឡើងក្នុងរយៈពេលមធ្យមនៃទីផ្សារ និងមូលដ្ឋានផលិតកម្មតែមួយ ដែលត្រូវបានកំណត់នៅក្នុងសហគមន៍សេដ្ឋកិច្ចអាស៊ាន។ ក្នុងរយៈពេលមធ្យមរហូតដល់រយៈពេលវែង ការដោះស្រាយបញ្ហានៃការមិនអាចទុកចិត្តបាន និងការចំណាយខ្ពស់លើអគ្គិសនី ដោយត្រូវមានការផ្គត់ផ្គង់អគ្គិសនីបន្ថែមពីរោងចក្រវារីអគ្គីសនី និងរោងចក្រដើរដោយថាមពលធ្យូងថ្មី គឺជាចំណុចអាទិភាព។ **បទពិសោធន៍អន្តរជាតិ** ភ្ជាប់បរិយាកាសធុរៈកិច្ចរឹងមាំទៅនឹងលក្ខណៈមួយចំនួន ដែលរួមមាន (១) ក្របខណ្ឌច្បាប់ និងបទបញ្ញត្តិ ដែលអាចព្យាករណ៍បាន និងផ្អែកលើនិយាមអន្តរជាតិ ដែលជាផ្នែកដ៏សំខាន់ (២) បរិយាកាសវិនិយោគ ល្អ និងការសម្របសម្រួលពាណិជ្ជកម្ម និងភស្តុភារ ដែលជាកត្តាកំណត់សំខាន់នៃការប្រកួតប្រជែង[31]។

**ការជំរុញការវិនិយោគសាធារណៈ ដែលទទួលបានហិរញ្ញវត្ថុពីក្នុងស្រុកជាកិច្ចការសំខាន់ចាំបាច់។** ការជំរុញនេះ ត្រូវធ្វើឡើងដើម្បីប៉ះប៉ូវចំពោះការថយចុះនៃការវិនិយោគទុន ដែលទទួលបានហិរញ្ញវត្ថុពីដៃគូអភិវឌ្ឍន៍ ដោយសារតែកម្ពុជានឹងក្លាយជាប្រទេសដែលមានចំណូលមធ្យមកម្រិតទាប។ សំខាន់បំផុត កិច្ចការនេះតម្រូវឲ្យមានប្រាក់ចំណូលក្នុងស្រុកបន្ថែម។ ដោយសារមានកំណើននៃការប្រមូលប្រាក់ចំណូល ការផ្តល់មូលនិធិដល់ គម្រោងវិនិយោគសាធារណៈជាអាទិភាពអាចធ្វើទៅបាន និងអាចមានលក្ខណៈសមស្របក្នុងរយៈពេលខ្លី។ លើសពីនេះទៀត ការបង្កើនការវិនិយោគដែលទទួលបានហិរញ្ញវត្ថុពីក្នុងស្រុក ឲ្យមានប្រសិទ្ធភាពទាមទារឲ្យមានវិធានការ និងសមត្ថភាពសមស្រប។ ដូច្នេះ ក្នុងរយៈពេលខ្លីរហូតដល់រយៈពេលមធ្យម ត្រូវមានការពង្រឹងវិធាន និងបទប្បញ្ញត្តិ ដូចជាផ្នែកថវិកា លទ្ធកម្ម និងសវនកម្ម ដែលគ្របដណ្តប់លើ

[31] យុទ្ធសាស្រ្តសមាហរណកម្មពាណិជ្ជកម្មកម្ពុជា ២០១៤ ដល់ ២០១៨ ដោយរាជរដ្ឋាភិបាលកម្ពុជា ធនាគារពិភពលោក UNDP និងធនាគារអភិវឌ្ឍន៍អាស៊ី។

ការគ្រប់គ្រងគម្រោងវិនិយោគទុនក្នុងស្រុក ដោយផ្តោតលើការកែលម្អការពិនិត្យលទ្ធភាព ការអនុវត្ត និងការវាយតម្លៃ ដើម្បីសម្រេចបានតម្លៃនៃប្រាក់ដូចមានកំណត់នៅក្នុងកម្មវិធីកំណែទម្រង់ហិរញ្ញវត្ថុ។ ម្យ៉ាងទៀតក៏ត្រូវមានការពង្រឹងសមត្ថភាព និងគុណភាពស្ថាប័ន ដើម្បីគ្រប់គ្រងការវិនិយោគសាធារណៈឲ្យកាន់តែប្រសើរ។ នេះជាកិច្ចការដែលត្រូវចំណាយពេលយូរដែល ត្រូវមានការប្តេជ្ញាចិត្តខ្ពស់ និងការដឹកនាំនយោបាយ។ **បទពិសោធន៍អន្តរជាតិ** បង្ហាញថា សំខាន់ត្រូវគោរពចំពោះគោលការណ៍ទូលំទូលាយទាំងបួន ដើម្បីបង្កើនការវិនិយោគសាធារណៈ ឲ្យ បានជោគជ័យ (១) ការសម្រេច "ប្រសិទ្ធភាពក្នុងការបែងចែក" ដោយបង្វែរធនធានវិស័យដែលមាន ផលិតភាពតិចទៅវិស័យដែលមានផលិតភាពខ្ពស់ជាង (២) មានមូលដ្ឋានក្នុងក្របខណ្ឌសារពើពន្ធ ម៉ាក្រូដ៏ល្អ ដើម្បីចៀសវាងការឡើងថ្លៃពិតដោយសារការកើនឡើងនៃអត្រាប្តូរប្រាក់ ពីកំណើននៃការចំណាយវិនិយោគ (៣) ប្រព័ន្ធគ្រប់ គ្រងការវិនិយោគសាធារណៈត្រូវមានភាពសមស្រប និង (៤) វិស័យសំណង់ត្រូវមានលទ្ធភាពឆ្លើយតប និងគ្រប់តាមតម្រូវការដែលកើនឡើង[32]។

**ការបន្តពង្រឹងការត្រួតពិនិត្យ និងសម្របសម្រួល ដើម្បីរក្សាស្ថិរភាពវិស័យធនាគារ និងសំណង់ដែលកំពុងមានកំណើនលឿន ជាការសំខាន់។** ទោះជាកម្ពុជាអាចនឹងរួចផុតពីការប្រែប្រួលផ្នែកហិរញ្ញវត្ថុ ដោយសារតែទីផ្សារមូលធនតូច លំហូរធនាគារ ក្នុងទម្រង់ជាប្រាក់បញ្ញើជារូបិយប័ណ្ណបរទេស នៅតែមានភាពរសើបចំពោះការយល់ឃើញ និងទំនុកចិត្តរបស់សាធារណជន[33]។ វិធានការផ្សេងទៀតដើម្បី ពង្រឹងការគ្រប់គ្រងប្រព័ន្ធធនាគារតាមរយៈការពង្រឹងផ្នែកគណនេយ្យ និងសវនកម្ម រួមជាមួយនឹងការមានទិន្នន័យគ្រប់គ្រាន់ និងត្រឹមត្រូវ គឺជាចំណុចអាទិភាព។ សំខាន់ជាងនេះទៀត ការបង្កើតក្របខ័ណ្ឌការងារ សម្រាប់គ្រប់គ្រងវិបត្តិដែលគាំទ្រដោយការសម្របសម្រួលអន្តរស្ថាប័ន គឺជាកិច្ចការសំខាន់ជាមូលដ្ឋាន។ ទៅអនាគត ការយល់ដឹងច្បាស់លាស់អំពីច្រកបញ្ជូនលទ្ធភាព នៃការប្រែប្រួលពីខាងក្រៅ រួមទាំង ការធ្លាក់ចុះនៃសេដ្ឋកិច្ចចិន ដែលមានឥទ្ធិពលមកលើសេដ្ឋកិច្ចកម្ពុជា និងទំនាក់ទំនងរវាងវិស័យហិរញ្ញវត្ថុ និងវិស័យផលិតកម្ម នឹងជួយពង្រឹងភាពរឹងមាំរបស់សេដ្ឋកិច្ចចំពោះវិបត្តិនានា។ កិច្ចខិតខំនាពេលថ្មីនេះក្នុង ការកែលម្អការសម្របសម្រួលរវាងស្ថាប័នសាធារណៈដែលគ្រប់គ្រងទៅលើវិស័យធនាគារ នគរូបនីយកម្ម វិស័យសំណង់ និងអចលនទ្រព្យ ដោយមានកិច្ចសហការពីក្រុមហ៊ុនសំណង់ធំៗ និង អ្នកអភិវឌ្ឍន៍វិស័យអចលនទ្រព្យ គឺជាជំហានដំបូងដ៏ល្អមួយ។ ការធ្វើបែបនេះនឹងជួយបញ្ចៀសបញ្ហាពពុះ ដែលអាចកើតមានពីការអភិវឌ្ឍនៃវិស័យសំណង់ និងអចលនទ្រព្យ។ បទពិសោធន៍ អន្តរជាតិបង្ហាញថា ត្រូវមានក្របខណ្ឌស្តង់ដាអប្បបរមា សម្រាប់ការអនុវត្តការត្រួតពិនិត្យធនាគារ ឲ្យបានល្អ ដែលអាចអនុវត្តជាទូទៅ ដែលត្រូវមាន (១) អំណាចត្រួតពិនិត្យដែលមានកំណត់យ៉ាងច្បាស់ (២) ការទទួលខុសត្រូវ និងគណនីយភាពក្នុងចំណោមអាជ្ញាធរត្រួតពិនិត្យ និង (៣) បទដ្ឋានប្រុងប្រយ័ត្នត្រឹមត្រូវ។ បុរេលក្ខខណ្ឌ សម្រាប់ការត្រួតពិនិត្យធនាគារឲ្យមានប្រសិទ្ធភាពរួមមាន (១) ក្របខណ្ឌច្បាស់លាស់សម្រាប់ការបង្កើតគោលនយោបាយស្ថិរភាពហិរញ្ញវត្ថុ (២) ក្របខណ្ឌច្បាស់ លាស់សម្រាប់ដោះស្រាយវិបត្តិ និង (៣) ប្រព័ន្ធការពារ (ឬបណ្តាញសុវត្ថិភាពសាធារណៈ) កម្រិតសមស្រប[34]។

---

[32] ប្រទេសម៉ុងហ្គូលី ការកែលម្អការវិនិយោគសាធារណៈដើម្បីដោះស្រាយបញ្ហាប្រឈមនៃការបង្កើនហេដ្ឋា រចនាសម្ព័ន្ធ ធនាគារពិភពលោក ឆ្នាំ ២០១៣។

[33] នៅអំឡុងខែ មិថុនា-សីហា ឆ្នាំ ២០១៣ ប្រាក់បញ្ញើក្នុងធនាគារ (ភាគច្រើនជាប្រាក់ដុល្លាអាមេរិក) ថយចុះប្រមាណ ៦០០ លានដុល្លាដោយសារភាពមិនប្រាកដប្រជានយោបាយពាក់ព័ន្ធនឹងការបោះឆ្នោត។

[34] គណៈកម្មាធិការ Basel ស្តីពីការត្រួតពិនិត្យធនាគារ គោលការណ៍ស្នូលសម្រាប់ការត្រួតពិនិត្យធនាគារ ប្រកដោយប្រសិទ្ធភាព ខែ កញ្ញា ឆ្នាំ ២០១២ ធនាគារសម្រាប់ការទូទាត់អន្តរជាតិ (Bank for International Settlements)

# ឃ. ប្រធានបទពិសេស ៖ អន្តរកាលនៃវិស័យកសិកម្មកម្ពុជា ៖ ហានិភ័យ និងកាលានុវត្តភាព[35]

## សេចក្តីផ្តើម




**វិស័យកសិកម្មបានចូលរួមចំណែកច្រើនបំផុតដល់កំណើនសេដ្ឋកិច្ចនៅអំឡុងទសវត្សរ៍ឆ្នាំ ២០០០ ដែលជួយប្រជាជនក្រីក្រ និងផ្តល់ផលទៅគ្រប់គ្នា។** ក្នុងអំឡុងឆ្នាំ ២០០៤-២០១២ កំណើនផសស កសិកម្ម មានចំនួន ៥,៣ ភាគរយ/ឆ្នាំ។ ប៉ុន្តែ នៅអំឡុងឆ្នាំ ២០១៣-២០១៥ អត្រាកំណើននេះបានថយចុះមកត្រឹម ១ ភាគរយ។ តើស្ថានភាពនេះមានន័យថា កម្ពុជាកំពុងស្ថិតក្នុងអន្តរកាលដែលមិន អាចផ្លាស់ប្តូរបាន ឆ្ពោះទៅរកកំណើនកសិកម្មយឺតមែនទេ? កម្ពុជាមិនអាចមានស្ថានភាពអាក្រក់នេះទេ ដោយសារតែកំណើនកសិកម្មនៅតែសំខាន់ខ្លាំងចំពោះការបន្តកាត់បន្ថយភាពក្រីក្រ និងការរីកចម្រើនរួមគ្នា។ គោលនយោបាយដែលសមស្របចំពោះការវិនិយោគទីផ្សារ និងឯកជន និងការវិនិយោគវិស័យសាធារណៈដែលមានគោលដៅចំពោះប្រព័ន្ធធារាសាស្ត្រ ការផ្សព្វផ្សាយកសិកម្ម និងសេវាកសិកម្ម "ល្អប្រសើរជាសាធារណៈ" ផ្សេងទៀត ដែលមានភាពសមស្របចំពោះថវិកាសរុបរបស់រដ្ឋាភិបាល អាចជួយធានានូវកំណើនកសិកម្មដ៏រឹងមាំ។

### ប្រវត្តិកំណើនកសិកម្មកាលពីមួយទសវត្សរ៍កន្លងទៅនេះគឺជាជោគជ័យមួយក្នុងចំណោមជាច្រើន...

**ក្នុងទសវត្សរ៍កន្លងទៅនេះ វិស័យកសិកម្មរបស់កម្ពុជាជួបប្រទះការផ្លាស់ប្តូររចនាសម្ព័ន្ធដ៏សំខាន់ ដូចមានបង្ហាញក្នុងគណនីជាតិ ហើយត្រូវបានសង្កេតឃើញនៅក្នុងអំឡុងការអង្កេតផ្សេងៗរបស់ធនាគារពិភពលោកឆ្នាំ ២០០៥ និង ២០១៣។** ទោះបីជាកសិកម្មនៅតែដើរតួនាទីសំខាន់ក៏ដោយ ក៏វិស័យនេះលែងសូវមានចំណែក "សំខាន់" ក្នុង ផសស និងកម្លាំងពលកម្មសរុបទៀតហើយ ប៉ុន្តែ "មានផលិតភាព" ច្រើនជាងមុន មានន័យថា ផលិតភាពដីកសិកម្ម និងកម្លាំងពលកម្មបានកើនឡើង។ ការផ្លាស់ប្តូរនេះត្រូវបានជំរុញដោយកំណើនវិស័យកសិកម្មដែលទ្រទ្រង់ដល់ប្រជាជនក្រីក្រ និងមានភាពរស់រវើក។

**កំណើនវិស័យកសិកម្មនៅកម្ពុជាធ្លាប់តែមានកម្រិតខ្ពស់។** នៅអំឡុងឆ្នាំ ២០០៤-២០១២ កំណើនប្រចាំឆ្នាំនៃផលិតកម្មដុលគឺ ៨,៧ ភាគរយ។ ផសស កសិកម្ម កើនឡើងចំនួន ៥,៣ ភាគរយ/ ឆ្នាំក្នុងអំឡុងពេលនេះ។ អត្រាកំណើនដ៏ខ្លាំងក្លានេះ ដែលស្ថិតក្នុងចំណោមកម្រិតខ្ពស់បំផុតក្នុងពិភព លោក បានមកពីផលិតកម្មដំណាំ ជាពិសេសគឺស្រូវ (កំណើនប្រចាំ

[35] ឧបសម្ព័ន្ធនេះគឺផ្អែកតាមរបាយការណ៍របស់ធនាគារពិភពលោក "អន្តរកម្មវិស័យកសិកម្មកម្ពុជា៖ ហានិភ័យ និងឱកាស" ការងារសេដ្ឋកិច្ច និងវិស័យ របាយការណ៍លេខ ៩៦៣០៨-KH។ របាយការណ៍ទាំងមូល អាចរកបាននៅ http://documents.worldbank.org/curated/en/2015/08/24919384/cambodian-agriculture-transition-opportunities-risks។

ឆ្នាំ ៩ ភាគរយ) និង ពោតក្រហម (២០ ភាគរយ) ដំឡូងមី (៥១ ភាគរយ) អំពៅ (២២ ភាគរយ) និងបន្លែ (១០ ភាគរយ) ប៉ុន្តែកំណើនផ្នែកបសុសត្វ និងជលផល មានកម្រិតទាប។

**កំណើនវិស័យកសិកម្មដែលជួយដល់ប្រជាជនក្រីក្រ។**

អត្រាភាពក្រីក្ររបស់កម្ពុជា បានថយចុះពី ៥០ ភាគរយនៅឆ្នាំ ២០០៧ មកត្រឹម ២១ ភាគរយនៅឆ្នាំ ២០១១ ដោយចំនួនប្រជាជនក្រីក្រ បានថយចុះពី ៧ លាននាក់មកត្រឹម ៣ លាននាក់។ ការកាត់បន្ថយភាពក្រីក្រភាគច្រើន កើតមាននៅ







តំបន់ជនបទ។ ការកាត់បន្ថយភាពក្រីក្រជាង ៦០ ភាគរយ ដោយសារវិស័យកសិកម្ម ដោយកំណើនតម្លៃអង្ករជំរុញឲ្យមានផលិតកម្មអង្ករកាន់តែច្រើន ដូច្នេះហើយបានបង្កើនប្រាក់ឈ្នួលតាមកសិដ្ឋាន។ ការកាត់បន្ថយភាពក្រីក្រនឹងបន្តពឹងផ្អែកលើភាពជោគជ័យនៃវិស័យកសិកម្មក្នុងរយៈពេលជាច្រើនឆ្នាំខាងមុខ ដោយសារតែតួនាទីដ៏សំខាន់របស់វិស័យនេះចំពោះកម្លាំងពលកម្ម តម្លៃបន្ថែម និងការនាំចេញ និងស្ថានភាពដែលថា កសិករជាច្រើនស្ថិតក្នុងចំណោមពលរដ្ឋដែលក្រីក្រ និងងាយ រងគ្រោះបំផុតនៅកម្ពុជា។

**ប្រាក់ឈ្នួលក្នុងវិស័យកសិកម្មកំពុងជួបគ្នាជាមួយនឹងប្រាក់ឈ្នួលក្រៅវិស័យកសិកម្ម។** ប្រាក់ឈ្នួលក្នុងវិស័យកសិកម្មបានកើនឡើងចំនួន ២០៦ ភាគរយ នៅចន្លោះពេលនៃការអង្កេតរបស់ធនាគារពិភពលោក ដែលធ្វើឡើងនៅចន្លោះឆ្នាំ ២០០៥ និង ២០១៣ ចំណែកប្រាក់ឈ្នួលក្រៅវិស័យកសិកម្មបានកើនឡើង ៦០ ភាគរយ។ ជាលទ្ធផល អនុបាតនៃកម្មករក្រៅវិស័យកសិកម្មម្នាក់ធៀបនឹងតម្លៃបន្ថែមក្នុងវិស័យកសិកម្មក្នុងតម្លៃបច្ចុប្បន្ន បានថយចុះមក ២,១ ភាគរយនៅឆ្នាំ ២០១២ ចុះពី ៣,២ ភាគរយនៅឆ្នាំ ២០០៤។ ចំណូលនៃកម្លាំងពលកម្មតាមកសិដ្ឋានមានការកើនឡើង។

**ការធ្វើពិពិធកម្មផលិតកម្មដំណាំបានចាប់ផ្តើម។** ទោះបីជាផលិតកម្មនៅតែផ្តោតសំខាន់លើស្រូវ ប៉ុន្តែដំណាំចម្រុះកំពុងមានការផ្លាស់ប្តូរ ដែលជំរុញដោយប្រាក់ចំណេញខ្ពស់នៃដំណាំក្រៅពីស្រូវ។ នៅឆ្នាំ ២០១៣ ចំណូលដុលកសិដ្ឋានមធ្យម (និងចំណូលចំពោះកម្លាំងពលកម្ម) គឺ ៥០៦ ដុល្លា/ហិកតា (៩,៤ ដុល្លា/ថ្ងៃ) សម្រាប់ដំឡូងមី ៣០៣ ដុល្លា/ហិកតា (៨,៨ ដុល្លា/ថ្ងៃ) សម្រាប់ពោតក្រហម និង ១.៣៩៣ ដុល្លា/ហិកតា (៧,២ ដុល្លា/ថ្ងៃ) សម្រាប់បន្លែ ធៀបនឹង ២៤៥ ដុល្លា/ហិកតា (៤,៦ ដុល្លា/ថ្ងៃ) សម្រាប់ស្រូវវស្សា និង ២៩៦ ដុល្លា/ហិកតា (៩,៦ ដុល្លា/ថ្ងៃ) សម្រាប់ស្រូវប្រាំង។ ស្រូវប្រាំងមានលក្ខណៈប្រកួតប្រជែងនឹងដំណាំផ្សេងៗ បើគិតទៅលើចំណូលនៃកម្លាំងពលកម្ម ប៉ុន្តែការពង្រីក ការដាំដុះស្រូវប្រាំងជួបប្រទះបញ្ហាដោយសារតែកង្វះប្រព័ន្ធធារាសាស្រ្ត។ ចំណែកនៃផ្ទៃដីដាំដុះស្រូវសរុបបានថយចុះពី ៨៦ ភាគរយនៅឆ្នាំ ២០០២ មកត្រឹម ៧៤ ភាគរយនៅឆ្នាំ ២០១១ ខណៈដែល ចំណែកផ្ទៃដីដាំដុះពោតក្រហម និងដំឡូងមី បានកើនឡើងយ៉ាងខ្លាំង។



**ទោះបីជាចំណែកនៃស្រូវក៏ចាប់ផ្តើមធ្វើពិពិធកម្មដែរ។** ដោយសារមានតម្រូវការពីរោងម៉ាស៊ីន កិនស្រូវទំនើប កសិករជាច្រើនកំពុងដាំដុះស្រូវផ្កាម្លិះដែលផ្តល់ប្រាក់ចំណេញច្រើន ដែលត្រូវបានប៉ាន់ស្មានថា មាន ១០ ភាគរយនៃផ្ទៃដីដាំដុះស្រូវ និង ៣០ ភាគរយនៃផលិតកម្មសរុប។ ការពង្រីកផ្ទៃដីកសិកម្មសម្រាប់ដាំដុះស្រូវផ្កាម្លិះគឺអាចទៅរួច តាមរយៈការកែលម្អគុណភាពគ្រាប់ពូជ ការផ្សព្វផ្សាយកសិកម្ម និងប្រព័ន្ធធារាសាស្ត្រ។

**ទិន្នផលកើនឡើងសម្រាប់ដំណាំភាគច្រើន។** ដោយមានកំណើនប្រចាំឆ្នាំលើផ្ទៃដីដាំដុះ ៩,៧ ភាគរយ និងផលិតកម្មដុលកសិកម្ម ៨,៧ ភាគរយ កំណើនទិន្នផលប្រចាំឆ្នាំ ៤ ភាគរយនៅអំឡុងឆ្នាំ ២០០៤-២០១២ កំណើនទិន្នផលនេះកើតចេញពីការប្រើប្រាស់បច្ចេកទេសល្អប្រសើរ ការពង្រីកប្រព័ន្ធ ធារាសាស្ត្រ (ទោះបីជានៅខ្វះខាត) ការប្រើប្រាស់ធាតុចូលទំនើប និងលទ្ធភាពល្អប្រសើរក្នុងការទទួលបានសេវាប្រើគ្រឿងយន្ត ដោយសារភាពជឿនលឿនផ្នែកពាណិជ្ជកម្ម។ ក្រៅពីនេះ កសិករក៏មាន លទ្ធផលកាន់តែប្រសើរក្នុងទីផ្សារ។

**ផលិតផលកសិដ្ឋានរបស់កម្ពុជានៅតែមានលក្ខណៈប្រកួតប្រជែងផ្នែកតម្លៃនៅតាមកសិដ្ឋាន។** ការវិភាគទៅលើការប្រកួតប្រជែងនៃការចំណាយ និងធនធានក្នុងស្រុកបង្ហាញថា ទោះបីជា មានកំណើននៃការចំណាយលើកម្លាំងពលកម្ម និងតម្លៃនៃធាតុចូលកសិដ្ឋាន ប៉ុន្តែតម្លៃបន្ថែមដែលទទួលបានពីកសិករមានចំនួនលើសពីការចំណាយនៃកត្តាផលិតកម្មក្នុងស្រុក (ដីធ្លី កម្លាំងពលកម្ម និងដើមទុន)។ ការប្រកួតប្រជែងខ្ពស់នេះបង្ហាញពីកំណើនយ៉ាងច្រើននៃការនាំចេញផលិតផលកសិ កម្មក្នុងរយៈពេលមួយទសវត្សរ៍កន្លងមក។ យ៉ាងណាក៏ដោយ ការប្រកួតប្រជែងនៃស្រូវវស្សាបានថយចុះក្នុងរយៈពេលប៉ុន្មានឆ្នាំនេះ ហើយកសិករខ្នាតតូចជាច្រើនដែលដាំដុះស្រូវធម្មតា បានចាប់ផ្តើម បាត់បង់ភាពប្រកួតប្រជែងរបស់ខ្លួន។

**កំណើនវិស័យកសិកម្មកន្លងមកកើតមានដោយសារកត្តាជាច្រើន។** ក្នុងចំណោមកត្តាសំខាន់ៗគឺពាណិជ្ជកម្មសេរី និងគោលនយោបាយកសិកម្មដែលផ្តោតលើទីផ្សារ។ កម្ពុជាស្ថិតក្នុងចំណោមប្រទេសកំពុងអភិវឌ្ឍន៍មួយចំនួនដែលមិនអាចឆ្លើយតបទៅនឹងកំណើនតម្លៃស្បៀងអាហារសកល ប៉ុន្តែ បានមើលឃើញកំណើននោះជាឱកាសបង្កើនកំណើនកសិកម្ម។ ប្រទេសនាំចេញសុទ្ធផ្សេងទៀតដូចជា ឥណ្ឌា និងវៀតណាម បានប្រើប្រាស់ការរឹតត្បិតក្នុងនាំចេញ ដើម្បីបន្ថយឥទ្ធិពលនៃកំណើនតម្លៃស្បៀងអាហារសកលទៅក្នុងទីផ្សាររបស់ខ្លួន។ តម្លៃផលិតផលកសិកម្មខ្ពស់នៅកម្ពុជាបានធ្វើឲ្យការពង្រីកដីកសិដ្ឋានទទួលបានប្រាក់ចំណេញច្រើន។ ក្រៅពីនេះ វិស័យកសិកម្មទទួលបានផលប្រយោជន៍ពី (១) កំណើនលទ្ធភាពចូលទៅក្នុងទីផ្សារបរទេស តាមរយៈកិច្ចព្រមព្រៀង "អ្វីៗគ្រប់យ៉ាងលើកលែងតែអាវុធ" ជាមួយសហភាពអឺរ៉ុប និងពាណិជ្ជកម្មសេរីឆ្លងព្រំដែនជាមួយប្រទេសជិតខាង (២) ភាពងាយស្រួល និងការប្រើប្រាស់សេវាគ្រឿងយន្តកាន់តែច្រើនជាងមុន ដោយសារតែកំណើនចំណាយខ្ពស់លើកម្លាំងពលកម្មជនបទ (៣) លទ្ធភាពកាន់តែប្រសើរក្នុងការទទួលបានហិរញ្ញវត្ថុ និង (៤) ការវិនិយោគនៃវិស័យឯកជនលើម៉ាស៊ីនកិនស្រូវ។

## ... ប៉ុន្តែ មានបញ្ហាប្រឈមជាច្រើន

**ចំណែកយ៉ាងធំនៃកំណើនវិស័យកសិកម្មកន្លងមកត្រូវបានជំរុញដោយការពង្រីកផ្ទៃដីដាំដុះ។** ការចូលរួមចំណែកជាមធ្យម (គិតតាមផ្ទៃដីដំណាំ) នៃការពង្រីកដីធ្លី ចំពោះការផ្លាស់ប្តូរចំណូលដុលពីកសិដ្ឋានក្នុងស្ថានភាពជាក់ស្តែងនៅអំឡុងឆ្នាំ

២០០៥-២០១៣ មានចំនួន ៦០ ភាគរយ (តារាង ១)។ ផ្ទៃដីដាំដុះត្រូវបានពង្រីកជាមធ្យម ៤,៧ ភាគរយ/ឆ្នាំ ដោយកំណើនយ៉ាងខ្លាំងបំផុត (១២៨ ភាគរយ) គឺដំឡូងមី។

**តារាង ១ ៖ ការផ្លាស់ប្តូរប្រចាំឆ្នាំនៃចំណូលដុលពីកសិដ្ឋានក្នុងស្ថានភាពជាក់ស្តែង អំឡុងឆ្នាំ ២០០៥-២០១៣ (%)**

| | ការផ្លាស់ប្តូរផ្ទៃដីដាំដុះ | ការផ្លាស់ប្តូរចំណូលដុល/ហិកតា | ការផ្លាស់ប្តូរចំណូលដុលសរុប |
|---|---|---|---|
| ស្រូវវស្សា | 2.1 | 2.4 | 4.5 |
| ស្រូវប្រាំង | 6.7 | 2.1 | 8.8 |
| ដំឡូងមី | 128.1 | 15.1 | 143.2 |
| ពោតក្រហម | 17.2 | -10.3 | 6.9 |
| បន្លែ | 6.4 | 44.5 | 50.9 |
| **មធ្យម** | **4.7** | **3.4** | **8.2** |

សម្គាល់ ៖ ចំណូលដុលជាប្រាក់ចំណូលដុលដកនឹងការប្រើប្រាស់ធាតុចូលផ្ទាល់ រួមទាំង ការជួល កម្លាំងពលកម្ម។ ប្រាក់ចំណូលដុលពីកសិដ្ឋានរួមមាន ស្រូវ ដំឡូងមី ពោតក្រហម និងបន្លែ។
ប្រភព ៖ ការអង្កេតរបស់ធនាគារពិភពលោកឆ្នាំ ២០០៥ និង ២០១៣

**កំណើនជាមធ្យមនៃប្រាក់ចំណូលដុលក្នុងមួយហិកតានៅថេរ គឺ ៣,៤ ភាគរយ/ឆ្នាំ។** ប៉ុន្តែ វាមានការប្រែប្រួលនៅចន្លោះពី ២,១ ភាគរយសម្រាប់ស្រូវប្រាំង រហូតដល់ ៤៤,៥ ភាគរយសម្រាប់បន្លែ។ ចំណូលដុលរបស់ពោតក្រហម/ហិកតាបានថយចុះ។ ក្នុងករណីជាច្រើន កសិករដែលពង្រីកផ្ទៃដីដាំដុះរបស់ខ្លួន ទទួលបានប្រាក់ចំណូលខ្ពស់ ប៉ុន្តែ កសិករដែលមិនផ្លាស់ប្តូរផ្ទៃដីដាំដុះមិនអាចបង្កើនប្រាក់ ចំណូលរបស់ខ្លួនច្រើនឡើយ។ អំឡុងពេលនៃការកើនឡើងនៃតម្លៃស្បៀងអាហារត្រូវបានប្រើប្រាស់ ដើម្បីពង្រីកផ្ទៃដីដាំដុះ ជាជាងបង្កើតមូលដ្ឋានរឹងមាំតាមរយៈកំណើនផលិតភាព។

**ទោះជាភាពក្រីក្របានថយចុះយ៉ាងច្រើន ចំនួនប្រជាជនដែលងាយរងគ្រោះក៏កើនឡើងច្រើនផងដែរ។** ប្រជាជនភាគច្រើនដែលរួចផុតពីភាពក្រីក្រ រួចផុតតែតិចតួចប៉ុណ្ណោះ។ ការបាត់បង់ចំណូល តែ ១.២០០ រៀល/ថ្ងៃ (ស្មើនឹងតម្លៃទឹកហូបពីរដប) អាចធ្វើឲ្យអត្រាភាពក្រីក្រនៅកម្ពុជាកើនឡើងទ្វេដងរហូតដល់ ៤០ ភាគរយ។ អត្រាដ៏ខ្ពស់នៃភាពងាយរងគ្រោះនេះជាសញ្ញានៃកំណើនផលិតភាពកសិកម្មតិចតួចបំផុត។ សន្តិសុខអាហារូបត្ថម្ភក៏ទាបជាងការកាត់បន្ថយភាពក្រីក្រដែរ ទោះបីជាប្រេវ៉ាឡង់នៃកុមារគឿដែលមានអាយុក្រោម ៥ ឆ្នាំ បានថយចុះ ៧ ភាគរយនៅចន្លោះឆ្នាំ ២០១០ និង ២០១៤ ប៉ុន្តែវានៅតែស្ថិតក្នុងអត្រាខ្ពស់ប្រមាណ ៣៣ ភាគរយដដែល។




*ប្រជាជនក្រីក្រជាប្រជាជនដែលរកប្រាក់ចំណូលបាន តិចជាង ១,១៥ ដុល្លា/ថ្ងៃ (បន្ទាត់ភាពក្រីក្រ)*




*ប្រជាជនដែលស្ទើរតែក្រីក្រ ឬងាយរងគ្រោះ ជាប្រជាជនដែលរកប្រាក់ចំណូលបានលើស ១,១៥ ដុល្លា/ថ្ងៃ ប៉ុន្តែក្រោម ២,៣០ ដុល្លា/ថ្ងៃ*

**កសិករខ្នាតតូចងាយរងគ្រោះខ្លាំងបំផុត។** កសិករខ្នាតតូច ដែលមានផ្ទៃដីដាំដុះតិចជាងមួយហិកតា បានរាយការណ៍ពីការលំបាកក្នុងការពង្រីក និងចូលរួមក្នុងខ្សែសង្វាក់តម្លៃអាហារទំនើបបច្ចុប្បន្ន។ ចំណែកនៃកសិដ្ឋានទាំងនេះក្នុងចំនួនគ្រួសារជនបទសរុបដែលមានដីធ្លី គឺ ៤៨ ភាគរយ នៅឆ្នាំ ២០១១។ ក្នុងទសវត្សរ៍កន្លងមក មាននិន្នាការនៅកម្ពុជាដែលថា កសិដ្ឋានខ្នាតធំ (លើស ៣ ហិកតា) មានកាន់តែច្រើន ហើយកសិដ្ឋានខ្នាតតូចកាន់តែរួមតូច (តិចជាង ១ ហិកតា)។ ទំហំជាមធ្យម នៃកសិដ្ឋានដែលមានទំហំតូចជាង ១ ហិកតា ដែលត្រូវបានអង្កេត បានថយចុះពី ០,៩៥ ហិកតានៅឆ្នាំ ២០០៨ មកត្រឹម ០,៨៨ ហិកតានៅឆ្នាំ ២០១២ ចំណែកទំហំជាមធ្យមនៃកសិដ្ឋានខ្នាតមធ្យម (ចន្លោះពី ១ ទៅ ៣ ហិកតា) បានកើនឡើងពី ១,៥៥ ហិកតា រហូតដល់ ២,៣៨ ហិកតា ហើយកសិដ្ឋានធំៗ (លើសពី ៣ ហិកតា) បានកើនឡើងពី ៣,៦១ ហិកតា ទៅ ៧,០៣ ហិកតា។ ទោះបីជាមានកំណើន ផលិតភាពរបស់កសិដ្ឋានខ្នាតតូចមួយចំនួនក្នុងរយៈពេលប៉ុន្មានឆ្នាំថ្មីៗនេះក្តី ផលិតភាពរបស់កសិដ្ឋានប្រពៃណីខ្នាតតូចភាគច្រើននៅតែទាប ដោយសារតែការផ្សព្វផ្សាយកសិកម្ម និងសេវាសាធារណៈ ផ្សេងទៀតមិនបានចូលទៅដល់ពួកគេឲ្យបានទូលំទូលាយ។ វាហាក់ដូចជាថា កំណើនប្រាក់ចំណូលរបស់កសិករក្រុមនេះ ក្នុងមួយទសវត្សរ៍កន្លងមក បានមកពីតម្លៃផលិតកម្មខ្ពស់ ដែលជំរុញដោយតម្លៃផលិតផលកសិកម្មខ្ពស់ និងការលក់កម្លាំងពលកម្មរបស់ពួកគេឲ្យកសិដ្ឋានខ្នាតធំដែលទទួលបានប្រាក់ឈ្នួលខ្ពស់ មិនមែនផលិតភាពដីធ្លី និងផលិតភាពកម្លាំងពលកម្មខ្ពស់ឡើយ។

**ឧស្សាហកម្មកែច្នៃកសិកម្មបានដើរតួនាទីតិចតួចក្នុងកំណើនកសិកម្ម លើកលែងតែស្រូវ។** ដំណាំស្ទើរតែទាំងអស់ត្រូវបាននាំចេញទៅប្រទេសជិតខាងដោយមិនបានកែច្នៃ។ នេះបង្ហាញពីភាពទន់ខ្សោយនៃខ្សែសង្វាក់តម្លៃ ជាពិសេសក្នុងប្រព័ន្ធនៃការគ្រប់គ្រងខ្សែសង្វាក់ផ្គត់ផ្គង់ក្រោយពេលប្រមូលផល (ការប្រមូលវត្ថុធាតុដើម ការរក្សាទុក ហិរញ្ញវត្ថុ ភស្តុភារ ការដឹកជញ្ជូន និងព័ត៌មាន)។

## អ្វីដែលដំណើរការល្អពីពេលមុន នឹងលែងគ្រប់គ្រាន់សម្រាប់ពេលអនាគតហើយ

**នៅពេលដែលតម្លៃស្បៀងអាហារសកលថយថ្លៃ ហើយព្រំដីកាន់តែរួមតូច វិស័យកសិកម្មកម្ពុជាកំពុងបាត់បង់កត្តាជំរុញកំណើនចំនួនពីរ។** ក្រៅពីនេះទៀត កម្លាំងពលកម្មកសិកម្មកំពុងតែខ្សត់ទៅៗ និងកាន់តែថ្លៃ ដែលបន្ថែមទៅនឹងការចំណាយផលិតកម្ម។ តម្លៃផលិតផលកសិកម្មសកលត្រូវបាន ព្យាករថានឹងចុះក្នុងអំឡុងទសវត្សរ៍បន្ទាប់ ហើយការលក់អង្ករធម្មតាដែលមានគុណភាពទាបជាងក្នុងទីផ្សារក្នុងស្រុក និងទីផ្សារបរទេស នឹងកាន់តែមិនសូវចំណេញ។ ការពឹងផ្អែកលើតម្រូវការខ្ពស់ ក្នុងស្រុកដែលជំរុញដោយកំណើន ផសស និង តម្រូវការសកលតែមួយមុខ ដោយមិនមានការប្រើប្រាស់ធនធានដោយប្រសិទ្ធភាព នឹងមិនអាចរក្សាអត្រាខ្ពស់នៃកំណើនវិស័យកសិកម្មរបស់កម្ពុជាកន្លងមកបានឡើយ។ កម្ពុជាត្រូវស្វែងរកកត្តាជំរុញថ្មី ដើម្បីរក្សាកំណើនកសិកម្មឲ្យបាន ៥ ភាគរយ ឬប្រហាក់ប្រហែលនេះ។

**កំណើនដ៏យឺតនៃវិស័យកសិកម្មបច្ចុប្បន្ននៅកម្ពុជាអាចបង្ហាញពីលទ្ធភាពនៃការថយចុះកំណើនរយៈពេលវែង។** នៅពេលដែលតម្លៃស្បៀងអាហារសកលថយចុះបន្តិចម្តងៗ ហើយទីផ្សារអង្ករសកលកាន់តែមានភាពប្រកួតប្រជែង ដោយមានវត្តមានរបស់ប្រទេសថៃ និងមីយ៉ាន់ម៉ា ផលិតកម្មស្រូវនៅកម្ពុជាមិនបានកើនឡើងទេ។ ទន្ទឹមនឹងនេះ តម្លៃបន្ថែមរបស់ដំណាំសរុបបានថយចុះ ពី ៤,៩ ភាគរយនៅឆ្នាំ ២០១២ មកត្រឹម ០,៦ ភាគរយនៅឆ្នាំ ២០១៣។ កំណើននៃតម្លៃបន្ថែមកសិកម្មមានភាពយឺតយ៉ាវ រហូតដល់ ១,៦ ភាគរយនៅឆ្នាំ ២០១៣ បន្ទាប់ពីកំណើនជាមធ្យមចំនួន ៥,៣ ភាគរយនៅអំឡុងឆ្នាំ ២០០៤-២០១២។

**ការត្រឡប់ទៅមានអត្រាកំណើនកសិកម្មខ្ពស់ ជាការសំខាន់។** វិស័យកសិកម្មនៅតែផ្តល់ចំណែកធំធេងដល់ ផសស ពាណិជ្ជកម្ម និងកម្លាំងពលកម្ម ដែលមានន័យថា វិស័យនេះនឹងនៅតែជាវិស័យចម្បងសម្រាប់កាត់បន្ថយភាពក្រីក្រ និងភាពងាយរងគ្រោះក្នុងទសវត្សរ៍ក្រោយ។ ប្រសិនបើកម្ពុជាបន្តផ្លាស់ប្តូររចនាសម្ព័ន្ធ ដោយមានកំណើនកសិកម្មចំនួន ៥ ភាគរយ នៅឆ្នាំ ២០៣០ កម្ពុជានឹងមានវិស័យកសិកម្មខ្នាតតូច ប៉ុន្តែកាន់តែមានផលិតភាព។ ចំណែករបស់វិស័យកសិកម្មក្នុង ផសស និងកម្លាំងពលកម្មសរុប នឹងថយចុះមកត្រឹម ១៧ ភាគរយ និង ៣១ ភាគរយនៅឆ្នាំ ២០៣០ ចុះពី ២៦ ភាគរយ និង ៥១ ភាគរយនៅឆ្នាំ ២០១២។ ទន្ទឹមនឹងនេះ ផលិតភាពដីធ្លីនឹងកើនឡើងពី ១.៣០០ ដុល្លា/ហិកតា ទៅ ២.៧០០ ដុល្លា/ហិកតា ហើយផលិតភាពកម្លាំងពលកម្មនឹងកើនឡើងពី ១.២០០ដុល្លា/ម្នាក់ រហូតដល់ ៣.៧០០ដុល្លា/ម្នាក់នៅអំឡុងពេលដូចគ្នា (តារាង ២)។

**ផ្ទុយទៅវិញ ការខូចខាតដោយសារកំណើនកសិកម្មដែលយឺត គឺធំធេង។** ប្រសិនបើវិស័យកសិកម្មមានកំណើនជាមធ្យមតែ ៣ ភាគរយក្នុងអំឡុងឆ្នាំ ២០១២-២០៣០ តម្លៃបន្ថែមនៃវិស័យកសិកម្មនឹងមានចំនួនទាបជាង ២៩ ភាគរយ នៅឆ្នាំ ២០៣០ ធៀបនឹងសេណារីយ៉ូនៃកំណើន ៥ ភាគរយ។ ស្ថានភាពនេះនឹងធ្វើឲ្យមានការកាត់ចេញពី ផសស ចំនួន ១៨ ភាគរយ ដែលធ្វើឲ្យមានប្រជាជនកាន់តែច្រើនស្ថិតក្នុងវិស័យកសិកម្ម កាត់បន្ថយផលិតភាពកម្លាំងពលកម្មក្នុងកសិកម្មចំនួន ៣៤ ភាគរយ និងពន្យឺតការមកក្បែរគ្នានៃប្រាក់ចំណូលរវាងកសិករ និងប្រជាជនដែលមិនមែនជាកសិករ។ កំណើនកសិកម្មទាបនឹងធ្វើឲ្យការកាត់បន្ថយភាពក្រីក្រកាន់តែយឺតខ្លាំង។

**តារាង ២ ៖ ផលប៉ះពាល់នៃកំណើនកសិកម្មយឺតនៅកម្ពុជា**

| សូចនាករ | 2012 | 2030 | |
|---|---|---|---|
| | | កំណើន ផសសកសិកម្ម 3% | កំណើន ផសស កសិកម្ម 5% |
| ភាគរយវិស័យកសិកម្មក្នុង ផសស | 26 | 15 | 17 |
| ភាគរយវិស័យកសិកម្មក្នុងកម្លាំងពលកម្ម | 51 | 34 | 31 |
| ផលិតភាពកម្លាំងពលកម្មក្នុងវិស័យកសិកម្ម (ដុល្លា/ម្នាក់) | 1,200 | 2,450 | 3,700 |
| ផលិតភាពដីធ្លីក្នុងវិស័យកសិកម្ម (ដុល្លា/ហិកតា) | 1,300 | 1,900 | 2,700 |
| អនុបាតផលិតភាពកម្លាំងពលកម្មក្នុងវិស័យកសិកម្ម ធៀបនឹងកម្លាំងពលកម្មក្នុងវិស័យផ្សេង | 2.1 | 2.1 | 1.6 |

ប្រភព ៖ ការប៉ាន់ស្មានរបស់បុគ្គលិកធនាគារពិភពលោក

**ចក្ខុវិស័យរយៈពេលវែងនៃវិស័យកសិកម្មកម្ពុជាត្រូវរួមបញ្ចូលសមាសភាគនៃនិរន្តរភាព ផលិតភាព ការប្រកួតប្រជែង និងកំណើនប្រាក់ចំណូល ទន្ទឹមនឹងការងាកចេញពីការផ្តោតខ្លាំងលើផលិតកម្ម។** ការពិនិត្យទៅលើសេណារីយ៉ូផ្សេងៗនៃការអភិវឌ្ឍកសិកម្មនៅថ្ងៃអនាគតបានបង្ហាញថា កំណើនផលិតភាពកសិដ្ឋាននឹងមានឥទ្ធិពលវិជ្ជមានខ្លាំងបំផុតលើប្រាក់ចំណូលកសិដ្ឋាន ជាពិសេសប្រសិនបើការផ្លាស់ប្តូរពីបែបប្រពៃណីទៅប្រើប្រាស់បច្ចេកវិទ្យាទំនើប រួមផ្សំនឹងប្រសិទ្ធភាពនៃការប្រើប្រាស់ធាតុចូលទំនើប និងប្រព័ន្ធធារាសាស្ត្រ។ កសិករដែលដាំដុះស្រូវផ្កាម្លិះ កែច្នៃដំឡូងមីជាដំឡូងស្ងួត និងធ្វើសកម្មភាពដែលផ្តល់តម្លៃបន្ថែមផ្សេងទៀត អាចបង្កើនប្រាក់ចំណូលរបស់ពួកគេបន្ថែមទៀតបាន ហើយនេះជាសារៈសំខាន់នៃឧស្សាហកម្មកែច្នៃកសិកម្ម។ ការបន្ថយការចំណាយក្នុងផលិតកម្មតាមរយៈការប្រើប្រាស់ធនធានដែលមានស្រាប់បានល្អ (ឧ. កំណើនផលិតភាព) និងការកាត់បន្ថយការ ថយចុះតម្លៃផលិតផលចេញកសិដ្ឋាន តាមរយៈការចំណាយទាបលើផ្នែកភស្តុភារ ជាគន្លឹះនៃការរក្សារការប្រកួតប្រជែងកសិដ្ឋាន។ ក្រៅពីនេះ ការបន្តពង្រីកផ្ទៃដីដាំដុះនឹងផ្តល់ប្រាក់ចំណូលបន្ថែម ប៉ុន្តែកត្តានិរន្តរភាពនឹងរិតត្បិតការពង្រីកផ្ទៃដីទំហំច្រើននៅថ្ងៃអនាគត។ ឧបសគ្គនេះធ្វើឲ្យផលិតភាពកសិកម្ម ការធ្វើពាណិជ្ជកម្ម និងពិពិធកម្ម កាន់តែមានសារៈសំខាន់ក្នុងការធានានូវកំណើនវិស័យកសិកម្មដែលកាត់បន្ថយភាពក្រីក្រ និងជំរុញការរីកចម្រើនរួមនៅកម្ពុជា។

**អនុសាសន៍ ៖**

ក/ **កំណើនយ៉ាងលឿន និងជាបន្តក្នុងវិស័យកសិកម្ម និងការបន្តផ្លាស់ប្តូររចនាសម្ព័ន្ធក្នុងវិស័យកសិកម្ម អាចធ្វើទៅបានសម្រាប់កម្ពុជា។** គោលនយោបាយចំនួន ៤ អាចជួយគាំទ្រកំណើនវិស័យកសិកម្មនេះក្នុងអំឡុង ៥ ឆ្នាំទៅមុខ។ ទីមួយ គឺការរក្សាបរិយាកាសគោលនយោបាយកសិកម្មដែលសមស្របចំពោះវិស័យឯកជន ដោយត្រូវផ្តោតបន្ថែមទៅលើការសម្រាលបន្ទុកផ្នែកត្រួតពិនិត្យចំពោះធាតុចូលនៅកសិដ្ឋាន។ ទីពីរ គឺការពង្រឹងនិរន្តរភាពបរិស្ថាននៃផលិតកម្មកសិកម្ម។ ទីបី គឺការបង្កើនគុណភាពកម្មវិធីសាធារណៈផ្នែកកសិកម្ម និង (ទៅលទ្ធភាពនៃថវិកាសរុបរបស់រដ្ឋាភិបាលកម្ពុជា) បង្កើនវិភាជថវិកាដល់កម្មវិធីដែលកាន់តែមានប្រសិទ្ធភាព។ ទីបួន គឺការជួយអភិវឌ្ឍកសិអាជីវកម្ម និងឧស្សាហកម្មកែច្នៃកសិកម្ម។

ខ/ **ការរក្សាបរិយាកាសគោលនយោបាយកសិកម្មដែលសមស្របចំពោះវិស័យឯកជន**

**គោលនយោបាយកសិកម្មកម្ពុជាដែលផ្តោតលើទីផ្សារ និងគោលនយោបាយពាណិជ្ជកម្មសេរីបានជួយដល់ការសម្រេចបានកំណើនវិស័យកសិកម្មកម្រិតខ្ពស់នាពេលកន្លងមក។** វិស័យឯកជនទទួលបានប្រយោជន៍ពីការអន្តរាគមន៍តិចតួច ប្រសិនបើមាន លើការកំណត់តម្លៃផលិតផលកសិដ្ឋាន និងធាតុចូល ពីការប្តេជ្ញាចិត្តខ្ពស់ចំពោះពាណិជ្ជកម្មសេរី ដូចជា ពាណិជ្ជ កម្មឆ្លងព្រំដែន និងពីការកាត់បន្ថយការចំណាយលើការនាំចេញ និងពេលវេលានៃការជម្រះ បញ្ជីឯកសារ។ ស្ថានភាពនេះបានជំរុញឲ្យកសិករ និងតួអង្គផ្សេងទៀត ធ្វើការវិនិយោគ និងបង្កើតប្រាក់ចំណេញ។ គោលនយោបាយពាណិជ្ជកម្មសេរី និងគោលនយោបាយកសិកម្ម ដែលផ្តោតលើទីផ្សារទាំងនេះ នៅតែមានសារៈសំខាន់សម្រាប់កំណើននាពេលខាងមុខ ហើយត្រូវមានការការពារដោយប្រើគ្រប់មធ្យោបាយទាំងអស់។

**ក្រៅពីការរក្សាគោលនយោបាយកសិកម្មដែលគ្មានការកេងចំណេញ កំណែទម្រង់ក្នុងវិស័យគ្រាប់ពូជអាចជួយដល់កំណើនវិស័យកសិកម្ម។** ការផ្គត់ផ្គង់គ្រាប់ពូជមិនបានគ្រប់គ្រាន់ និងគុណភាពគ្រាប់ពូជមិនល្អនៅកម្ពុជា គឺជាមូលហេតុចម្បងដែលធ្វើឲ្យមានផលិតភាពទាប ដែលបានបង្កជាឧបសគ្គចំពោះកំណើនវិស័យកសិកម្មនៅថ្ងៃខាងមុខ ដោយសារតែការវិនិយោគលើជី និងគ្រឿងម៉ាស៊ីន ទទួលបានផលមកវិញ លុះត្រាតែមានការផ្សំទៅនឹងការប្រើប្រាស់គ្រាប់ ពូជល្អប៉ុណ្ណោះ។ មានការកេងចំណេញនៃគោលនយោបាយជាច្រើនក្នុងវិស័យគ្រាប់ពូជ ដែល មានពីការផ្តាច់មុខរបស់រដ្ឋក្នុងការផ្គត់ផ្គង់គ្រាប់ពូជជាមូលដ្ឋាន រហូតដល់កង្វះបទប្បញ្ញត្តិ ច្បាស់លាស់ ដែលអនុគ្រោះសម្រាប់ការសាកល្បង ផ្សព្វផ្សាយ ផលិតកម្ម និងការនាំចូល គ្រាប់ពូជ។ ត្រូវដោះស្រាយឧបសគ្គផ្នែកបទប្បញ្ញត្តិ និងច្បាប់ក្នុងវិស័យគ្រាប់ពូជក្នុងរយៈពេលប៉ុន្មានឆ្នាំខាងមុខ។

**បទប្បញ្ញត្តិពាក់ព័ន្ធនឹងធាតុចូល ដូចជា ជី ក៏អាចធ្វើការកែលម្អដើម្បីកាត់បន្ថយការចំណាយរបស់កសិករ។** ថ្មីៗនេះកម្ពុជាបានដាក់លក្ខខណ្ឌដ៏ស្មុគស្មាញជាច្រើនសម្រាប់ ក្រុមហ៊ុននាំចូលជីក្នុងការចុះបញ្ជីផលិតផល និងដាក់ពាក្យសុំអាជ្ញាប័ណ្ណនាំចូល។ នីតិវិធីទាំងនេះគួរតែត្រូវធ្វើឲ្យសាមញ្ញ តាមរយៈការផ្តល់អាជ្ញាប័ណ្ណនាំចូលទៅតាមភាពសមស្របនៃផលិតផល ហើយនៅពេលទទួលបានគ្រប់ទាំងអស់ហើយ ក្រុមហ៊ុននាំចូលទាំងអស់ត្រូវ អនុញ្ញាតឲ្យនាំចូលដោយសេរីនូវបរិមាណធាតុចូលដែលបានចុះបញ្ជីទាំងនោះ។

## គ/ ការពង្រឹងនិរន្តរភាពបរិស្ថាន

**ការបញ្ចូលនិរន្តរភាពបរិស្ថានទៅក្នុងគោលនយោបាយកសិកម្មមានសារៈសំខាន់កាន់តែខ្លាំង។** ការពង្រីកយ៉ាងលឿននៃដីដាំដុះ ក្នុងចំនួន ៤,៧ ភាគរយក្នុងមួយឆ្នាំក្នុងអំឡុងឆ្នាំ ២០០៥ ដល់ ២០១៣ ដែលជាញឹកញាប់ធ្វើឲ្យព្រៃឈើថយចុះ មិនប្រកបដោយនិរន្តរភាពទេ។ ត្រូវមានការពង្រីកផ្ទៃដីដាំដុះដែលកាន់តែមាននិរន្តរភាព តាមរយៈការរៀបចំផែនការប្រើប្រាស់ដីធ្លីកាន់តែប្រសើរ ការពង្រឹងសុវត្ថិភាពចំពោះកម្មសិទ្ធិដីធ្លី និងការរក្សាជីជាតិដីតាមរយៈការប្រើប្រាស់ដីធ្លីដែលមានស្រាប់ឲ្យបានល្អ និងការជំរុញការគ្រប់គ្រងដីធ្លីប្រកបដោយនិរន្តរភាព។ បទពិសោធន៍អន្តរជាតិបង្ហាញថា វិធីដ៏មានប្រសិទ្ធភាពបំផុតក្នុងការជំរុញសកម្មភាពទាំងនេះគឺត្រូវរួមបញ្ចូលការការពារធនធានធម្មជាតិ ជាមួយនឹងការផ្សព្វផ្សាយកសិកម្ម និងកម្មវិធីសាធារណៈផ្សេងទៀតដែលបង្កើនការយល់ដឹងរបស់អ្នកប្រើប្រាស់ដីធ្លីពីការខាតបង់ និងផល ប្រយោជន៍រយៈពេលវែង និងជំរុញការប្រើប្រាស់បច្ចេកវិទ្យាទំនើប។

**នៅពេលកសិករកាន់តែច្រើនប្រើប្រាស់សារធាតុគីមីកសិកម្មលើបន្លែ និងដំណាំផ្សេងទៀត រដ្ឋាភិបាលត្រូវពង្រឹងបទប្បញ្ញត្តិសុខភាពសាធារណៈ ដែលពាក់ព័ន្ធនឹងការប្រើប្រាស់ដោយសុវត្ថិភាព និងជំរុញកម្មវិធីជាជម្រើសផ្សេងទៀត ដែលធានាបាននូវការគ្រប់គ្រងសត្វចង្រៃដែល មានភាពសមស្របចំពោះបរិស្ថាន មានប្រសិទ្ធភាព និងសុវត្ថិភាព។** កម្មវិធីជាជម្រើសទាំងនេះរួមមាន ការគ្រប់គ្រងសត្វចង្រៃចម្រុះ ដោយចំនួនសត្វចង្រៃត្រូវបានគ្រប់គ្រងដោយការគ្រប់គ្រងជីវសាស្ត្រ សកម្មភាពវប្បធម៌ និងការបង្កើត និងប្រើប្រាស់ដំណាំចម្រុះដែលធន់ ឬអាច ប្រឆាំងនឹងសត្វចង្រៃ។

## ឃ/ ការបង្កើនការវិនិយោគ "ទំនិញសាធារណៈ" ក្នុងវិស័យកសិកម្ម

**កំណើនវិស័យកសិកម្មនៅថ្ងៃខាងមុខនឹងបានមកពីការបង្កើនផលិតភាព ការធ្វើពាណិជ្ជកម្ម និងពិពិធកម្ម ដែលសុទ្ធតែពឹងផ្អែកលើការវិនិយោគ "ទំនិញសាធារណៈ" ក្នុងវិស័យកសិកម្មប្រកបដោយប្រសិទ្ធភាព។** កសិដ្ឋានភាគច្រើនដែលមានទំហំតូចនៅកម្ពុជា និងចំនួនដ៏ច្រើននៃកសិដ្ឋាននេះ (ប្រហែល ៥០ ភាគរយនៃកសិដ្ឋាននៅកម្ពុជាមានទំហំដល់ ១ ហិកតា) ទាមទារឲ្យមានធនធានបន្ថែមទៀតសម្រាប់ការផ្តល់សេវា ជាងក្នុងបណ្តាប្រទេសដែលមានកសិដ្ឋានខ្នាតធំ និងកសិករតិច។ កម្មវិធីសាធារណៈទូទាំងពិភពលោកដែលធ្វើឲ្យមានកំណើនវិស័យកសិកម្មរយៈពេលវែង រួមមាន ប្រព័ន្ធធារាសាស្ត្រ ការស្រាវជ្រាវ ការផ្សព្វផ្សាយ ការអប់រំ ការបណ្តុះបណ្តាលវិជ្ជាជីវៈ សុវត្ថិភាពស្បៀងអាហារ និងការផ្តល់ព័ត៌មានទីផ្សារ។ ខណៈដែលកម្មវិធីទាំងនេះក៏មានសារៈសំខាន់សម្រាប់កំណើនវិស័យកសិកម្ម និងការផ្លាស់ប្តូររចនាសម្ព័ន្ធជាបន្តបន្ទាប់របស់កម្ពុជាផងដែរនោះ កម្មវិធីទាំងនេះមិនសូវបានជួយដល់កំណើនវិស័យ កសិកម្មនាពេលកន្លងមកទេ។ នេះគឺដោយសារតែប្រសិទ្ធភាព និងប្រសិទ្ធផលទាប។ កម្មវិធីជាច្រើនត្រូវបានរៀបចំឡើងមិនបានល្អ និងខ្វះការអនុវត្ត។ ចំណាយភាគច្រើនផ្តោតលើដើមទុន និងប្រាក់ឈ្នួលដោយមានការចំណាយតិចតួចលើប្រតិបត្តិការ និងការជួសជុល។ កម្រិតផ្តល់មូលនិធិទាបគឺជាមូលហេតុមួយទៀតនៃការខ្វះកម្មវិធីទាំងនេះនៅកម្ពុជា។

**ត្រូវមានការយកចិត្តទុកដាក់ខ្លាំងជាងមុនទៅលើការផ្សព្វផ្សាយកសិកម្ម។** កម្មវិធីនេះមាន សារៈសំខាន់ក្នុងការបង្កើនជំនាញ និងចំណេះដឹងកសិករ ដើម្បីប្រើប្រាស់ការអនុវត្តការដាំដុះ បែបទំនើប និងពង្រីកប្រព័ន្ធដាំដុះស្រូវរបស់ពួកគេ។ គោលនយោបាយផ្សព្វផ្សាយកសិកម្ម ដែលទើបតែបានទទួលការអនុម័តនាពេលថ្មីៗនេះ បង្កើតជាបរិយាកាសល្អដើម្បីសាកល្បង វិធីសាស្ត្រជាជំរើសផ្សេងៗ ដើម្បីផ្តល់សេវាផ្សព្វផ្សាយ រួមទាំងការជួលបន្តទៅវិស័យឯកជនឲ្យផ្តល់សេវាកម្ម។ លើសពីនេះទៀត ការផ្សព្វផ្សាយត្រូវតែមានភាពសមស្របផ្នែកយេនឌ័រ ព្រោះថា គ្រួសារដែលមានស្ត្រីជាមេគ្រួសារ និងស្ត្រីក្នុងគ្រួសារដែលមានបុរសជាមេគ្រួសារមានតម្រូវការខុសពីបុរស ដោយសារតែតួនាទីខុសគ្នាក្នុងផលិតកម្មកសិកម្ម និងដោយសារតែកង្វះពេលវេលារបស់ស្ត្រី និងកង្វះចល័តភាពដែលមានឥទ្ធិពលលើលទ្ធភាពទទួលបានការបណ្តុះបណ្តាល។

**ត្រូវមានការយកចិត្តទុកដាក់ជាពិសេសលើការវិនិយោគលើប្រព័ន្ធធារាសាស្ត្រ។** បើសិនជាគ្មានលទ្ធភាពពិតប្រាកដក្នុងការទទួលបានទឹកក្នុងប្រទេសដែលអាកាសធាតុត្រូពិច ដូចជា កម្ពុជា ជាការលំបាកចំពោះការធ្វើប្រពលវប្បកម្ម និងការធ្វើពាណិជ្ជកម្ម។ លទ្ធភាពរបស់កសិករ ក្នុងការទទួលបានទឹកនៅរដូវប្រាំង នៅពេលដែលមានត្រូវការខ្ពស់ មានភាពល្អប្រសើរតែតិចតួចប៉ុណ្ណោះ។ ការមានប្រព័ន្ធធារាសាស្ត្រនៅកម្ពុជាស្ថិតក្នុងកម្រិតទាបបំផុតនៅអាស៊ី ទោះបីជាការបែងចែកធនធានភាគច្រើនលើការវិនិយោគប្រព័ន្ធធារាសាស្ត្រ ត្រូវបានចំណាយលើហេដ្ឋារចនាសម្ព័ន្ធសំខាន់ក្តី។ ខណៈដែលកម្រិតនៃប្រព័ន្ធធារាសាស្ត្រត្រូវមានការពង្រីកបន្ថែម ការពង្រីកនេះត្រូវដើរទន្ទឹមគ្នានឹងការពង្រីកប្រឡាយ ការស្តារ និងកែលម្អប្រព័ន្ធដែល មានស្រាប់ ការវិនិយោគលើការគ្រប់គ្រងប្រព័ន្ធធារាសាស្ត្រដោយមានការចូលរួម និងហេរដ្ឋា រចនាសម្ព័ន្ធប្រព័ន្ធបង្ហូរទឹក និងការសម្រសម្រួលល្អប្រសើរលើការគ្រប់គ្រងប្រព័ន្ធធារាសាស្ត្រ ឬទឹកជំនន់ ដោយមានការផ្តល់សេវាសាធារណៈផ្នែកកសិកម្មផ្សេងទៀត។

**ត្រូវមានការផ្តោតខ្លាំង ចំពោះការបញ្ចូលកសិដ្ឋានខ្នាតតូចទៅក្នុងខ្សែសង្វាក់គុណតម្លៃស្បៀងអាហារទំនើប។** សេវាផ្សព្វផ្សាយសាធារណៈមានសារៈសំខាន់បំផុតសម្រាប់កសិដ្ឋានទាំងនេះ ដោយសារកសិដ្ឋានទាំងនោះមិនងាយនឹងទទួលបានសេវាផ្សព្វផ្សាយគ្រប់គ្រាន់ពីវិស័យឯកជននោះទេ ខណៈដែលនៅពេលមិនមានការបង្កើនជំនាញគ្រប់គ្រងកសិដ្ឋាន និងព័ត៌មាន ពួកគេនៅតែក្រីក្រ និងងាយរងគ្រោះ និងត្រូវបានកាត់ផ្តាច់ពីដំណើរការអភិវឌ្ឍសេដ្ឋកិច្ច។ កសិដ្ឋានខ្នាតតូច រួមទាំង គ្រួសារដែលចូលរួមក្នុងដីសម្បទានសង្គមកិច្ច អាចទទួលបានការគាំទ្រតាមរយៈសេវាសាធារណៈ ដើម្បីសម្របសម្រួលទំនាក់ទំនងយ៉ាងខ្លាំងជាមួយឧស្សាហកម្មកសិអាជីវកម្ម និងកែច្នៃកសិកម្មតាមរយៈភាពជាដៃផលិត (ឧ. ការធ្វើកសិកម្មជាប់កិច្ចសន្យា និងសមាគមកសិករ) ការបណ្តុះបណ្តាលផ្នែកអាជីវកម្ម និងជំនាញផ្សេងទៀត និងការផ្តល់ព័ត៌មានទីផ្សារ។

### ង/ ការជួយអភិវឌ្ឍឧស្សាហកម្មកសិអាជីវកម្ម និងកែច្នៃកសិកម្ម

**ទោះបីជាការអភិវឌ្ឍឧស្សាហកម្មកសិអាជីវកម្ម និងកែច្នៃកសិកម្ម គួរត្រូវបានចាត់ទុកជាផ្នែកមួយនៃការកែលម្អបរិយាកាសអាជីវកម្មរួមនៅកម្ពុជា ផ្នែកជាច្រើនដែលមានផលប៉ះពាល់ខ្លាំងលើការអភិវឌ្ឍកសិអាជីវកម្មត្រូវមានវិធានការរដ្ឋាភិបាល។** វិធានការទាំងនេះរួមមានការវិនិយោគលើ (១) កំណើនលទ្ធភាពនៃការមានអគ្គិសនីប្រើប្រាស់ និងការបញ្ចុះតម្លៃអគ្គិសនី (មួយគីឡូវ៉ាត់ថ្លៃពី ០,១៦ ដល់ ០,២៣ ដុល្លាអាមេរិក នៅកម្ពុជា ដោយតម្លៃអគ្គិសនីនៅប្រទេសថៃតែ ០,១៣ ដុល្លាអាមេរិក នៅវៀតណាម តែ ០,០៨ ដុល្លាអាមេរិកប៉ុណ្ណោះ) ដើម្បី បង្កើនប្រាក់ចំណេញនៅ

ក្នុងឧស្សាហកម្មកែច្នៃ និងជំរុញការវិនិយោគពីវិស័យឯកជន (២) មានសមត្ថភាពខ្ពស់ជាងមុនផ្នែកសុវត្ថិភាពស្បៀងអាហារ អនាម័យ និងភូតគាមអនាម័យ ដើម្បីជួយឲ្យសហគ្រាសកម្ពុជាបំពេញតាមលក្ខខណ្ឌរបស់ក្រុមហ៊ុននាំចូល និងចាប់យក ចំណែកទីផ្សារបរទេស និងជួយពួកគេក្នុងការប្រកួតប្រជែងជាមួយកំណើននៃការនាំចូលអាហារ ដោយសារតែកំណើនប្រាក់ចំណូលរបស់ប្រជាជនកម្ពុជា និងតម្រូវការអាហារចម្រុះ (៣) ភស្តុភារក្នុងការនាំចេញ ដើម្បីកាត់បន្ថយការចំណាយប្រតិបត្តិការ និង (៤) ការបង្កើនលទ្ធភាពទទួលបានហិរញ្ញវត្ថុ រួមទាំង តាមរយៈការទទួលទុកក្នុងឃ្លាំង ដើម្បីបង្កើតឱកាសវិនិយោគថ្មីសម្រាប់ឧស្សាហកម្ម និងពាណិជ្ជកម្មកែច្នៃ។

**កំណើនវិស័យកសិកម្មនៅថ្ងៃខាងមុខក្នុងកម្រិតខ្ពស់ពីពេលមុន និងការបន្តការផ្លាស់ប្តូររចនាសម្ព័ន្ធ អាចមាននៅកម្ពុជា។** មិនត្រូវឲ្យកំណើនវិស័យកសិកម្មដ៏យឺតក្លាយជារបត់ថ្មីនោះទេ។ ការយកចិត្តទុកដាក់បន្ថែមលើនិរន្តរភាព គុណភាពសេវាកសិកម្ម បរិយាកាសគោលនយោបាយសមស្រប និងការអនុវត្ត នឹងសុទ្ធតែជាកត្តាសំខាន់ៗក្នុងការសម្រេចបានជាក់ស្តែងនូវលទ្ធភាពទាំងនេះ។ កិច្ចប្រឹងប្រែងពិតជាត្រូវការជាចាំបាច់។

# សូចនាករសំខាន់ៗនៅប្រទេសកម្ពុជា

| | 2012 | 2013 | 2014 | 2015p | 2016f | 2017f |
|---|---|---|---|---|---|---|
| **ទិន្នផល តម្រូវការក្នុងស្រុក និងតម្លៃ** | | | | | | |
| ផសសពិត (% ប្រែប្រួលធៀប នឹងឆ្នាំមុន) | 7.3 | 7.4 | 7.1 | 6.9 | 6.9 | 6.8 |
| តម្រូវការក្នុងស្រុក (% ប្រែប្រួលធៀបនឹងឆ្នាំមុន) | 14.9 | 12.1 | 12.4 | 11.0 | 10.7 | 11.1 |
| សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ (ចុងគ្រា % ប្រែប្រួលធៀបនឹង ឆ្នាំមុន) | 2.5 | 4.6 | 1.2 | 1.5 | 2.0 | 2.0 |
| **វិស័យសាធារណៈ (% នៃផសស)** | | | | | | |
| ប្រាក់ចំណូលរបស់រដ្ឋាភិបាល | 15.3 | 15.1 | 16.6 | 16.9 | 16.5 | 17.0 |
| ការចំណាយរបស់រដ្ឋាភិបាល | 21.0 | 21.5 | 20.1 | 20.6 | 20.5 | 21.0 |
| តុល្យភាពចំណាយរបស់ រដ្ឋាភិបាលមិនគិតជំនួយឥតសំណង | -5.7 | -6.4 | -3.5 | -3.7 | -4.0 | -4.0 |
| តុល្យភាពចំណាយរបស់រដ្ឋាភិបាល គិតទាំងជំនួយឥតសំណង | -3.3 | -2.7 | -0.3 | -1.6 | -2.0 | -2.3 |
| **ពាណិជ្ជកម្មក្រៅប្រទេស ជញ្ជីងទូទាត់ និងបំណុលបរទេស** (គិតជាលានដុល្លារអាមេរិក លើកលែងតែគិតខុសពីនេះ) | | | | | | |
| ជញ្ជីងពាណិជ្ជកម្ម | -2,455.7 | -2,598.4 | -3,010.7 | -3,129.1 | -3,536.0 | -4,058.1 |
| ការនាំចេញទំនិញ | 5,632.8 | 6,890.2 | 7,569.1 | 8,289.2 | 9,135.1 | 10,033.2 |
| (%ប្រែប្រួលធៀបនឹងឆ្នាំមុន) | 7.9 | 22.3 | 9.9 | 9.5 | 10.2 | 9.8 |
| ការនាំចេញសំខាន់ៗ (% ប្រែប្រួលធៀបនឹងឆ្នាំមុន) 1/ | 7.0 | 17.6 | 11.7 | 12.0 | 14.0 | 14.0 |
| ការនាំចូលទំនិញ (លានដុល្លាអាមេរិក) | 8,088.5 | 9,488.6 | 10,579.8 | 11,418.3 | 12,671.1 | 14,091.3 |
| (%ប្រែប្រួលធៀបនឹងឆ្នាំមុន) | 20.6 | 17.3 | 11.5 | 7.9 | 11.0 | 11.2 |
| តុល្យភាពគណនីចរន្ត (លានដុល្លាអាមេរិក) 2/ | -1,376.0 | -1,639.0 | -1,793.7 | -1,920.4 | -2,033.2 | -2,274.7 |
| (% ផសស) | -9.7 | -10.7 | -10.8 | -10.5 | -10.3 | -10.6 |
| វិនិយោគផ្ទាល់ពីបរទេស | 1,697.9 | 1,826.1 | 1,676.9 | 1,549.5 | 1,652.9 | 1,747.7 |
| បំណុលបរទេស(លានដុល្លាអាមេរិក) | 4,547.4 | 5,110.7 | 5,555.4 | 6,020.0 | 6,469.3 | 6,894.5 |
| (% ផសស) | 32.1 | 33.3 | 33.4 | 32.8 | 32.8 | 32.2 |
| អនុបាតសេវាបំណុល(%ប្រែប្រួលធៀបនឹងឆ្នាំមុន) | 1.0 | 1.1 | 1.3 | 1.3 | 1.5 | 1.7 |
| ទុនបម្រុងរូបិយប័ណ្ណបរទេសដុល | 3,463.0 | 3,642.5 | 4,657.9 | 5,665.2 | 6,398.7 | 6,847.7 |
| (ចំនួនខែនៃការនាំចូលទំនិញ និងសេវា) | 3.1 | 3.5 | 4.1 | 4.5 | 4.5 | 4.4 |
| **ទីផ្សារហិរញ្ញវត្ថុ** | | | | | | |
| ឥណទានក្នុងប្រទេស (%ប្រែប្រួលធៀបនឹងឆ្នាំមុន) | 29.6 | 28.6 | 28.4 | 27.0 | 25.8 | 25.0 |
| អត្រាការប្រាក់រយៈពេលខ្លី (% ក្នុងមួយឆ្នាំ) | 11.6 | 11.3 | 11.5 | 12.0 | 12.2 | 11.8 |
| អត្រាប្តូរប្រាក់ (ប្រាក់រៀល/ដុល្លាអាមេរិក, ចុងគ្រា) | 3,995.0 | 3,995.0 | 4,075.0 | 4,054.0 | 4,058.0 | 4,062.0 |
| អត្រាប្តូរប្រាក់ពិត (2010=100) | 105.4 | 109.9 | 112.1 | 113.5 | 115.5 | 117.8 |
| (%ប្រែប្រួលធៀបនឹងឆ្នាំមុន) | 0.5 | 4.3 | 2.0 | 1.3 | 1.7 | 2.0 |
| ចំណាំ ៖ ផសសធម្មតា (លានដុល្លាអាមេរិក) | 14,188 | 15,362 | 16,623 | 18,363 | 19,711 | 21,412 |

ប្រភព ៖ អាជ្ញាធរកម្ពុជា មូលនិធិរូបិយវត្ថុអន្តរជាតិ និងការប៉ាន់ស្មាន របស់បុគ្គលិកធនាគារពិភពលោក

f = ព្យាករណ៍

p = ប៉ាន់ស្មាន

1/ សម្លៀកបំពាក់

2/ មិនគិតបង្វែរផ្លូវការ

WORLD BANK GROUP

ធនាគារពិភពលោក
ការិយាល័យប្រចាំប្រទេសកម្ពុជា
ផ្ទះលេខ  មហាវិថីនរោត្តម១១៣
រាជធានីភ្នំពេញ ប្រទេសកម្ពុជា
ទូរស័ព្ទ ៖ (៨៥៥-២៣) ៨៦១ ៣០០
ទូរសារ ៖ (៨៥៥-២៣) ៨៦១ ៣០១/៣០២
គេហទំព័រ ៖ www.worldbank.org/cambodia